ជនសङ्គហត្ថ	បុ.	[ជន + សङ្គហ + អត្ថ] ប្រយោជន៍ដល់ក.សង្គ្រោះដល់ជន, ត្រូវការដល់សេចក្តីសង្គ្រោះដល់ជន។
ជនាធិប	គុ. បុ.	[ជន + អធិប] ជាធំជាងជន (ស្តេច, ព្រះរាជាសាមញ្ញដូច **ទិសម្បតិ**), វិ. **ជនានំ អធិបោ>ជនាធិបោ។**
ជនាលយ	បុ.	លំនៅនៃជន, មណ្ឌប (ដូច **មណ្ឌប**) ។
ជនិកា	ឥ.	ម្តាយ, មាតា (ដូច **ជនេត្តី**) ។
ជនិន្ទ	គុ.	[ជន + ឥន្ទ] ជាធំជាងជន (ស្តេច), វិ. **ជនានំ ឥន្ទោ>ជនិន្ទោ**។
ជនេតិ	កិ.	[ជន + ណេ + តិ-រ.] ញ៉ាំង....ឲ្យកើត, បង្កើត។
ជនេត្តិកា	ឥ.	[ជន+តិ+ណ្ឌ+ក-ស.] (ស្រី) អ្នកញ៉ាំងកូនឲ្យកើត (ម្តាយ), វិ. **ជនេតីតិ> ជនេត្តី, ជនេត្តី ឯវ>ជនេត្តិកា។**
ជនេត្តី	ឥ.	ម្តាយ, មាតា (ដូច **អម្ម**) ។
ជនេត្វា	អ.	[ជន + ណេ + ត្វា] ញ៉ាំង....ឲ្យកើតហើយ, បង្កើតហើយ។
ជនេន្ត	គុ.	[ជន + ណេ + អន្ត] កាលញ៉ាំង...ឲ្យកើត។
ជនេសិ	កិ.	[ជន + ណេ + ណ្ឌ-អជ្ជ. + ស-អា.] ញ៉ាំង....ឲ្យកើតហើយ។
ជនេសុត	គុ.	[ជន + សុត] ប្រាកដហើយក្នុងពួកនៃជន។
ជនេស្សាមិ	កិ.	[ជន + ណេ + ស្សាមិ-ភ.] នឹងញ៉ាំង....ឲ្យកើត។
ជន្តាឃរ	នបុ.	រោងភ្លើង (ដូច **អគ្គិសាលា**) ។ -**ជន្តាឃរវត្តាទិ** គុ. (វត្ត) មានជន្តាឃរវត្តជាដើម, មានវត្តគឺភិក្ខុគប្បីធ្វើក្នុងផ្ទះជាទីញ៉ាំងសរីរៈឲ្យក្តៅជាដើម, មានវត្តគឺភិក្ខុគប្បីធ្វើក្នុងរោងភ្លើង (ផ្ទះបាយ) ជាដើម។
ជន្តុ	បុ.	[ជន + តុ] អ្នកបង្កើតឬអ្នកកើតអំពីកម្មក្តិលេស (សត្វដូច **លោក**), វិ. **ជាយតីតি>ជន្តុ, ជាយតি កម្មក្តិលេសេហីតি ឥតি>ជន្តុ**។
ជន្ទ	នបុ.	ជង្គង់ (ដូច **ឩរុបព្ព**) ។
ជន្ទុក	នបុ.	[ជន + ណេ + ក-ស.] (អវយវ:) ជាគ្រឿងញ៉ាំងដំណើរឲ្យកើត (ជង្គង់, ក្បាលជង្គង់), វិ. **ជាយតি ឥមនមេតেនাতি>ជន្ទុ, ជន្ទុ ឯវ>ជន្ទុកំ** ។ -**មត្ត** គុ. មានជង្គង់ជាប្រមាណ។ -**ឃ្យមាណាឩរុឃ្យមាណកដ្ឍ-ណាទិ** គុ. មានជង្គង់ជាប្រមាណនិងមានភ្លៅជាប្រមាណនិងមានចង្កេះជាប្រមាណជាដើម, (មានត្រឹមជង្គង់និងត្រឹមភ្លៅនិងត្រឹមចង្កេះជាដើម) ។
ជនি	ធា.	១- **សទ្ទេ ជនতি** "ចេញសំឡេង, ស្រែក" ភូ. អា. **ឯកោ ឥជ្ជតោ ជនতি** "ពស់មួយឲ្យសំឡេង" ។ **ជនតীতি សុសូតি សទ্দং ករোতি** -ស. ។ ២- **ជនេ ជញ្ញតি** "ធ្វើ, ឲ្យកើត, បង្កើត" ទិ. ។ ធាតុនេះជាសកម្មធាតុ =**ករোতি** ធ្វើបើជាចុ.វិញទៅជា **ជនেতি ជនযতি សុទ্ধកត្តុ**

=**ករោតិ** ធ្វើ ឬការិត. =**និព្វត្តេតិ** បង្កើត -ស. ។ **ជនកោ** បុ. "ឪពុក, បិតា" អ្នកបង្កើត (ជនិ+ណ្ឍ) ។**ជនេត្តី ជនេនី ជនិតា** ឥ. ម្តាយ, មាតា បង្កើត" (ជនិ+យុ, ជនិ+តិ) ។ **បុថុជ្ជន** បុ."បុថុជ្ជន, ជនសាមញ្ញ" ឲ្យ កិលេសកើតច្រើន។

៣-**ជាតុភាវេ ជាយតិ ជាតោ ជាតិ ជនំ** "កើត, ប្រាកដ,..." ទិ. ។ ធាតុនេះជាអកម្មធាតុ ឧ. **បុត្តោ ជាយតិ**។ បើមាន **ឥ** បុព្វបទ ក្លាយ ទៅជាសកម្មធាតុវិញ ឧ. **ឥត្តី បុត្តំ ឥជាយតិ** "ស្រីសម្រាលនូវកូន" ។ **ឥត្តី បុត្តំ ឥជាតា** "ស្រីសម្រាលនូវកូនហើយ" ។ **ឧបឥជញ្ញា ឥត្តី** "ស្រីអ្នកសម្រាលកូន" ។ ការិត. **ជាបេតិ ជាបយតិ** "ឲ្យកើត, បង្កើត, ឲ្យប្រាកដ" ។ **ជាបិកា** "ឲ្យកើត, បង្កើត" បាលីថា **អត្ថជាបិកា បញ្ញា** "ប្រាជ្ញាញ៉ាំងប្រយោជន៍ឲ្យកើត" ។ សព្ទជាវេរចន:នៃ **ជាតិ**គឺ **ជនំ ជាតិ សញ្ជាតិ និព្វត្តិ អភិនិព្វត្តិ ខន្ធានំ ចាតុភាវោ** -ស. ។ **ជន** បុ. "បុគ្គល, មនុស្ស (ទាំងប្រុសទាំងស្រី)" ។ **ពីជ** នបុ. "ពូជ, គ្រាប់, ហេតុ, ការណ៍, អង្គជាតិនៃបុរសស្ត្រី" (រ+ជន-ស្ងចិ) ។

ជបា	ឥ.	ជ្ជា, កុឡាប (ដូច **ជីវសុមន**) ។
ជប្ជិត	កិ.គុ.	ពោល (ដូច **ឧទីរិត**) ។
ជតិ	ធ.	**គត្តវិនាមនេ ជតតិ ជម្ពតិ ឥជម្ពតិ** "មិតពត់កាយ,..." ភ្ជ. រុ. ។
ជម្ពវ	នបុ.	ផ្លែព្រីង (ដូច **ជម្ពូ**) ។
ជម្ពាលី	ឥ.	អណ្ដូងជ្រាំ, រណ្ដៅជ្រាំជិតទ្វារស្រុក (ដូច **ឱលិកល្ល**)។
ជម្ពាល	បុ.	ភក់ (ដូច **កលល**) ។
ជម្ពុ	ឥ.	ផ្លែព្រីង (ដូច **ជម្ពវ**) ។
ជម្ពុក	អ.ន.	អាជីវកឈ្មោះជម្ពុក: ។ -**ទាន** បុ. វាទ:ថាអាជីវកឈ្មោះជម្ពុក:, កិ. ពោលថាអាជីវកឈ្មោះជម្ពុក:។ -**អាជីវកវត្ថុ** នបុ. រឿងនៃអាជីវក ឈ្មោះជម្ពុក:។ បុ. សត្វចចក, កញ្ជ្រោង) (ដូច **សិគាល**) ។
ជម្ពូ	ឥ.	ផ្លែព្រីង (ដូច **ជម្ពវ**) ។
ជម្ពូទីប	បុ.	[ជម្ពូ+ទីប] ជម្ពូទ្វីប, ជនអ្នកជម្ពូទ្វីប, ភោះឬទ្វីបដែលគេកំណត់ហើយ ដោយដើមព្រីង, រ. **ជម្ពុយា លក្ខិតោ ទីបោ>ជម្ពូទីបោ**។ -**ឥល** នបុ. ផ្ទៃនៃជម្ពូទ្វីប។ -**ទាសី** បុ. អ្នកនៅក្នុងជម្ពូទ្វីប, អ្នកមានកិ.នៅក្នុង ជម្ពូទ្វីបជាប្រក្រតី។
ជម្ពូនទ	បុ.នបុ.	[ជម្ពូ + នទ] មាសជម្ពូនទ (មានព្រីងធំ១ដើមជាទេវព្រឹក្ស «ឈើជា លំនៅនៃទេវតា» បិតនៅក្បែរស្ទឹង, ស្ទឹងនោះគេហៅថា **ជម្ពូនទី**, ផ្លែ ព្រីងធំ១ប៉ុន១ឆ្នាំងជ្រុះធ្លាក់ចុះទៅក្នុងស្ទឹងនោះក៏ក្លាយកើតជាមាស, មាសនោះឯងគេហៅថា **ហាសជម្ពូនទ**)។ **អភि**.សុ. ។ មាសជម្ពូន ទជាឈ្មោះមាសម្យ៉ាងដែលល្អពិសេស, មាសភ្លើង។
ជម្ពូនទនិក្ខ	នបុ.	[ជម្ពូនទ + និក្ខ] និក្ខ:នៃមាសជម្ពូនទ, ឆ្ពោរនៃមាសជម្ពូនទ (**និក្ខ** ប្រែ

ថា «មាស» ក៏បាន) ។

ជម្ពូបរិព្វាជិកា អ.ន. ឈ្មោះជម្ពូបរិព្វាជិកា ។

ជម្ពូសាខា ឥ. [ជម្ពូ + សាខា] មែកនៃព្រីង។

ជម្ពីរ បុ. ដើមក្រូចឆ្មារ (ដូច**ទន្តសដ្ឋ**), បាឡីថា **ជម្ពោ ជម្ពុណো** ដូច្នេះក៏មាន ។

ជម្ពី ធា. **ឌាសនេ ជម្ពេតិ ជម្ពយតិ** "បំផ្លាញ, កម្ចាត់បង់" ចុ. ។

ជម្ម គុ. [ជម+ម] អ្នកលាមក, អ្នកថោកទាប (ដូច **ឆិហីនក**), អ្នកជ្រុលជ្រួស, អ្នកធ្វើអំពើដោយឥតពិចារណា (ដូច**អនិសម្មការី**), អាក្រក់, ក១ក់, (រ. **គុណទោសេ អនិសម្ម អនុបបរិក្ខិត្វា យោ ករោតិ សោ> ជម្មោ** អ្នកណាមិនពិចារណានូវគុណនិងទោសហើយធ្វើអ្នកនោះជាមនុស្សលាមក) ។

ជម្មី គុ. [ជម្ម + ល្ម] លាមក, អាក្រក់, ក១ក់។

ជម្ម ធា. **អទនេ ជមតិ** "ស៊ី, បរិភោគ" ភ្ជ. ។

ជយ បុ. [ជិ + ណឬអ] កិ.ឈ្នះ, ជម្នះ, រ. **ជយនំ>ជយោ** ។ -**ករុសុមវណ្ណ** គុ. មានពណ៌ដូចជាពណ៌នៃផ្កាជយព្រឹក្ស (ផ្កាច្បារ) ។ -**ឋានជយ**បុ. កិ. ឈ្នះនិងកិ.ចាញ់។ -**ឋាន** នបុ. ទឹកគឺបុគ្គលគប្បីផឹកក្នុងកាលជាទីឈ្នះនូវសត្រូវ, ទឹកគឺបុគ្គលគប្បីផឹកក្នុងកាលមានជ័យ, ទឹកជយបាន។ -**សុមនបុប្ផវណ្ណ** គុ. មានពណ៌ក្រហមព្រឿងៗដូចជាពណ៌នៃផ្កាច្បារនិងពណ៌នៃលក្ត។

ជយន នបុ. សេចក្តីឈ្នះ, ការឈ្នះ, ជម្នះ (ដូច **ជិតិ**) ។

ជយឋាន នបុ. ការផឹកសុរាជ័យគឺការផឹករបស់ជនដែលមានជ័យជម្នះក្នុងសង្គ្រាម។

ជយម្ប្ដតី ឥ. ប្រពន្ធនិងប្ដី (ដូច **ឥនម្ប្ដតិ**) ។

ជយសុមន នបុ. ដើមច្បា (ដូច **ពន្ធូក**) ។

ជយ បុ. ការជ្ងាញ់ (ដូច **ឥជ្ជយ**), សេចក្តីឈ្នះ, ការឈ្នះ, ជម្នះ (ដូច **ជយន**) ។

ជយ៎ំ គុ. [ជយន្ត + សិ-រ.] កាលឈ្នះ។

ជរ គុ. [ជរ+អ] ចាស់, គ្រាំគ្រា។ -**សក្ខ្ភាវ** បុ. ភាវៈនៃខ្លួនជាព្រះឥន្ទ្រចាស់។ -**សក្ខ** បុ. ព្រះឥន្ទ្រចាស់។ -**សិតាល** បុ. ចចកចាស់, ក១ញ្ជ្ងាងចាស់។

ជរគ្ភវ បុ. គោចាស់ (ដូច **ឥុទ្ធ**) ។

ជរតា ឥ. សេចក្តីគ្រាំគ្រា (ដូច **ជរ**) ។

ជរ ឥ. [ជរ + អ + អា-ឥ.] (ធម្មជាតិ) ចាស់, គ្រាំគ្រា, ជរា, សេចក្តីគ្រាំគ្រា(ដូច **ជរតា**) រ. **ជរតីតិ>ជរ**។ -**ជជ្ជរិត** គុ. គឺជរាឲ្យគ្រាំគ្រាហើយ, ដែលគ្រាំគ្រាហើយព្រោះជរា។ -**ជិណ្ណកាល** បុ. កាលនៃរូបនោះចាស់ហើយព្រោះជរា, កាលនៃរូបនោះគឺជរាឲ្យគ្រាំគ្រាហើយ។ -**ជិណ្ណ-ម-ហាលកព្រាហ្មណ** បុ. ព្រាហ្មណ៍អ្នកកាន់យកនូវភាវៈនៃខ្លួនជាធំគឺជរាឲ្យគ្រាំគ្រាហើយ, ព្រាហ្មណ៍ចាស់ដែលគ្រាំគ្រាហើយព្រោះជរា។ -**ជិណ្ណ-ម-ហាលកិត្ថីវណ្ណ** បុ. ភេទនៃស្រីអ្នកកាន់យកនូវភាវៈនៃខ្លួនជា

ធំគឺជរាឲ្យគ្រាំគ្រាហើយ, ភេទដូចជាភេទនៃស្រីចាស់ដែលគ្រាំគ្រាហើយព្រោះជរា។ -**ជិណ្ណ** គុ. ដែលចាស់ហើយព្រោះជរា, គឺជរាឲ្យគ្រាំគ្រាហើយ។ -**ព្យាធិមរណមិស្សតា** ឥ. ភាវ:នៃជាតិនោះជាធម្ម-ជាតិច្រឡំដោយជរានិងព្យាធិនិងមរណ:, ភាវ:នៃជាតិនោះជារបស់មានជរានិងព្យាធិនិងមរណ:ដ៏ច្រឡំគ្នា។ -**ឥត្ថត្ថណ្ណនា** ឥ. កថាជាគ្រឿងពណ៌នានូវសេចក្តីនៃជរាវគ្គ។ - **ឆាតវេគញ្ហាហត** គុ. គឺកម្លាំងនៃខ្យល់ដែលកើតអំពីជរាកម្ចាត់បង់ហើយ, គឺសន្ទុះនៃខ្យល់ដែលកើតអំពីជរាបៀតបៀនចំពោះហើយ។

ជរាសិថិលចម្ម នបុ. ស្បែកធ្លាក់ព្រោះជរាជាហេតុ, សព្ទនេះជាអត្ថនៃវលីសព្ទ។

ជរ បុ. រោគស្គម។

ជរ ធ. ១- **រោគេ ជរតិ** "ឈឺចាប់,...″ ភ្ជ. **ជរោ សជ្ជរោ** បុ. "ការឈឺចាប់, រោគ" អា. **ជរេន ជីឡិតា មនុស្សា** "មនុស្សទ. ត្រូវរោគបៀតបៀនហើយ" -ស. ។ **បជ្ជរោ** បុ. "រោគរ៉ាំរ៉ៃ, ជំងឺត្រាំត្រែង, ការឈឺចាប់ក្រៃលែង" (ប+ជរ+រោគ) ។

២- **ឆយហានិយំ ជរេតិ ជរយតិ ជរ** "ចាស់, ទ្រុឌទ្រោម, ស្រកស្រុត, សាបសូន្យវ័យ" ចុ. ផ្លាស់ **ជរ** ជា **ជិរ** ឬ **ជីរ** ខ្លះ ជា **ជិយ្ય** ខ្លះ ទៅជា **ជិរតិ** ឬ **ជីរតិ ជិយ្យតិ** -ស. និង **ឥច្ឆាយន**. ។

ជល នបុ. [ជល + អ] (ធម្មជាត) ហូរទៅ (ទឹក), វិ. **ជលតិ សន្ទតីតិ>ជលំ** ។ គុ. រុងរឿង។

ជលចរ បុ. ត្រី (ដូច **មីន**) ។

ជលឆាយក បុ. កុណ្ឌីទឹក, កំសៀវទឹក (ដូច **ឥន្ទ្រ**) ។

ជលនិធិ បុ. សមុទ្រ (ដូច **សាគ**) ។

ជលន្ត គុ. [ជល + អ + អន្ត] កាលរុងរឿង, កំពុងរុងរឿង។

ជលបថ បុ. [ជល + បថ] ផ្លូវនៃទឹក។ -**ថលបថាធិ** គុ. (ទី) មានផ្លូវនៃទឹកនិងផ្លូវនៃគោកជាដើម។

ជលសុត្តិ ឥ. ខ្យងឬខ្ជ (ដូច **សម្ពុ**) ។

ជលាឆារ បុ. ទន្លេសាប, ស្រះ (ដូច **ជលាសយ**) ។

ជលាពុ បុ. សុកកូន, សុកដែលស្រោបទារកនៅក្នុងផ្ទៃ (ដូច **ឥញ្ហាសយ**) ។

ជលាពុជ បុ. សត្វដែលកើតអំពីសុក។

ជលាសយ បុ. ទន្លេសាប, ស្រះ (ដូច **ជលាឆារ**) ។

ជលិត គុ. [ជល + ឥ-អា. + ត] ឲ្យរុងរឿងហើយ, ដែលរុងរឿងហើយ, គឺ....ឲ្យរុងរឿងហើយ។

ជលិតិទ្ធិ គុ. [ជលិត + ឥទ្ធិ] អ្នកមានឫទ្ធិដ៏រុងរឿងហើយ, វិ. **ជលិតា ឥទ្ធិ យស្ស សោ >ជលិតិទ្ធិ**។

ជលុកា ឥ. ឈ្លើង (ដូច **រត្តបា**) ។

ជល្លិ ឥ. ស្បែក, សម្បក, សម្បកឈើ, ក្រមរឈើ, កម្ទេច, រំកាច់។ ប្រើជា «**ឆល្លិ**» ក៏មាន។

ជល នបុં. ទឹក (ដូច **ឱារ**) ។

ជលិ ធា. **អបឱារណេ ជាលេតិ ជាលយតិ** "ហ៊ុមព័ទ្ធ, បិទ, ឃាំង" ចុ. ។ **ជាលំ** នបុં. ជាល, សំណាញ់ដូចពាក្យថា **មច្ឆជាលំ** "សំណាញ់ដាក់ត្រី, បង្ហួច, ហ្វូង, ពួក ឥ. អណ្តាត" ដូចពាក្យថា **អគ្គិជ្ជាលា** "អណ្តាតនៃភ្លើង" ។

ជវ បុំ. [ជុ + ណ] ការស្ទុះទៅ, ការលឿនទៅ, សន្ទុះ, រហ័ស, ប្រញាប់ប្រញាល់ (ដូច **រយ**), វិ. **ជវនំ>ជវោ, ជវន្តិ ឯត្ថាតិ ឱា>ជវោ** ។

ជវច្ឆិន្ន គុ. [ជវ + ឆិន្ន] អ្នកមានសន្ទុះដាច់ហើយ, ដែលដាច់ហើយព្រោះការស្ទុះទៅឬព្រោះការលឿនទៅ។

ជវន នបុં. [ជុ + យុ] ជវន, ការស្ទុះទៅ, ការលឿនទៅ, វិ. **ជវិយតេ>ជវនំ** ។ **-ក្ខណ** បុំ. ខណៈនៃជវនចិត្ត, ខណៈនៃចិត្តដែលស្ទុះទៅ។ **-មន** បុំ., នបុំ. ចិត្តដែលលឿនទៅ, ជវនចិត្ត។ **-ឱិថី** ឥ. វិថីនៃជវនចិត្ត, វិថីនៃចិត្តដែលស្ទុះទៅ។បុំ. សេះលឿន (ដូច **ជវាធិក**), អ្នកដើរឆាប់, អ្នកដើរលឿន (ដូច **ឱវតី**) ។

ជវនិកា ឥ. សំពត់រនាំង (ដូច **តិរោករណី**) ។

ជវមាន គុ. [ជុ + អ + មាន] កាលលឿនទៅ, កាលស្ទុះទៅ។

ជវាធិក បុំ. សេះលឿន (ដូច **ជវន**) ។

ជសិ ធា. ១-**ហឹសាយំ ជសតិ** "បៀតបៀន" ភូ. ។
២-**ហឹសាតាឡនេសុ ជាសេតិ ជាសយតិ** "បៀតបៀន, វាយ, គោះ, ប្រហារ" ចុ.។

ជហន្តិ កិ. [ហា-ហា + អ + អន្តិ-វ.] លះ, លះបង់។ រូបសិទ្ធិនៃស័ព្ទពួកនេះចូរមើលក្នុងកច្ចាយនូបត្ថម្ភក: ភាគទី២។

ជហិតុំ អ. [ហា-ហា + តុំ] ដើម្បីលះបង់។

ជហិត្វា អ. [ហា-ហា + ត្វា] លះបង់ហើយ។

ជហិស្សាមិ កិ. [ហា-ហា + អ + ស្សាមិ-ភ.] នឹងលះបង់។

ជហេ កិ. [ហា-ហា + អ + ឯយ្យ-ស.] គប្បីលះបង់។

ជឡ គុ. [ជល + អ, ល>ឡ] ល្ងីល្ងើ, ពន្លីពន្លើ, លលា, ឬលេលា, រឡ្ចិករឡ្ចក់, អ្នកលង់ខ្លៅ (ដូច **មូឡ្ហ**) ។

ជឡត្ត នបុં. សេចក្តីលង់ខ្លៅ (ដូច **មូឡ្ហត្ត**), សព្ទនេះជាអត្ថនៃថម្ភសព្ទ។

ជាគរ បុំ. [ជាគរ + អ] ការភ្ញាក់, សេចក្តីភ្ញាក់រឭក, វិ. **ជាគរណំ>ជាគរោ។**

ជាគរតោ គុ. [ជាគរន្ត + ស-វិ. ផ្លាស់ន្តនិងស-វិ.>តោ] កាលភ្ញាក់, កាលភ្ញាក់រឭក។

ជាគរធម្ម បុំ. [ជាគរ + ធម្ម] ធម៌ជាគ្រឿងភ្ញាក់រឭក។

ជាគរន្ត គុ. [ជាគរ + អន្ត] កាលភ្ញាក់, កាលភ្ញាក់រឭក។

ជាគរិយ នបុ. [ជាគរ + ឥយ] ភាវ:នៃសេចក្ដីភ្ជាក់រឭក, ភាវ:នៃបុគ្គលអ្នកភ្ជាក់រឭក ឬសេចក្ដីភ្ជាក់រឭក, វិ. **ជាគរស្ស ភាវោ>ជាគរិយំ, ជាគរេ ៦ឥ ភាវ> ជាគរិយំ**។

ជាគរិយា ឥ. សេចក្ដីរលឹក, សេចក្ដីភ្ជាក់, មិនលក់ (ដូច **ជាគរ**) ។

ជាគរ បុ. សេចក្ដីរលឹក, សេចក្ដីភ្ជាក់, មិនលក់ (ដូច **ជាគរិយា**) ។

ជាគរ ធា. ឬ **គ-គរ =និន្ទក្ខយេ ជាគរតិ ជាគរោតិ បដិជាគរោតិ ជាគរោ-រំ ជាគរណំ** "ភ្ជាក់ (អស់លក់)" ភ្ជ. ត. ។

ជាត គុ. [ជន>ជា + ត] កើតហើយ(ដូច **ភូត**), បុ. ហ្វូង, ប្រជុំ, ពួក (ដូចចយ, ដូច **ឃ្ងត**) ។ -**ការ** បុ. ការនៃ....កើតហើយ។ -**កុមារ** បុ. កុមារដែលកើតហើយ។ -**ឈ្ម**បុ. ឈ្មមណ្ណើដែលកើតហើយ។ -**ឆ្ឆ** គុ. អ្នកមានឆន្ទ:កើតហើយ, អ្នកមានសេចក្ដីពេញចិត្តកើតហើយ។ -**ដ្ឋានវស** បុ. អំណាចនៃទីនៃ....កើតហើយ។ -**ដ្ឋ** បុ. សេចក្ដីថាកើតហើយ , សេចក្ដីគឺភាវ:នៃ....កើតហើយ។ -**ត្ត** បុ. ភាវ:នៃ....នោះជា....កើតហើយ។ -**មង្គលទិវស** បុ., នបុ. ថ្ងៃជាទីធ្វើនូវមង្គលដល់ទារកដែលកើតហើយ , ថ្ងៃនៃមង្គលគឺ....គឃ្ប៉ីធ្វើដល់ទារកដែលកើតហើយ។ -**រូប** គុ. មានរូបកើតហើយ, នបុ. មាស។ -**វេទ** បុ. ភ្លើង។ -**សត្ត** បុ. សត្វអ្នកកើតហើយ។ -**សំវឌ្ឍ** គុ. អ្នកកើតហើយចម្រើនព្រមហើយ, អ្នកមានសេចក្ដីចម្រើនព្រមកើតហើយ។ -**សារ** គុ. មានសារ:កើតហើយ, មានខ្លឹមសារកើតហើយ។ -**សាសន** នបុ. សាសន: (ពាក្យបណ្ដាំ, សំបុត្រ) កើតហើយ , ពាក្យជាគ្រឿងប្រៀនប្រដៅកើតហើយ។ -**ស្សរ** បុ. ស្រះកើតហើយ, ជាតស្រះ។

ជាតរូប នបុ. មាស (ដូច **កនក**) ។

ជាតវេទ បុ. ភ្លើង (ដូច **សិខី**) ។

ជាតាបច្ចា ឥ. ស្រីមានកូនសម្រាលហើយ, ស្រីសម្រាលកូន (ដូច **ទ្វិជាតា**) ។

ជាតិ ឥ. [ជន>ជា + តិ] កិ.កើត, ការកើត, កំណើត, វិ. **ជនតំ>ជាតិ** ។ -**អាទិ** នបុ. (ទុក្ខ) មានជាតិជាដើម។ -**អាទិធម្ម** គុ. មានទុក្ខមានជាតិជាដើមជាធម្មតា, បុ. ធម៌មានជាតិជាដើម។ -**អាទិភយ** នបុ. ភ័យមានជាតិជាដើម, ភ័យកើតអំពីធម៌មានជាតិជាដើម។ -**កុលប្បទេសភោគ-យសវយសម្បត្តិ** ឥ. កិ.ដល់ព្រមដោយជាតិនិងត្រកូលនិងប្រទេសនិងភោគ:និងយសនិងវ័យ, ជាតិសម្បត្តិនិងកុលសម្បត្តិនិង.... ។ -**ក្ខ-យសទ្ធាត** គុ. ពោលគឺកិ.អស់ទៅនៃជាតិ។ -**ក្ខយ** បុ. ការអស់ទៅនៃជាតិ។ -**គោត្តកុលភោគ** បុ. ជាតិនិងគោត្រនិងត្រកូលនិងភោគ:។ -**គោត្តមត្ត** គុ. ហេតុគ្រាន់តែជាតិនិងគោត្រ, គុណត្រឹមតែជាតិនិងគោត្រ។ -**ជរាព្យាធិមរណ**នបុ. ជាតិនិងជរានិងព្យាធិនិងមរណ:។ -**ជរូបគ** គុ. អ្នកចូលទៅដល់នូវជាតិនិងជរា, វិ. **ជាតិជរំ ឧបគច្ឆន្តីតি>**

ជាតិជរូបគា (**ឧបគ**<**ឧប** + **គម** + **ក្ងិ**) ។ -**ទុក្ខាធិ** គុ. (ទុក្ខ) មានជាតិទុក្ខជាដើម។ -**សម្ភវ** បុ. កិ.កើតព្រមអំពីជាតិ, សេចក្ដីចម្រើនព្រមនៃជាតិ, គុ. មានជាតិជាដែនកើតព្រម , មានជាតិជាដែនចម្រើនព្រម។ - **សម្ភេទ** បុ. កិ.បែកព្រមនៃជាតិ, កិ. ច្រឡំនៃជាតិ។ -**សុមនា** ឥ. ម្លិះរួត, ផ្កាម្លិះរួត។ -**ស្សរញ្ញាណ** នបុ. ញ្ញាណជាគ្រឿងរឭកបាននូវជាតិ។ -**ស្សរ** បុ. អ្នករឭកបាននូវជាតិ, វិ. **ជាតឺ សរតីតិ**>**ជាតិស្សរោ** ។

ជាតិ ឥ. សេចក្ដីកើត, កំណើត (ដូច **ឧព្ភវ**), ពពួក (ដូច **និកាយ**), បដិសន្ធិ, ទូទៅ, មិនប្លែកគ្នា (ដូច **សាមញ្ញ**), ប្រសូតិ, ត្រកូល, ភព, ប្លែកគ្នា (ដូច **វិសេស**), ម្លិះ (ដូច **សុមនា**), សំខ្ចតលក្ខណៈ។

ជាតិកោស នបុ. ផ្លែចន្ទន៍ (ដូច **ជាតិផល**) ។

ជាតិផល នបុ. ផ្លែចន្ទន៍ (ដូច **ជាតិកោស**) ។

ជាតិយាវន នបុ. [ជាតិយា + វន] វិហារឈ្មោះជាតិយាវន, ព្រៃនៃឈើចន្ទន៍, ព្រៃដ៏ដេរដាសដោយដើមចន្ទន៍, ព្រៃនៃដើមម្លិះ, ព្រៃដែលកើតឯង។

ជាតិសុមនា ឥ. ម្លិះ (ដូច **មាលតិ**) ។

ជាតី ឥ. ម្លិះ (ដូច **សុមនា**) ។

ជាតុ និ. ឯកំសត្ថវាចកៈ និបាតប្រាប់អត្ថគឺចំណែកមួយប្រៃថា ដោយពិត, **អញ្ញេទត្ថុ**, **ឥត្ថ**, **សសក្ខំ**, **អទ្ធា**, **ឥមំ**, **ឥវ**, **ហវេ** ក៏ជាឯកំសត្ថវាចកៈដែរ, មួយទៀត **ជាតុ** ជាអនិយតត្ថវាចកៈនិបាតប្រាប់អត្ថគឺមិនកំណត់ប្រៃថាក្នុងកាលខ្លះ (ដូច **ឥធ**) ។

ជាតុស្សាហ គុ. [ជាត + ឧស្សាហ] អ្នកមានសេចក្ដីឧស្សាហ៍ (សេចក្ដីប្រឹងប្រែង, សេចក្ដីខ្ជីឃ្មាត) កើតហើយ, វិ. **ជាតោ ឧស្សាហោ យស្ស សោ**> **ជាតុស្សាហោ**។

ជានតោ គុ. [ជានន្ត + ស-វិ., ផ្ការ៉ាស់ន្ត + ស-វិ.>តោ] កាលដឹង។

ជានន នបុ. [ញ>ជ>ជ + យុ , យុ>អានន] កិ.ដឹង, ការចេះ, ការយល់, វិ. **ញ្ញាយ តេតិ**>**ជានន**ំ។ - **និយាម** បុ. ទំនង(ដំណើរ, ការកំណត់) នៃកិ.ដឹង។ -**ភាវ** បុ. ភាវៈនៃកិ.ដឹង, ភាវៈគឺកិ.ចេះ។ - **សមត្ថ** គុ. អ្នកអាចក្នុងកិ.ដឹង, អ្នកអាចដើម្បីកិ.ដឹង។ -**សមយ** បុ. សម័យគឺកិ.ដឹង, លទ្ធិជាគ្រឿងដឹង។ - **សិប្ប** នបុ. សិល្ប:ជាគ្រឿងដឹង, សិល្ប:ជាទីចេះ។

ជានន្ត គុ. [ញ + នា + អន្ត] កាលដឹង ។

ជានន្ទិ កិ. [ញ + នា + អន្ទិ-វ.] ដឹង, ចេះ, យល់។

ជានបទ គុ. [ជនបទ + ណ] (ជន) អ្នកនៅក្នុងជនបទឬអ្នកកើតក្នុងជនបទ (អ្នកជនបទ), វិ. **ជនបទេ ភវសតីតិ**>**ជានបទោ**, **ជនបទេ ជាតោ ឥ**> **ជានបទោ**។

ជានមាន គុ. [ញ + នា + មាន] កាលដឹង។

ជានាតិ កិ. [ញ + នា + តិ-វ.] ដឹង, ចេះ, យល់, ស្គាល់។

ជានាតុ កិ. [ញា + នា + តុ-ប.] ចូរដឹង។
ជានាបេតព្ព គុ. [ញា + នា + ណាបេ + តព្ព] គឺ...គប្បីញ៉ាំង...ឲ្យដឹង, គឺ...គប្បីឲ្យដឹង។
ជានាបេតុំ អ. [ញា + នា + ណាបេ + តុំ] ដើម្បីញ៉ាំង...ឲ្យដឹង។
ជានាបេត្វា អ. [ញា + នា + ណាបេ + ត្វា] ឲ្យដឹងហើយ។
ជានាបេយ្យុំ កិ. [ញា + នា + ណាបេ + ឯយ្យុំ-ស.] គប្បីឲ្យដឹង។
ជានាបេសិ កិ. [ញា + នា + ណាបេ + ល្ស-អជ្ជ, ចុះ-ស-អា.] ឲ្យដឹងហើយ។
ជានាម កិ. [ញា + នា + ម-រ.] ដឹង, ចេះ, យល់, ស្គាល់។
ជានាសិ កិ. [ញា + នា + សិ-រ.] ដឹង, ចេះ, យល់, ស្គាល់។
ជានិ ឥ. [ហា + ណ្ស] សេចក្តីសាបសូន្យ, សេចក្តីវិនាស(ដូច **ជីរណ**) ។
ជានិតព្ព គុ. [ញា + នា, នា>និ+តព្ព] គឺ....គប្បីដឹង។
ជានិត្វា អ. [ញា + នា, នា>និ + ត្វា] ដឹងហើយ។
ជានិបតិ បុ. ប្រពន្ធនិងប្តី (ដូច **ជាយាបតិ**) ។
ជានិស្សតិ កិ. [ញា + នា, នា>និ + ស្សតិ-ភ.] នឹងដឹង។
ជានុ នបុ. [ជន+ណុ] (អវយវ:) ជាគ្រឿងញ៉ាំងដំណើរឲ្យកើត (ជង្គង់ដូច **ឧរុបព្ព**), វិ. **ជាយតិ គមនមេតេនាតិ>ជានុ**។ -**ប្បមាណជនប្បមាណ** គុ. មានជង្គង់ជាប្រមាណនិងមានដោះជាប្រមាណ (ត្រឹមជង្គង់និងត្រឹមដោះ), ។ - **មណ្ឌល** នបុ. មណ្ឌលនៃជង្គង់។
ជានេមុ កិ. [ញា + នា + ម-រ.] ដឹង, នឹងដឹង។ ចុះ **ឯយ្យាម-ស.>ឯមុ**ក៏បាន = គប្បីដឹង។
ជានេយ្យ កិ. [ញា + នា + ឯយ្យ-ស.] គប្បីដឹង។
ជានេយ្យុំ កិ. [ញា + នា + ឯយ្យុំ-ស.] គប្បីដឹង។
ជានំ គុ. [ជានន្ត + សិ-វិ. ផ្លាស់ន្ត + សិ-វិ.>អំ] កាលដឹង។ញា + យុ = កិ.ដឹង, វិ. **ញ្ញាយតេតិ>ជានំ**។
ជាមតរ បុ. [ជាមាតុ + អ-វិ, ផ្លាស់ឧនៃតុ>អរ] កូនប្រសារប្រុស, ឲ្យជាកូនប្រសារប្រុស។
ជាមាតា ឥ. កូនប្រសាប្រុស (**ធីតុបតិ**) ។
ជាយតិ កិ. [ជន>ជា + យ + តិ-រ.] កើត។
ជាយតេ កិ. [ជន>ជា + យ + តេ-រ.] កើត។
ជាយបតិក បុ. [ជាយា+បតិ+ក] ប្រពន្ធនិងប្តី, វិ. **ជាយា ច បតិ ច>ជាយបតិកា**។
ជាយមាន គុ. [ជន>ជា + យ + អា-ឥ.] (ស្ត្រី) ជាដែនកើតនៃកូន (ប្រពន្ធ), វិ. **ជាយតិ បុត្តោ ឥមាយាតិ>ជាយា**។
ជាយា ឥ. ប្រពន្ធ (ដូចទារ) ។
ជាយាបតិ បុ. ប្រពន្ធនិងប្តី (ដូច **ជយម្បតិ**) ។
ជាយិស្សតិ កិ. [ជន>ជា + យ + ឥ-អា.+ ស្សតិ-ភ.] នឹងកើត។
ជារ បុ. ប្រុសជាសាហាយ (ដូច **ឧបបតិ**) ។

ជាល នបុ. [ជល + ណ] បណ្ដាញ, បង្ការ, បន្ទឹង, លប, សំណាញ់, ជាល,មង (ដូច **មច្ឆាទិពន្ធន**, **អានាយ**), បង្ហូច (ដូច **ភវក្ខ**, **ទ្វារជាន**), ហ្វូង, ប្រជុំ, ពួក (ដូច **សមូហ**, **ករណ្ឌ**) ។ -**ករណ្ឌក** នបុ. ពោងសម្រាប់ចងនូវសំណាញ់, -នូវបណ្ដាញ (ប្រូល) ។ -**ការិក** គុ. ធ្វើនូវបណ្ដាញ, វិ. **ជាលំ ករោតីតិ**> **ជាលការិកា** ។ -**ឫវសទិស** គុ. ប្រាកដស្មើដោយនំជាល (ប្រាកដស្មើដោយនំមានសណ្ឋានដូចជាបណ្ដាញ) ។ -**មុត្ត** គុ. រួចហើយចាកបណ្ដាញ។ - **អាទិ** គុ. (វត្ថុ) មានបណ្ដាញជាដើម។

ជាលក នបុ. ផ្ការឈើនិងផ្លែឈើដែលនៅជាប្រក្រតី (ដូច **ខារក**) ។

ជាលា ឥ. អណ្ដាតភ្លើង (ដូច **សិខា**) ។

ជាលិកា ឥ. ក្រោះ (ដូច **ភវច**) ។

ជាលិក បុ. ព្រានបង្ការ (ដូច **ទ្វាគុរិក**), ព្រានសំណាញ់ (ដូច **ភេវដ្ដ**) ។

ជាលិនី គុ. [ជាល+ណ្ឍ+ឥនី] មានបណ្ដាញ,វិ. **ជាលំ យស្ស អត្ថីតិ**>**ជាលីនី** ។ ន.ឥ. ឥណ្ណា (ដូច **ទ្ធិសត្ថិកា**) ។

ជាលិសទិស គុ. [ជាលី + សទិស] ប្រាកដស្មើដោយកុមារឈ្មោះជាលី។

ជាលូបម គុ. [ជាល + ឧបមា] មានឧបមាដោយបណ្ដាញ, មានសេចក្ដីប្រៀបដោយបណ្ដាញ។

ជាលេត្វា អ. [ជល + ណ + ត្វា] ឲ្យរុងរឿងហើយ, ឲ្យភ្លឺហើយ, អុជហើយ។

ជាលេន្ត គុ. [ជល + ណ + អន្ត] កាលរុងរឿង, កាលឲ្យរុងរឿង។

ជាលេយ្យ កិ. [ជល + ណ + ឯយ្យ-ស.] គប្បីរុងរឿង, គប្បីឲ្យរុងរឿង។

ជាលេសិ កិ. [ជល + ណ + ណ្ឍ-អជ្ជ. , ចុះ-ស-អា.] ឲ្យរុងរឿងហើយ, អុជហើយ។

ជាលេស្សាមិ កិ. [ជល + ណ + ស្សាមិ-ភ.] នឹងញ៉ាំង...ឲ្យរុងរឿង, -ឲ្យភ្លឺ។

ជាវី ឥ. ស្រីមានសាហាយ (ដូច **អតិជារិនី**) ។

ជិ ធា. ១-**ជយេ ជិនាតិ ជិជិនាតិ** "ឈ្នះ, មានជោគជ័យ" កី. ។

២-**ជានិយំ ជិនាតិ ជានិ** "សាបសូន្យ, វិនាស" កី. ។ **ជិន** បុ. "អ្នកសាបសូន្យ, អ្នកបំផ្លាញ" អា. **ជិនោ ធនញ្ច ទ្ទាសេ ច** "ជាអ្នកបំផ្លាញទ្រព្យសម្បត្តិនិងទាស:ទ." ។ **ជិនធនា** "អ្នក មានទ្រព្យសម្បត្តិសាបសូន្យអស់" (សុធាភោជន-ជាតក) ។

៣-**ជយាតិភវនេសុ ជេតិ ជយតិ បរាជយតិ ជិតំ ជិជិតំ ជយោ បរាជយោ ជិនោ ហរជិ លោកជិ ជេតោ ជិតវា**។ល។ "ឈ្នះ, មានជោគជ័យ, គ្របសង្កត់, ជិះជាន់" ភ្ជ. ។ខ ចំណាំ:កាលណាមានបរានាំមុខប្រែថា "ចាញ់, បរាជ័យ" ។ **បរាជយតិ** "ចាញ់" ។ **ជិជិតីសតិ** "ប្រាថ្នាដើម្បីឈ្នះ, ចង់ឈ្នះ" (វិ+ជិ+ស+តិ) មេសូត្រសទ្ទនីតិថា **ជិស្ស ច** និមិត្ត **ស** បច្ច័យផ្លាស់ **ជិ** ធាតុជា **ជិតី**។

ជិគុច្ឆតិ កិ. [គុ-គុប + ឆ + តិ-វិ.] ខ្ពើម, រក្សា។

ជិគុច្ឆន្ត គុ. [គុ-គុប + ឆ + អន្ត] កាលខ្ពើម, កាលរក្សា។

ជិគុច្ឆមាន គុ. [គុ-គុប + ឆ + មាន] កាលខ្ពើម, កាលរក្សា។
ជិគុច្ឆា ឥ. សេចក្តីខ្ពើម, ការតិះដៀល (ដូច**ឆរហា**) ។
ជិយច្ឆា ឥ. [ឃ-ឃស + ឆ + អា-ឥ.] សេចក្តីប្រាថ្នាដើម្បីស៊ី, សេចក្តីចង់ស៊ី, (សេចក្តីឃ្លានដូច **ខុទា**), វិ. **ឃសិតុំ ឥច្ឆា>ជិយច្ឆា**។ -**ទុក្ខ** នបុં. ទុក្ខគឺសេចក្តីឃ្លាន, ទុក្ខដែលកើតអំពីសេចក្តីឃ្លាន។ -**រោគសទិស** គុ. ប្រាកដស្មើដោយរោគគឺសេចក្តីឃ្លាន។
ជិយច្ឆិត គុ. [ជិយច្ឆា + ឥ + ត] អ្នកប្រព្រឹត្តទៅដោយសេចក្តីឃ្លាន។ ឃ-ឃស + ឆ + ឥ-អា. + ត = ដែលឃ្លានហើយ។
ជិយជ្ជិត គុ. ឃ្លាន (ដូចខុទិត) ។
ជិយញ្ញ បុំ. ទីបំផុត, ខាងក្រោយ (ដូច **អន្ត, បច្ឆិម**) ។ គុ. ថោកទាប (ដូច **អធម**) ។
ជិញ្ជុក បុំ. ទំពាំងបាយជូរ (ដូច **ឥុញ្ជ**) ។
ជិណ្ណ គុ. [ជរ + ត, ត>ឥណ្ណ] ចាស់ហើយ , គ្រាំគ្រាហើយ, ទ្រុឌទ្រោមហើយ។ - **ការ** បុំ. កាលនៃ....ជាអ្នកចាស់ហើយ, កាលនៃ....គឺជវាឲ្យគ្រាំគ្រាហើយ។ -**ភោជ្ជ** បុំ. ក្រៀលចាស់, ក្រៀលចាស់ហើយ។ -**ចីវរក** គុ. (ភិក្ខុ) មានចីវរចាស់, អ្នកមានចីវរគ្រាំគ្រា។ -**ចីវរ** នបុំ. ចីវរចាស់, ចីវរចាស់គ្រាំគ្រា។ -**ព្យាធិមតសន្ធាត** គុ. ពោលគឺជនដែលចាស់ហើយនិងជនដែលឈឺចាប់និងជនដែលស្លាប់ហើយ, គឺបណ្ឌិតពោលថាជនអ្នកចាស់ហើយនិងជនអ្នកមានព្យាធិនិងជនអ្នកស្លាប់ហើយ។ -**ឃ្ឃដិ-សន្ធារណាធិ** គុ. (កិច្ច) មានកិ.ជួសជុលនូវទីដែលគ្រាំគ្រាហើយជាដើម។ -**ហត្ថី** បុំ. ដំរីចាស់, ដំរីគឺជវាឲ្យគ្រាំគ្រាហើយ។ -**ឧទ្យាន** នបុំ. ឧទ្យានចាស់, ឧទ្យានដែលគ្រាំគ្រាហើយ។
ជិណ្ណក បុំ. បុគ្គលចាស់ (ដូច **មហាលួក**) ។
ជិណ្ណវសន នបុំ. សំពត់ចាស់ (ដូច **បដច្ឆរ**) ។
ជិណ្ណ គុ. ចាស់ (ដូច **ឥុឌ្ឍ**) ។
ជិត នបុំ.,គុ. [ជិ + ត] កិ.ឈ្នះ, គឺ...ឈ្នះ, -ផ្ទាញ់ហើយ។
ជិតវា អ., គុ. [ជិ + តវន្តុ ឬជិត + វន្តុ] ឈ្នះហើយ, អ្នកមានកិ.ឈ្នះ, វិ. **ជិតមស្ស អត្ថីតិ >ជិតវា**។
ជិតិ ឥ. សេចក្តីឈ្នះ, ការឈ្នះ, ជម្នះ (ដូច **ជយ**) ។
ជិត្វាន អ. [ជិ + ត្វាន] ឈ្នះហើយ, ផ្ទាញ់ហើយ។
ជិន បុំ. [ជិ+ឥន] (ព្រះមានជោគ) ទ្រង់ឈ្នះ, (ព្រះជិនស្រី, ព្រះនាមព្រះពុទ្ធជាម្ចាស់), វិ. **ជិនាតីតិ>ជិនោ**។គុ. សូន្យហើយ, សាបសូន្យហើយ, អស់ហើយ។
ជិនន្ត គុ. [ជិ + នា + អន្ត] កាលឈ្នះ, កាលផ្ទាញ់។
ជិនាតិ កិ. [ជិ + នា + តិ-វ.] ឈ្នះ, ផ្ទាញ់។
ជិនិតព្ព គុ. [ជិ + នា, អានៃនា>ឥ + តព្ព] គឺ...គប្បីឈ្នះ, -គប្បីផ្ទាញ់។

ជិនិស្សតិ កិ. [ជិ + នា + ស្សតិ-ភ.] នឹងឈ្នះ, នឹងផ្ទាញ់។
ជិនីសុ កិ. [ជិ + នា + ឧ-អជ្ជ.] ឈ្នះហើយ, ផ្ទាញ់ហើយ។
ជិនេ កិ. [ជិ + នា + ឯយ្យ-ស.] គប្បីឈ្នះ, គប្បីផ្ទាញ់។
ជិម្ហ គុ. រៀច, កោង, រំពត់ (ដូច **ឥជ្ជិល**) ។
ជិមិ ធា. **អ១ឆេ ជេមតិ** "ស៊ី, បរិភោគ" ភ្ជ. ។
ជិយា ឥ. [ជរ>ជិយ + អ + អា-ឥ.] ខ្សែបន្ទោះ, ខ្សែតំពេច (ខ្សែធ្នូ) ។
ជិយា ឥ. ខ្សែបន្ទោះធ្នូ (ដូច **ឥណ**) ។
ជិយិ កិ. [ជិ + ណយ +ល្ហ-អជ្ជ.] សូន្យហើយ, អស់ហើយ។
ជិយ្យតិ កិ. [ជរ>ជិយ្យ + អ + តិ-រ.] ចាស់, គ្រាំគ្រា។
ជីរ ធា. **ព្ជូហ១ ជីរតិ ជីរណំ ជីរហ១ ជីរ** "ចម្រើនឡើង, ធំឡើង, ចាស់" ភ្ជ. ។ អា. **អប្ជស្ស្ជតាយ៎ ឃ្ជ១ សោ ១ណ្ឌ១ ១ជ ជីរតិ** "បុរសរៀនសូត្រតិចតួចនេះចម្រើនឡើងឬចាស់ឡើងដូចគោបម្រើ -ស. ។
ជិរន្តិ កិ. [ជរ>ជិរ + អ + អន្តិ-រ.] ចាស់, គ្រាំគ្រា, ទ្រុឌទ្រោម។
ជិរន្តុ កិ. [ជរ>ជិរ + អ + អន្តុ-ប.] ចូរចាស់, ចូរគ្រាំគ្រា, ចូរទ្រុឌទ្រោម។
ជិរមាន គុ. [ជរ>ជិរ + អ + មាន] កាលចាស់, កាលគ្រាំគ្រា, កាលទ្រុឌទ្រោម។
ជិរិ កិ. [ជីរ + អ + ល្ហ-អជ្ជ.] រេចហើយ, រេចរឹលហើយ, ជ្ជួតជ្ជាបហើយ, សាបសូន្យហើយ។
ជិ១ ធា. **ហ១ីសាយ៎ ជិ១ណាតិ** "ចៀតចៀន" សុ. ។
ជិ១ា ឥ. [ជីរ + ហាឬជីវិត + អា + ០ + អ] (ធម្មជាតិ) ជាគ្រឿងរស់នៅនៃសត្វឬ (ធម្មជាតិ) ហៅរកនូវជីវិត (អណ្ណាតដូច **រសនា**), រ. **ជីវន្តិ ឯតាយាតិ**> **ជិ១ា**, **ជីវិតំ អ១ាយតីតិ ១ា**>**ជិ១ា**។ -**អ១ត** គុ. ចុងនៃអណ្ណាត។ -**ឥ១ាយ** គុ. គឺ...គប្បីដឹងច្បាស់ដោយអណ្ណាត។
ជិ១ ធា. **សេ១ឆេ ជេសតិ** "ស្រោច, បាចសាច, ប្រោះព្រំ" ភ្ជ. ។
ជីមូត ឬ. មេឃ (ដូច **ឥជ្ជុ១**), ស្មៅពុកឆ្មា (ដូច **ទ១ឥតាស**) ។
ជីយតិ កិ. [ជរ>ជិយ + អ + តិ-រ.] ចាស់, គ្រាំគ្រា, ទ្រុឌទ្រោម។
ជីរណលក្ខ១ណ គុ. [ជីរណ + លក្ខ១ណ] មានកិ.គ្រាំគ្រាជាលក្ខ១ណ:។
ជីរតិ កិ. [ជីរ + អ + តិ-រ.] ចម្រើន, ចាស់, រេចរឹល, ជ្ជួតជ្ជាប។
ជីរន្តិ កិ. [ជីរ + អ + អន្តិ-រ.] ចម្រើនឡើង,ធំឡើង, ចាស់, គង់ចាស់, គង់គ្រាំគ្រា។
ជីរមាន គុ. [ជីរ + អ + មាន] កាលចម្រើន, កាលចាស់។
ជីរ១ម៎ តុ អ. [ជីរ + ណាម + តុ] ដើម្បីញ៉ាំង....ឲ្យជ្ជួតជ្ជាប, ឲ្យសាបរលាប, ឲ្យទ្រុឌទ្រោម, ឲ្យរលួយ។
ជីឥ ឬ. ជីវិត (ដូច **ជ១ណ**), សត្វ (ដូច **ជ១**) ។
ជីឥ១ម្ពឥ១ ន១ុ. [ជីវ១ + អម្ព + ១ន] ព្រៃនៃស្វាយរបស់កុមារឈ្មោះជីវ១:, វិហារឈ្មោះជីវ១ម្ពវន។

ជីវកវត្ថុ នបុ. [ជីវក + វត្ថុ] រឿងនៃ....ឈ្មោះជីវក: (**ជីវក**<ជីវ + ណ្ឍ = អ្នករស់នៅ, រ. **ជីវតីតិ**>**ជីវកោ**) ។

ជីវក បុ. ឈ្មោះឈើម្យ៉ាងប្រើធ្វើថ្នាំ (ដូច **មធុរក**) ។

ជីវគ្គាហ បុ. [ជីវ + គហ + ណ] ចាប់យកទាំងរស់, ការចាប់យកទាំងរស់។

ជីវញ្ជីវ បុ. សត្វជីវញ្ជីវ (សត្វព្រហីត) ដីកាប្រាប់ថាសត្វនេះមានរូបធំប្រមាណ ប៉ុនសត្វក្ងោកមានស្លាបដ៏វិចិត្រមាននៅក្នុងដែនទក្ខិណាបថជាដើម។

ជីវន នបុ. [ជីវ + យុ] កិ.រស់នៅ, ជាគ្រឿងរស់នៅ, ជាទីរស់នៅ។ -**មត្ត**គុ. គ្រាន់តែកិ.រស់នៅ, គ្រាន់តែជាគ្រឿងរស់នៅ។

ជីវនី ឥ. ដើមទាល់ (ដូច **ជីវន្តី**)។

ជីវន្ត គុ. [ជីវ + អន្ត] កាលរស់នៅ, កំពុងរស់នៅ។

ជីវន្តី ឥ. ដើមទាល់ (ដូច **ជីវនី**) ។

ជីវន នបុ. ការចិញ្ចឹមជីវិត, ការរស់នៅ (ដូច **ឋុត្តិ**) ។

ជីវភត្ត នបុ. [ជីវ + ភត្ត] ជីវភត្ត, ភត្តគឺបុគ្គលគប្បីឲ្យដល់ជនអ្នករស់នៅ, ឲ្យជាភត្ត គឺ.....គប្បីឲ្យចំពោះជនអ្នករស់នៅ, រ. **ជីវតីតិ**>**ជីវো**, **ជីវស្ស ទាតព្ពំ ភត្តំ** >**ជីវភត្តំ**។

ជីវមច្ឆក បុ. [ជីវ + មច្ឆ + ក] ត្រីរស់។

ជីវមាន គុ. [ជីវ + អ + មាន] កាលរស់នៅ, កំពុងរស់នៅ។

ជីវលោក បុ. [ជីវ + លោក] ជីវលោក, លោកគឺសត្ត, លោកគឺសត្វអ្នករស់នៅ, លោកជាទីអាស្រ័យនៅនៃសត្ត។

ជីវសិ កិ. [ជីវ + អ + សិ-រ.] រស់នៅ, រមែងរស់នៅ។

ជីវសុមន នបុ. ផ្កាកុឡាប, ផ្កាចា (ដូច **ជ្ជ**) ។

ជីវាម កិ. [ជីវ + អ + ម-រ.] រស់នៅ, រមែងរស់នៅ។

ជីវាហិ កិ. [ជីវ + អ + ហិ-រ.] ចូររស់នៅ។

ជីវិកា ឥ. [ជីវ + ណ្ឍ + ឥ-អា. + អា-ឥ.] អ្នករស់នៅ (ការរស់នៅ, កិ.ចិញ្ចឹមជីវិត ដូច **ឋុត្តិ**), រ. **ជីវតីតិ**>**ជីវិកា**។

ជីវិត នបុ. [ជីវ + ឥ-អា. + ត] កិ.រស់នៅ, រ. **ជីវិយតេតិ**>**ជីវិតំ**, **ជីវនំ ១**> **ជីវិតំ** ។ (ធម្មជាត) ជាគ្រឿងរស់នៅនៃសត្ត្ថ (ធម្មជាត) ជាទីប្រព្រឹត្ត ទៅនៃសម្ប្ស្ស យុត្តធម៌ (ជីវិត), **ជីវន្តិ អនេនាតិ**>**ជីវិតំ**, **ជីវន្តិ បវត្តន្តិ ឯត្ថ សម្ប្ស្ស យុត្តធម្មាតិ**>**ជីវិតំ**។ -**ករ** នបុ. កិ.សម្រេចនូវជីវិត, ជាគ្រឿងសម្រេចនូវជីវិត, ការចិញ្ចឹមនូវជីវិត។ -**ត្ថ** បុ. ប្រយោជន៍ដល់ជីវិត, សេចក្ដីត្រូវការដល់ជីវិត។ -**ទាន** នបុ. ការឲ្យនូវជីវិត។ -**អន្តរាយ** បុ. អន្តរាយនៃជីវិត, អន្តរាយដល់ជីវិត។ -**ប្ប្ស ច្ចយ** បុ. បច្ច័យនៃ...., ជាបច្ច័យនៃ.... ។ - **បរិយោសាន** នបុ. កាលជាទីបំផុតនៃជីវិត។ -**ប្ប្ស ភវត្ត ១ក** គុ. ជាគ្រឿងញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅ , រ. **ជីវិតំ បវត្តេតិ ១ តេនាតិ** >**ជីវិតប្ប្ស ភវត្ត ១ កំ**។ -**មត្ត** គុ. គ្រាន់តែកិ.រស់នៅ, គ្រាន់តែ

ជាគ្រឿងលៀងនូវជីវិត។ -**លាភ** បុ. កិ.បាននូវជីវិត។ -**ឞុត្តិ** ឥ. កិ. ប្រព្រឹត្តទៅនៃជីវិត (**ឞុត្តិ**<ឞ + តិ , អ នៃ ឞ>ឞ), វិ. **ឞត្តនំ>ឞុត្តិ, ជីវិតស្ស ឞុត្តិ>ជីវិតឞុត្តិ**។ -**សំខយ** បុ. កិ. អស់ទៅនៃជីវិត (សំ + ខិ ឬ ខី + ណ> សំខយ) ។ - **ហេតុ** បុ. ហេតុនៃជីវិត, គុ. មានជីវិតជាហេតុ។

ជីវិតិន្ទ្រិយ នបុ. [ជីវិត + ឥន្ទ្រិយ] ឥន្ទ្រិយគឺជីវិត។ -**ឃ្ឍដិពទ្ធ**គុ. ដែលជាប់ចំពោះ ហើយដោយឥន្ទ្រិយគឺជីវិត។ -**ឧបច្ឆេទ** បុ. កិ.ចូលទៅកាត់នូវ...., កិ. ដាច់សូន្យនៃជីវិតិន្ទ្រិយ។

ជីវិតុកាម គុ. [ជីវិតុំ + កម + ណ] អ្នកចង់ដើម្បីរស់នៅ, អ្នកប្រាថ្នាដើម្បីរស់នៅ, វិ. **ជីវិតុំ កាមេតីតិ>ជីវិតុកាមោ**។

ជីវិតុបាយ បុ. [ជីវិត + ឧបាយ] ឧបាយនៃជីវិត, ឧបាយជាគ្រឿងរស់នៅ។

ជីវិស្សថ កិ. [ជីវ + អ + ឥ-អា. + ស្សថ-ភ.] នឹងរស់នៅ។

ជីវិស្សាម កិ. [ជីវ + អ + ឥ-អា. + ស្សាមិ-ភ.] នឹងរស់នៅ។

ជីវីសុ កិ. [ជីវ + អ + ឧ-អជ្ជ.] រស់នៅហើយ។

ជីវេ កិ. [ជីវ + អ + ឯយ្យ-ស.] គប្បីរស់នៅ។

ជីវេយ្យុ កិ. [ជីវ + អ + ឯយ្យុ-ស.] គប្បីរស់នៅ។

ជីវ បុ. ខ្លួន, ចិត្ត (ដូច **អត្តា**), សត្ត (ដូច **បាណី**) ។

ជីវ ធា. **បាណធារណេ ជីវតិ ជីវិតំ ជីវោ ជីវិកា** "រស់នៅ, មានជីវិត "ទ្រទ្រង់ជីវិត" ភូ.។

ជុ ធា. **គតិយំ ជវតិ ជវនំ ជវោ ជវណ្ណោ ជវំ** "លឿនទៅ, រហ័ស, ស្ទុះ" ភូ. ។

ជុតិ ធា. **ឞជ្ជនេ ជុន្ធតិ** "លះបង់, រៀ" រុ. ។

ជុណ្ហ អ.ន. អាមាត្រឈ្មោះជុណ្ហ:។

ជុណ្ហា ឥ. ពន្លឺព្រះចន្ទ (ដូច **ចន្ទិកា**), ចំណែកខាងខ្មៃត, ខ្មៃត (ដូច **ចន្ទិកា យុត្តា**), ពន្លឺនៃព្រះចន្ទ (**ចន្ទប្ឋភា**), រាត្រីប្រកបដោយពន្លឺព្រះចន្ទ នោះ, ខ្មៃត (**ឥទុបេតនិសា**) ។

ជុតិ គុ. ល្អ (ដូច**សោភា**, **ឥន្ធិ**) ។ឥ. រស្មី, ពន្លឺ (ដូច **ឞភា**, **រំសិ**) ។

ជុតិន្ធរ គុ. [ជុតិ + ធរ + អ] អ្នកទ្រទ្រង់នូវរស្មី, ឬអ្នកទ្រទ្រង់នូវរស្មីដ៏រុងរឿង (ទីនេះប្រើជាបទអាលបន:ថា បពិត្រព្រះអង្គអ្នកទ្រទ្រង់នូវរស្មីដ៏រុងរឿង), វិ. **ជុតឺ ធារេតីតិ>ជុតិន្ធរោ**។

ជុតិមន្ត គុ. [ជុតិ + មន្ត] អ្នកមានសេចក្តីរុងរឿង, អ្នកមានរស្មីដ៏រុងរឿង, វិ. **ជុតិ យេសមត្ថីតិ>ជុតិមន្តោ**។

ជុតិ ធា. ១-**ភាសនទិត្តីសុ ជោតតិ ទិជ្ជោតតិ ជុតិ ជោតិ** "ពោល, ថ្លែង, ភ្លឺ, រុងរឿង" ភូ.។ ការិត. **ជោតេតិ ជោតយិត្វាន**, អា. **ជោតយិត្វាន សទ្ធម្មំ** "ញ្ជាំងព្រះសទ្ធម្ម ឲ្យរុងរឿង" -ស. ។

២-**ទិត្តិយំ ជុណ្ហា** "ភ្លឺស្វាង, រុងរឿង,...” គុ. (ផ្លាស់ត ជាណ ហាបច្ច័យ)

អា. **ជុណ្ហារត្តិ** "រាត្រីខៃក្លឹ, រាត្រីខាងខ្មើត" វិ. **ជុតិ អស្សាត្ថីតិ ជុណ្ហា**។ **ចន្ទស្ស ឆា ជុតឺ សោតំ ឆយ្ហតិ ពន្ធតីតិ ជុណ្ហា** (ជុតិ+ន ហ៊ា) ។ ឬមកពី (ជុសិ+ហ) ប្រែថា "រីករាយ" ។

ជុសិ ធា. ១-**ហឺសាយំ ឬតិសេវនេសុ ច ជុសតិ ជោសតិ** "ចៀតចៀន, ផ្ទ្រៃ ចិត្ត, រីករាយ, សេពគប់, ប្រតិបត្តិ" ភូ. ។

២-**ឬរិតក្ករនេ ជោសេតិ ជោសយតិ** "ត្រិះរិះ, គ្នេរគ្នាន់, ពិចារណា, កាញ់គ្នេរ" ចុ.។

ជុឝ្ឍ ធា. **គតិយំ ជុឝ្ឍតិ ជោឝ្ឍតិ** "ទៅ, ដល់, ប្រព្រឹត្តទៅ" ភូ. ។

ជូត បុ. ល្បែងបាសកា (ដូច **ក្ករ**) ។ -**ក**ម្ម [ជូត + កម្ម] នបុ.កម្មគឺកិ.លេងនូវបាស្ការ។ -**ការ**បុ. អ្នកលេងបាសកា (ដូច **ឧក្ករ**) ។

ជូឝ្ឍ ធា. **ពន្ធ ជូឝ្ឍតិ** "ចង់, ព័ន្ធព័ទ្ធ, រឹតរួត" ភូ. ។

ជ អា.និ.. នៃហាង, នៃមេ, ... ។

ជ ធា. ១- **ខយ ជីយតិ ជាយតិ** "អស់, សូន្យ, ក្ស័យ" ភូ. ។ អា. **ឥ ម ធនំ ន ជីយ** "ទ្រព្យរបស់ខ្ញុំមិនគប្បីអស់ទៅដូចម្តេចបាន ? " -ស. ។ ធាតុនេះមានរូប២គឺ **ជីយតិ ជាយតិ** ឯ **ជាយតិ** អាចឮច្រឡំនឹង **ជាយតិ** (<ជនិ) មានន័យថាកើត =**និព្ពត្តតិ** ក៏ប៉ុន្តែក្នុងទីនេះមានន័យថា អស់ទៅ =**ខយំ គច្ឆតិ**។

២-**ឧន្ធានត្ថនាមកៈ** និបាតប្រាប់អត្ថគឺហៅរកប្រែថា នៃនាង, ចូរមើល **ឧណ្ហ** ខាងដើម។

ជេតុច្ច គុ. [គុ-គុប + ឆ + ណ] គឺ....គប្បីខ្ពើម, -គួរខ្ពើម, -គួរតិះដៀល, វិ. **ជិគុ-ច្ឆិតព្ពោតិ** >**ជេគុច្ឆោ**។

ជេដ្ឋ គុ. [រ៉ុឌ្ឍ>ជឋ្ឋ>ជ + ឥដ្ឋ] ប្រសើរ, ថ្លៃថ្លា, ខ្ពង់ខ្ពស់, (ដូច **ឧត្តរ**, **អតិប្បសត្ថ**) (ពាក្យប្រៃនិងវិគ្គហៈដូច «**ជេដ្ឋក**») ។ -**ធីតុដ្ឋាន** នបុ. ទីនៃធីតាជាច្បង។ -**មូលមាស** បុ. ខែជាទីតាំងនៃខែប្រកបដោយជេដ្ឋ ឬក្ស, ខែជាខាងដើមនៃខែជេស្ឋ (ខាងខ្មើតនៃខែជេស្ឋ) ។ បុ. ខែជេស្ឋ, បុគ្គលចាស់ (ដូច **អតិវុទ្ធ**), បង (ដូច **ឧ្ជ**) ។

ជេដ្ឋក គុ. [រ៉ុឌ្ឍ>ជឋ្ឋ>ជ+ឥដ្ឋ + ក-ស.] ចម្រើនបំផុត, ប្រសើរបំផុត, ជាធំ, ជាចម្បង (ចូរមើលបទវិគ្គហៈក្នុងកថ្ចាយនូបត្ថម្ភកៈភាគទី២ត្រង់ **ឥន្ទ្ធ-ឥនិទ្ធេស**) ។ -**ឧសភ** បុ. គោចម្រើនបំផុត, គោប្រសើរបំផុត, អ្នកដូចជាឧសភប្រសើរបំផុត។ -**ឧ**ម្ភ**ិក** បុ. ឧ្ជ្ជ**ីអ្នកប្រសើរបំផុត, ឧ្ជ**ីជាច្បង។ -**ដ្ឋាន** នបុ. ទីនៃ....ប្រសើរបំផុត, -ជាច្បង។ -**តាបស** បុ. តាបសជាច្បង, តាបសអ្នកចម្រើនបំផុត។ -**ទេ**ឧ**ត្ត** បុ. ទេ**ត**ុត្ត**ជា**ច្ប**ង។ -**ឥ**ន**ិ**ដ្ឋ** បុ. ប្ន**ន**ច្ប**ង, ប្ន**ន**ជ**ាច្ប**ង។ -**ឧ**ត្ត** បុ. ឧ**ន**ប**ង, ឧ**ន**ជ**ាច្ប**ង។ -**ឧ**ស**ការ** បុ. ជ**ាងតម្ប**ាញ**ជ**ាច្ប**ង។ -**ភ**ិ**ឧ**ា** ឥ. ភ**ិ**ឧ**ាជ**ាច្ប**ង។ -**ស**ីល** នបុ. ស**ីលជ**ាច្ប**ង, ស**ីលប្រ**ស**ើ**រ**ំ**ផ**ុ**ត។

ជេដ្ឋ ត. ឈ្មោះផ្កាយឫក្សម្យ៉ាង។

ជេដ្ឋាបចាយិ-កកម្ម នបុ. [ជេដ្ឋាបចាយិក + កម្ម] កម្មនៃបុគ្គលអ្នកប្រព្រឹត្តកោតក្រែងដល់បុគ្គលជាច្បងឬអ្នកចម្រើនបំផុត, កម្មនៃបុគ្គលអ្នកប្រព្រឹត្តគោរពដល់បុគ្គលអ្នកជាច្បង ឬអ្នកប្រសើរបំផុត។

ជេតព្ព គុ. គប្បីឈ្នះ (ដូច **ជេយ្យ**), សព្ទនេះជាអត្ថនៃជេយ្យសព្ទ។

ជេតវន នបុ. [ជេត + វន] ព្រៃឈើរបស់ព្រះរាជកុមារឈ្មោះជេត (កាលដើមព្រៃឈើនោះឯងគឺព្រះរាជកុមារឈ្មោះជេត បានដាំហើយទ្រង់ជាម្ចាស់នៃព្រៃឈើនិងដីនោះបានជាគេហៅថា « **ជេតវនឬជេតពន** » គឺជាឈ្មោះអារាមមួយនៅជិតក្រុងសាវត្ថី ដែលអនាថបណ្ឌិកសេដ្ឋីបានទិញ អំពីព្រះរាជកុមារនោះ ដោយតម្លៃប្រាក់១ផកោដិ, តម្លៃសាងអស់ ១ផកោដិ, ធ្វើបុណ្យឆ្លងអស់១ផកោដិ, ទៀតរួមជា៥៤កោដិ) ។ -**ទ្វារកោដ្ឋក** បុ. ខ្លោងនៃទ្វារនៃវត្តឈ្មោះជេតពន, ស៊ុមនៃទ្វារនៃវត្តជេតពន។ -**មហាវិហារ** បុ. មហាវិហារ (វិហារធំ) ឈ្មោះជេតពន។ -**សមីប** នបុ. ទីជិតនៃវិហារជេតពន។ -**អាតិមុខី** គុ. អ្នកមានមុខចំពោះកាន់វត្តឈ្មោះជេតពន, អ្នកមានមុខឆ្ពោះទៅកាន់វត្តឈ្មោះជេតពន, អ្នកមានមុខឆ្ពោះទៅកាន់វត្តជេតពន។

ជេតុត្តរ នបុ. ទីក្រុងជេតុត្តរជាឈ្មោះទីក្រុង១ក្នុងដែនសក្ក។

ជេយ្យ គុ. ដែល...គប្បីឈ្នះ, ដែល...គួរឈ្នះ (ដូច **ជេតព្ព**), ប្រសើរ, ថ្លៃថ្លា, ខ្ពង់ខ្ពស់ (ដូច **អតិប្បសត្ថ**), បុគ្គលចាស់ (ដូច **អតិវុទ្ធ**) ។

ជេសិ ធា. **គតិយំ ជេសតិ ជេស្សតិ ជេស្សមានោ ជេស្សន្តោ ជេស្សុ** "ទៅ, ដល់, ប្រព្រឹត្តទៅ" ភូ. ។ ជេស្សតិមិនមែនភវិ. ទេ។ អា. **ជេស្សន្តំ ឥរិទុគ្គេសុ** "កាលធ្វើដំណើរទៅលើភ្នំនិងផ្លូវដែលដើរបានដោយលំបាកទ"-ស. ។

ជោតិ ឬ. ភ្លើង (ដូច **ជាតវេទ**, **អគ្គិ**), នបុ. ផ្កាយ (ដូច **តារា**, **ឧក្ខ្ពត**),ពន្លឺ (ដូច **រំសិ**) ។

ជោតិក គុ. [ជុតិ+ណិក] អ្នកមានសេចក្តីរុងរឿង, វិ. **ជុតិ យស្ស អត្ថីតি>ជោតិកោ**។ -**ត្ថេរ** បុ. ព្រះថេរៈឈ្មោះជោតិកៈ។ - **សេដ្ឋី** បុ. សេដ្ឋីឈ្មោះជោតិកៈ។

ជោតិបាសាណ ឬ. [ជោតិ + បាសាណ] ថ្មដ៏រុងរឿង, ថ្មមានរស្មីដ៏រុងរឿង។

ជោតិយ គុ. [ជុតិ + ឥយ] អ្នកមានសេចក្តីរុងរឿង។ អ.ន. សេដ្ឋីឈ្មោះជោតិយៈ។

ជោតិរស គុ. [ជោតិ + រស] មានរស្មីដ៏រុងរឿង, វិ. **ជោតិ រសោ រំសិ យស្សាតি > ជោតិរសោ** ។

ជោតិសត្ថ នបុ. វេទង្គគឺអង្គនៃវេទម្យ៉ាង, ជោតិសាស្ត្រ។

ជោតេត្វា អ. [ជុត + ណោ + ត្វា] ញ៉ាំង....ឲ្យរុងរឿងហើយ, -ឲ្យភ្លឺហើយ។

ជ្ឈ ត. ខ្សែបន្ទោះធ្នូ (ដូច **ឥណ**) ។

ជ្ឈិ ធា. **ឧក្ខេ ជ្ឈិសេតি ជ្ឈិសយតি** "រក្សា, ស្ងួនគ្រង" ចុ. ។

ឈ

ឈជ្ឌរី ត. បន្លែម្យ៉ាង, ម្រ ។

ឈជ្ឌ ធា. **បរិភាសនតជ្ជនេសុ ឈជ្ឌតិ** "ជេរ, ប្រទេច, កម្ទើញ, ពោលបន្ទាច, សម្ដុត, ជម្ជាប" ភ្ជ. ។

ឈមិ ធា. **អទនេ ឈមតិ** "ស៊ី, បរិភោគ" ភ្ជ. ។

ឈលិកា ត. សត្វរៃ (ដូច **ចីរី**) ។

ឈសា ត. តាសក់ស្រូវ (ដូច **នាគលតា**) ។

ឈស ឬ. ត្រី (ដូច **អម្ពុជ**) ។

ឈសិ ធា. **ហីសាយំ ឈសតិ** "ចៀតចៀន" ភ្ជ. ។

ឈាជក ឬ. ឈ្មោះឈើម្យ៉ាង (ដូច **គោលីស**) បាឡីខ្លះថា **ឈាជល**, ដីកាប្រាប់ថា **ឆាជលិបុប្ផាការោ ទ្ធិយជ្ជលោ រុក្ខោ** ឈើមានផ្លែរ៉ែង មានបែបភាពដូចផ្ការ៉ាច្រនៀង ។

ឈាតិ កិ. [ឈ + អ + តិ-រ.] ដុត, ឆេះ ។

ឈាន នឬ. [ឈ + យុ ឬឈា + យុ] (ធម្មជាត) គិតនូវអារម្មណ៍, សម្លឹងយកនូវអារម្មណ៍ ឬ (ធម្មជាត) ដុតនូវនីវរណធម៌ជាសត្រូវ(ឈាន), វិ. **អារម្ម ណំ ឈាយតីតិ >ឈានំ , ឍ្ឍនីវ ណេ ធ ម្មេ ឈាបេតីតិ ឆ >ឈានំ** ។ **-ក ីឡ ា** ត. កិ.លេងក្នុងឈាន, កិ.លេងដោយឈាន ។ **-ឍ្ឍ ុ ត** គុ. អ្នកខ្ជល់ខ្ជាយក្នុងឈាន ។ **-រ ត** គុ. អ្នកត្រេកអរហើយក្នុងឈាន ។ **-ឈ ាត ី** គុ. អ្នកបាននូវឈាន, អ្នកមានកិ.បាននូវឈាន, អ្នកមានកិ.បាននូវឈានជាប្រក្រតី (ចូរប្រកបវិគ្គហ:តាមពាក្យប្រែនេះផងចុះ) ។ **-ឝ ិ ប ស្ស - ន ា ម គ្ គ ផ ល ធ ម្ម** ឬ. ធម៌គឺឈាននិងវិបស្សនា និងមគ្គ និងផល ។ **-ឝ ិ ប ស្ស ន ា ម ត្ ត** គុ. គុណត្រឹមតែឈាននិងវិបស្សនា ។ **-ស ុ ខ** នឬ. សុខក្នុងឈាន, សុខដែលកើតអំពីឈាន ។ សេចក្ដីគិត, ការគិត, គំនិត (ដូច **ចិន្តា**) ។

ឈានាទិភេទ គុ. [ឈានាទិ + ភេទ] ផ្សេងដោយគុណវិសេសមានឈានជាដើម, មានឈានជាដើមជាប្រភេទ ។

ឈានាភិញ្ញា ត. [ឈាន + អភិញ្ញា] ឈាននិងអភិញ្ញា ។

ឈានុប្ប ាទ ិ ក ា ត. [ឈាន + ឧ + បទ + ណ្យ + ត-អា. + អា-ត.] អ្នកញ្ជាំងឈានឲ្យកើតឡើង, វិ. **ឈានំ ឧ ប្ប ាទ េ ត ីតិ >ឈ ា ន ុ ប ្ ប ា ទ ិ ក ា** ។

ឈាបនកិច្ច នបុ. [ឈាបន+កិច្ច] កិច្ចដោយកិ.ដុត, កិច្ចគឺកិ.ដុត, កិច្ចគឺកិ.ញ៉ាំងសរីរៈ ឲ្យឆេះ (ឈាបន <ឈាប + យុ ឬ ឈា + ណាបេ + យុ), វិ. **ឈាបិយតេតិ>ឈាបនំ** ។

ឈាបិត គុ. [ឈាប + ឥ-អា. + ត] គឺ....ដុតហើយ, គឺភ្លើងឆេះហើយ ។

ឈាបិយមាន គុ. [ឈាប + ឥ-អា. + យ + មាន] គឺភ្លើងកាលឆេះ, គឺ....កាលដុត ។

ឈាបេតិ កិ. [ឈាប + ណេ + តិ-វ.] ដុត, ញ៉ាំង....ឲ្យឆេះ ។

ឈាបេត្វា អ. [ឈាប + ណេ + ត្វា] ដុតហើយ, ញ៉ាំង....ឲ្យឆេះហើយ ។

ឈាបេសិ កិ. [ឈាប + ណេ + ឦ-អជ្ជ.] ដុតហើយ, ញ៉ាំង....ឲ្យឆេះហើយ ។

ឈាបេហិ កិ. [ឈាប + ណេ + ហិ-ប.] ចូរដុត, ចូរញ៉ាំង....ឲ្យឆេះ ។

ឈាបិ ធា. **ទាហេ ឈាបេតិ ឈាបយតិ ឈណ្ណោ** "ដុត, ឆេះ" ចុ. ។ ការិត. **ឈាបាបេតិ ឈាបាបយតិ ឈាបិតោ** ។ **ឈានំ** នបុ. ឈាន "ដុតនីវរណធម៌" ។

ឈាម គុ. [ឈេឬឈា + ម] គឺភ្លើងឆេះហើយ, គឺភ្លើងកំពុងឆេះ ។ **-សិត្ត** នបុ. គ្រាប់បាយដែលភ្លើងឆេះហើយ (បាយក្តាំង, បាយខ្លោច) ។ **-កាល** បុ. កាលនៃគន្ធកុដិគឺភ្លើងកំពុងឆេះ, -ឆេះហើយ ។ **-ខាណុមត្ថក** បុ. ទីបំផុតនៃដង្គត់គឺភ្លើងឆេះហើយ, ចុងនៃដង្គត់គឺភ្លើងឆេះហើយ ។ **-ក្ខេត្ត** នបុ. ស្រែដែលភ្លើងឆេះហើយ ។

ឈាយនវសេ បុ. [ឈាយន + វសេ] អំណាចនៃកិ.ឆេះ, -ដុត ។

ឈាយន្ត គុ. [ឈេ + អ + អន្ត] កាលដុត, ... ។

ឈាយមាន គុ. [ឈេ + អ + មាន] កាលដុត, កាលឆេះ, គឺភ្លើងកំពុងឆេះ ។

ឈាយសិ កិ. [ឈេ + អ + សិ-វ.] សញ្ជប់សញ្ជឹង, សុបសៅ, សំកុក, ដុត ។

ឈាយិត្វា អ. [ឈេ + ឥ-អា. + ត្វា] ឆេះហើយ, ដុតហើយ ។

ឈាយី គុ. [ឈេ + ណី] អ្នកសម្លឹង, អ្នកពិនិត្យ, អ្នកស្ទឹងស្ទាត់, អ្នកមានឈាន, វិ. **ឈាយតីតি >ឈាយី** ។

ឈាយីសុ កិ. [ឈេ + អ + ឧ-អជ្ជ.] ឆេះហើយ, ដុតហើយ ។

ឈាយំ គុ. [ឈេ + អ + អន្ត + សិ-វិ., ផ្លាស់ន្ត + សិ-វិ. >អំ] កាលដុត, (កាលញ៉ាំងកិលេសឲ្យឆេះ) ។

ឈាលុក បុ. ឈ្មោះឈើម្យ៉ាង (ដូច **ឬចុល**), បាលីខ្លះ **ឈាតុកោ** ។

ឈេ ធា. **ទិត្តិយំ ឈាយតি** "ភ្លឺ, រុងរឿង, ឆេះ" ភ្ជ. ។ អា. **ទីឃោ ឈាយតি** "ប្រទីប ភ្លឺ" -ស. ។ **ឈាយនំ =ជ្ឈលនំ** ។

ឈេ ធា. **ចិន្តាយំ ឈាយតি និជ្ឈាយតি ឧបនិជ្ឈាយតি សញ្ជ្ឈាយតি** "នឹក, គិត, ពិនិត្យ, ពិចារណា,...” ភ្ជ. ។ **ឧជ្ឈាយតি** "លើក

ទោស, ថ្កោលទោស, រិះគន់, តិះដៀល" កិន, **ឧជ្ឈត្តិ ឧជ្ឈាយនំ** ។ **និជ្ឌានំ ឧបនិជ្ឌានំ សញ្ជ្ឌាយនំ** នបុ. "ការពិនិត្យពិចារណា,..."។ **ឈានំ** នបុ. "ឈាន,..." ។ **ឈាយី** គុ. "អ្នកមានឈាន,..." ។ **ឧបជ្ឌា ឧបជ្ឌាយោ** បុ. "ព្រះឧបជ្ឌា "អ្នករំពៃមើលទោសតូចធំរបស់សិស្សដោយចិត្ត" រ. **មនសា ឧបេច្ច សិស្សានំ ឥជ្ជាឥជ្ជំ ឈាយតីតិ ឧបជ្ឌា** (**ឧប+ ឈេ+អ+ អា**) **ឧបជ្ឌាយោ** (**ឧប+ឈេ+ណ សូចិ**) ។

ញ

ញ្ញត្ត នបុ. [ញ្ញាត + ត្ត] ភាវៈនៃកិ.ដឹង, វិ. **ញ្ញាតស្ស ជានតស្ស ភាវោ>ញ្ញត្តំ**។ **ញ្ញត្ត** បុ. ជិត (ដូច **អវិទូរ**)។

ញ្ញត្វា អ. [ញ្ញា + ត្វា] ដឹងហើយ, ជ្រាបហើយ។

ញ្ញប ធ. **តោសនានិសានេសុ ញ្ញាបេតি ញ្ញាបយតি បញ្ញាបេតি បញ្ញាបយតি** "រីករាយ, ត្រេកអរ, សំលៀង, សម្រួច" បុ. ។ **បញ្ញាបេតি បញ្ញបេតি** "ក្រាល, បញ្ញត្ត, តែងតាំង" ។ ការិត, **បញ្ញាបាបេតি បញ្ញាបាបយតি**។ **បញ្ញបេតি បញ្ញាបេតি** បើកើតចាក ធាតុនេះជាកត្តុវាចក: បើសម្រេចមកពី (ប+ញ្ញ+ ណាបេ) ជាហេតុកត្តុវាចក:។ **បញ្ញត្តি** ឥ. "ការតែងតាំង,..." ។ **បញ្ញត្ត** កិ. គុ. "ដែលបញ្ញត្ត, តែងតាំងហើយ,..." ។

ញ្ញម ធ. **អទនេ ញ្ញមតি** "ស៊ី, បរិភោគ" ភ្ងូ. ។

ញ្ញ ធ. ១-**អវពោធនេ ញ្ញាតি អញ្ញាតি** "ដឹង, ត្រាស់ដឹង,..." ភ្ងូ. ។ **ញ្ញាតি ញ្ញាតកោ** បុ. "ញ្ញាតি, បងប្អូន" ដឹងថាពួករបស់យើង។ **អញ្ញ** បុ. "មនុស្សល្ងង់, កម្លៅ" មិនដឹងអ្វី (ន+ញ្ញ) =អវិទ្ទា, ពាលោ, -ស. ។ **អញ្ញ** ឥ. "ព្រះអរហត្តផល" ត្រាស់ដឹង (អា+ញ្ញ) ។ **បញ្ញត្តি ញ្ញត្តি** ឥ. "ការប្រកាស, ការផ្ទៀង, ការប្រាប់ឲ្យដឹង, ឲ្យចូលចិត្ត" (ប+ញ្ញ+ តি, ញ្ញ+តি) ។ **សញ្ញ** ឥ. "ការចំណាំ, សម្គាល់" (សំ+ញ្ញ) ។ **ឱ្ញាណ** នបុ. "វិញ្ញាណ, ចិត្ត" ស្គាល់ច្បាស់ (វិ+ញ្ញ+យុ) ។ **បញ្ញ** ឥ. "ប្រាជ្ញា, សេចក្តីឈ្លាសវៃដឹងត្រូវ" (ប+ញ្ញ) ។

២-**ហារណតោសនានិសានេសុ ញ្ញត្តি ញ្ញាតি** "សម្លាប់, ឲ្យរីករាយ, សំលៀង, សម្រួច, ធ្វើឲ្យមុត" ភ្ងូ. ។ **ញ្ញត្តি** សព្ទនេះជាកិរិយាអាខ្យាត =**ហរតি** សម្លាប់, =**តោសេតি** ឲ្យត្រេកអរ, រីករាយ, =**និសេតি** "សំលៀង, សម្រួច" ។ **ញ្ញត្តি** ជាកិរិយាសព្ទដូច**ឥត្តি** "ពោល" ជាកិរិយាអាខ្យាតនោះដែរដូចបាលីថា **ឥត្តি ឯតាយតি ឥតិ** (វ+អ+ តি)។ **មនុញ្ញ** គុ. "ល្អ, ប្រសើរ, លើសលុប" ធ្វើចិត្តឲ្យរីករាយក្រៃលែងវិ. **មនំ អាភុសោ តោសេតីតি មនុញ្ញោ** -ស. (មន+អា>ឧ+ ញ្ញ+អឬមន+អា>ឧ+ញ្ញ+ក្ត) ។

៣-**អវពោធនេ ជានាតি ជានតំ ជានន្តោ ជានមានោ ជានិតុំ** "ដឹង, ត្រាស់ដឹង" ក. ។ កម្ម. **ញ្ញាយតি នាយតি ។ ជញ្ញ** កិ. "គប្បីដឹង" (ញ្ញ+ឯយ្ស) ។ **ញ្ញេយ្យ** គុ. "គួរដឹង,..." (ញ្ញ+ណ្យ) ។ **បញ្ញាយតি**

កិ. **សុទ្ធកត្តុ**. "ប្រាកដ, ល្បីល្បាញ" (ប+ញា+យ+តិ) ទិ. ។ **បញ្ញាត** កិ.គុ. "ដែលល្បីល្បាញ, ដែលប្រាកដ" ។ **បញ្ញាណិ** នបុំ. "ប្រាជ្ញា" ។

ញាណ នបុំ. [ញា + យុ] កិ.ដឹង, សេចក្ដីឬ(ធម្មជាត)ជាគ្រឿងដឹង (ញាណ, ប្រាជ្ញា ដូច**វិជ្ជា**), វិ. **ញាយតីតি>ញាណំ**។ -**ខគ្គ** បុំ. ព្រះខាន់គឺញាណ, ញាណដូចជាកំបិតកោរ។ -**អគ្គិ** បុំ. ភ្លើងគឺញាណ, ញាណដូចជាភ្លើង។ -**បថ** បុំ. គន្លងគឺញាណ, ផ្លូវនៃញាណ។ -**បរិបាក** បុំ. កិ.ចាស់ជុំវិញនៃញាណ (**បរិបាក**<បរិ + បច + ណ = ចាស់ជុំវិញ, ចាស់ពេញលេញ, ចាស់គ្រប់គ្រាន់, ឆ្ពិនសព្ព) ។ -**ប្បទីប** បុំ. ប្រទីបគឺញាណ, ញាណដូចជាប្រទីប។ -**ផុសនា** ឥ. កិ.ពាល់ត្រូវគឺញាណ, (ធម្មជាតិ) ជាគ្រឿងពាល់ត្រូវគឺញាណ, (ធម្មជាតិ)គឺបុគ្គលគប្បីពាល់ត្រូវគឺញាណ។ -**សម្បយុត្ត** គុ. ដ៏សម្បយុត្តដោយញាណ, ដែលប្រកបព្រមហើយដោយញាណ។

ញាណទស្សន នបុំ. ផលមានសោតាបត្តិផលជាដើម, វិបស្សនាមានអនិច្ចានុបស្សនាជាដើម, ទិព្វចក្ខុ, សព្វញ្ញុតញ្ញាណ, បច្ចវេក្ខណញ្ញាណ, មគ្គមានសោតាបត្តិមគ្គជាដើម។

ញាណានុភាព បុំ. [ញាណ + អានុភាវ] អានុភាពនៃញាណ។

ញាតក បុំ. [ញា + តិ + ក-ស.] ជនដែលគេត្រូវស្គាល់ (ញាតិ, ជនជាញាតិដូចពន្ធវ), វិ. **ញាបេតព្វោតি>ញាតិ**, **ញាតិ ឯវ>ញាតកោ**។

ញាតត្ថចរិយា ឥ. [ញាតិ + អត្ថ + ចរិយា] កិ.ប្រព្រឹត្តដើម្បីប្រយោជន៍ដល់ញាតិ, ការប្រព្រឹត្តដើម្បីជាប្រយោជន៍ដល់ញាតិ។

ញាត កិ.គុ. [ញា + ត] គឺ.....ដឹងហើយ, ត្រាស់ដឹងហើយ (ដូច **ឥទិត**), នបុំ. កិ. នបុំ. ដឹង។ -**ធម្ម** [ញាត + ធម្ម] អ្នកមានធម៌ដឹងហើយ, វិ.**ញាតោ ធម្មោ យេហិ តេ>ញាតធម្មា**។ -**បរិញ្ញា** ឥ. ការកំណត់ដឹងដោយកិ.ដឹង, (ធម្មជាតិ)គឺបុគ្គលគប្បីកំណត់ដឹងដែលខ្លួនដឹងហើយ (ញាតបរិញ្ញា)។ -**ភាព** បុំ. ភាវៈនៃ....ជាគុណជាតគឺខ្លួនដឹងហើយ។

ញាតិ បុំ. [ញា + តិ] (ជន) ដែលគេត្រូវស្គាល់ (ញាតិដូច **សគោត្ត**) , វិ. ចូរមើល « **ញាតក**» ។ -**ឧបដ្ឋាន** បុំ. ញាតិនិងជនជាឧបដ្ឋាក។ -**កុល** នបុំ. ត្រកូលនៃញាតិ។ -**គណ** បុំ. ពួកនៃញាតិ, ក្រុមនៃញាតិ។ -**ជន** នបុំ. ជនជាញាតិ។ -**ទារក** បុំ. ទារកជាញាតិ, ទារកនៃញាតិ។ -**ធីតា** ឥ. ធីតាជាញាតិ, ធីតានៃញាតិ។ -**បរិវដ្ដ** បុំ. កិ.វិលទៅជុំវិញនៃញាតិ, ការវិលទៅជុំវិញនៃត្រកូលជាញាតិ (ជួរនៃញាតិ) ។ -**ពន្ធុវិរហិត** គុ. ដែលប្រាសហើយចាកញាតិនិងផៅពង្ស។ -**មជ្ឈ** នបុំ. កណ្ដាលនៃញាតិ។ -**មិត្ត** បុំ. ញាតិនិងមិត្រ។ -**សត** នបុំ. រយនៃញាតិ។ -**សមាគម** បុំ. ទីជាទីមកព្រមនៃញាតិ, កាលជាទីប្រជុំប្រជុំនៃញាតិ, កិ.ជួបជុំនៃញាតិ, ការជួបជុំនៃញាតិ។ -**សម្ជុមុខ្ជាត** គុ. គឺពួកនៃញាតិធ្វើក្នុងខាងមុខហើយ,

គឺពួកនៃញាតិចោមរោមហើយ (**បុរេ្ហត**<បុរ + ករ>ខ + ត) ។ -**សញ្ញ-ខិនាស** បុ.សេចក្តីវិនាសនៃពួកញាតិ ។ -**សំសគ្ គ** បុ. សេចក្តីជាប់ព្រមដោយញាតិ, ការជាប់ជំពាក់ដោយញាតិ, ការច្រឡូកច្រឡប់ដោយញាតិ (<សំ + សជ + ណ, ជ>គ>គ្ គ, លុបណ) ។ -**សំសដ្ ឋ** គុ. ដែលជាប់ព្រមដោយញាតិ, ដែលច្រឡូកច្រឡំដោយញាតិ (**សំ** + **សជ** + ត, ជ + ត>ដ្ ឋ) ។ -**សន្ហ** បុ. សេចក្តីសង្គ្រោះដល់ញាតិឬនូវញាតិ។ - **សាណោហិត** បុ. ញាតិនិងសាណោហិត, ញាតិនិងជនអ្នកប្រព្រឹត្តទៅមួយអន្លើដោយលោហិត, ញាតិនិងជនអ្នកមានលោហិតស្មើគ្នា, ញាតិនិងជនអ្នកមានលោហិតរួមគ្នា។ -**សាណោហិតិត្ថី** ឥ. ស្រីជាញាតិនិងជាសាណោហិត។ -**សិនេហ** បុ. សេចក្តីស្នេហាចំពោះញាតិ, សេចក្តីស្រឡាញ់ក្នុងញាតិ។ -**សុហជ្ជ** បុ. ញាតិនិងបុគ្គលជាទីស្រឡាញ់, ញាតិនិងភាវៈនៃបុគ្គលអ្នកមានហ្ជ្ជ័យល្អឬចិត្តល្អ (សុហជ្ជ<សុ + ហ្ជ + ណ្យ = វិ. **សុន្ទរំ ហ្ជ្ជ យមេតស្សាតិ**>**សុហ្ជ្ជ**, **សុហ្ជ្ជ ស្ស ភ្ជ្ជ ភ្ជ្ជ**>**សុហ្ជ្ជ**ំ។

ញ្ជ្ជ ាតុ	អ.	[ញ្ជ + តុ] ដើម្បីដឹង, កិ.ដឹង។
ញ្ជ្ជ ាបនត្ថ	បុ.	[ញ្ជ ាបន + អត្ថ] ប្រយោជន៍ដល់កិ.ញ្ជ ាំងបុគ្គលឲ្យដឹង, សេចក្តីត្រូវការដល់កិ.ញ្ជ ាំង....ឲ្យដឹង។
ញ្ជ្ជ ាបន	នបុ.	ការប្តឹង, ការឲ្យដឹង, ការបញ្ជ ាក់, សព្ទនេះជាអត្ថនៃវិញ្ញ ត្តិសព្ទ។
ញ្ជ្ជ ាបេតុ្ត ាម	គុ.	[ញ្ជ ាបេតុ + កម + ណ] អ្នកប្រាថ្នាដើម្បីញ្ជ ាំង.....ឲ្យដឹង, អ្នកចង់ដើម្បីញ្ជ ាំងអ្នកណានីមួយឲ្យដឹង។
ញ្ជ្ជ ាយ	គុ.	ណែនាំ (ដូច **ឧ្ត ាយ**), សមគួរ (ដូច **យុ្ត ្ត ិ**), (ធម៌)មានមគ្គជាដើមប្រកបដោយបដិបទា។
ញ្ជ្ជ េយ្ យ	គុ.	ធម៌ដែលគម្ប៉ីដឹងមាន៥យ៉ាងគឺ សង្ខ ារ១វិការ១លក្ខ ណ១និ ព្ជ ាន១ បញ្ញ ត្តិ១។

ដ

ដលិ	ធ.	**ភេលម្ហេ ដលតិ** "ឈោង, គោង, យុរយារ" ភ្ញ. ។
ដិកេ, ដេកេ	ធ.	**គតិយំ ដេកតិ** "ទៅ, ដល់, ប្រព្រឹត្តទៅ" ភ្ញ. ។ **ដីកា** ឥ. ជាឈ្មោះគម្ពីរសម្រាប់ កែខ្ចៃអដ្ឋកថាចាត់ជាថ្នាក់ទី៣គឺ ១/បាលី ២/អដ្ឋកថា កែបាលី ៣/ ដីកាកែអដ្ឋកថាឬទាំងបាលីផង។
ដិច	ធ.	**ខេបេ ដេបតិ** "បោះទៅ,...״ ភ្ញ. ។
ដុលិ	ធ.	**ភេលម្ហេ ដុលតិ** "ឈោង, គោង, យុរយារ" ភ្ញ. ។
ដំក	ប៉ុ.	ដៃកសម្រាប់ចោះថ្ម, ដៃកសម្រាប់ទម្លាយថ្ម (ដូច**ចាសាណាការ ណា**) ។

ឋ

ឋត្វា អ. [ឋា + ត្វា] ឋិតនៅហើយ , តាំងនៅហើយ, ឈរនៅហើយ។

ឋបនដ្ឋាន នបុ. [ឋបន + ឋាន] ទីជាទីតាំងទុក, ទីជាទីតម្កល់ទុក។

ឋបនោកាស បុ. [ឋបន + ឱកាស] ឱកាសជាទីតាំងទុក, ឱកាសជាទីតម្កល់ទុក។

ឋបន បុ. ការតម្កល់ទុក, ការតាំងទុក, សព្ទនេះជាអត្ថនៃបញ្ញត្តិសព្ទ។

ឋបយឺសុ កិ. [ឋប + ណាបេ + ឧ-អជ្ជ.] តាំងទុកហើយ, តម្កល់ទុកហើយ។

ឋបាបេត្វា អ. [ឋប + ណាបេ + ត្វា] ញ្ចុំង....ឲ្យតាំងទុកហើយ, ឲ្យតម្កល់ទុកហើយ, -ឲ្យដាក់ហើយ។

ឋបាបេសិ កិ. [ឋប + ណាបេ + ណ្ឌ-អជ្ជ.] ញ្ចុំង.....ឲ្យតាំងទុកហើយ, ... ។

ឋបិត គុ. [ឋប + ឥ-អា. + ត] គឺ....តាំងទុកហើយ, -តម្កល់ទុកហើយ, -ដាក់ហើយ។

-**អាលមក** នបុ. ផ្លែកន្ទួតព្រៃដែលបុគ្គលតម្កល់ទុកហើយ។ -**ឥណ្ឌ្ហិកា** ឥ. ហោជាងគឺ....តម្កល់ទុកហើយ។ -**កំសតាល** បុ. រគាំងដែល....តម្កល់ទុកហើយ។ -**ឥលញ្ជ** បុ. ឥន្ទ្រលដែល.... តាំងទុកហើយ, -តម្កល់ទុកហើយ។ -**ឥម្ពណ្ណ** បុ. ផ្លែល្ពៅដែល.... ដាក់ហើយ, -តម្កល់ហើយ។ -**ដ្ឋាន** នបុ. ទីនៃបុគ្គលតម្កល់ទុកហើយ។ -**ឋបិតដ្ឋាន** នបុ. ទីនៃ.....គឺបុគ្គលតម្កល់ទុកហើយ។ ។ - **និយាម** បុ. ទំនងនៃ.... គឺបុគ្គលតាំងទុកហើយ, ការកំណត់នៃ....គឺ... ។ -**ភត្ត** នបុ. ភត្តគឺ..... ។ -**ភាគភត្ត** នបុ. ភត្តជាចំណែកគឺ.... ។ -**ភារ** បុ. ភារ:នៃ....ជារបស់គឺ... ។ -**មណិរតន** នបុ. កែវគឺកែវមណីដែល.... ។ -**មត្ត** បុ. គ្រាន់តែគឺ.... ។ -**មំស** នបុ. សាច់គឺ..... ។ -**ឥដិរបន្ធី** ឥ. របៀបនៃពេជ្រដែល...។ -**សនិស** គុ. ប្រាកដស្មើដោយទីដែល..... ។

ឋបិយមាន គុ. [ឋប + ឥ-អា. + យ + មាន] គឺ....កាលតាំងទុក, ... ។

ឋបេត្វា អ. [ឋប + ណេ + ត្វា] ញ្ចុំង....ឲ្យឋិតនៅហើយ, តាំងទុកហើយ, តម្កល់ទុកហើយ, ទុកហើយ, លើកលែង, លើកទុក, រៀរលែង។

ឋបេន្ត គុ. [ឋប + ឯ ឬ ណេ + អន្ត] កាលតាំងទុក, កាលដាក់, ... ។

ឋបេសិ កិ. [ឋប + ឯ ឬ ណេ + ណ្ឌ-អជ្ជ. + ស-អា.] តាំងទុកហើយ, តម្កល់ទុកហើយ។

ឋបេហិ កិ. [ឋប + ឯឬណោ + ហិ-ប.] ចូរតាំងទុក, ចូរដាក់។

ឋស្សតិ កិ. [ហា + អ + ស្សតិ-ភ.] នឹងបិតនៅ។

ឋា ធ. ១-**គតិនិវត្តិយំ ឋាតិ តិដ្ឋតិ សណ្ឋាតិ សណ្ឋហតិ** "ស្ថិតនៅ, តាំងនៅ, ឈរ" ភូ. ។ រូបដទៃ **ឋិតោ ឋត្វា ឋាតុំ សណ្ឋានំ** ។ **ឋានំ** នបុំ. ប្រែបាន៤ន័យ៖១/ **ឥស្សរិយំ** "ឋាន:, តំណែង, ងារ" បាលីថា **ឥិស្សរិយស្មា ឋេនានមិន្ទោ ឥមំ ឥត្វា ឥមំ ឋានំ ឋបេ**។ ២/ **ឋិតិ** "ស្ថិតិ, តាំងនៅ, ប្រព្រឹត្តទៅ" បាលីថា **ឋានកុសលោ ហោតិ អក្ខណវេធី**។ ៣/ **ខណោ** "គ្រា, ស្រាប់, ខណ:" បាលីថា **ឋានសោ ឋេតំ តថាគតំ ឋដ្ឋិតាតិ**។ ៤/ ហេតុ "ហេតុ, ការណ៍" បាលីថា **ឋានញ្ច ឋានតោ ញត្វា**។ ខសង្កេត: **តិដ្ឋតិ** មតិកច្ចាយន: ផ្លាស់**ឋ**ធាតុ ទៅជា**តិដ្ឋ**+អ+តិ>**តិដ្ឋតិ**ដោយសូត្រថា "**ឋាតិដ្ឋោ**" ។ តាមវិធីអព្ភាស:ថាហ-ហ+អ+តិផ្លាស់អានៃហជាឥ, ហ>ត>តិ, ហ+អ>ហ+តិ>តិដ្ឋតិ។

២-**គតិនិវត្តិយំ ឋាយតិ** "តាំងនៅ, ស្ថិតនៅយឺនយូរ" បញ្ឍ្ឍ ដំណើរទៅ," ទិ. ។ **ឋាយី** គុ. អ្នកស្ថិតនៅយឺតយូរ,... ។ **ឧប្បជ្ជាយី** គុ. "អ្នកស្ថិតនៅអស់កល្ប" ។ តាមមតិស.ថា **ឋាតិ តិដ្ឋតិ ឋាយតិ** ជាអកម្មធាតុ។ **ឋបេតិ ឋបេតុំ** "តម្កល់ទុក, តាំងទុក" ទើបឈ្មោះ ថាសកម្មធាតុ។

ឋាតព្ព គុ. [ហ + តព្ព] គឺ....គប្បីតាំងនៅ, គឺ.... គប្បីឈរ។

ឋាតិ កិ. [ហ + អ + តិ-វ.] តាំងនៅ, -បិតនៅ, -ឈរនៅ។

ឋាតុំ អ. [ហ + តុំ] ដើម្បីតាំងនៅ, -បិតនៅ, -ឈរនៅ។

ឋាន នបុំ. [ហ + យុ] ទី, ទីជាទីតាំង, កន្លែង (ដូច **ឱកាស**), ហេតុ, ហេតុជាទីតាំង, ហេតុជាទីតាំងនៃផល (ដូច **ការណ**), ការតាំងនៅ, ការបិតនៅ, កិ.បិតនៅ, កិ.ឈរ, (ដូច **ឋិតិ**), ឋាន:, ជាន់, ថ្នាក់ងារ, ស័ក្តិ (ដូច **ឥស្សរិយ**)។

ឋានន្តរ នបុំ. [ឋាន + អន្តរ] លំដាប់នៃទី...., លំដាប់នៃទីជាទីតាំង, ឋានន្តរ, ឋានន្តរស័ក្តិ។ -**ឋ្ឋ** គុ. ដល់ហើយនូវលំដាប់នៃទី, -នូវទីជាលំដាប់, -នូវឋានន្តរ, -នូវឋានន្តរស័ក្តិ, មានឋានន្តរស័ក្តិដល់ហើយ។

ឋិត គុ. [ហ + ត, អានៃហ>ឥ] បិតនៅហើយ, តាំងនៅហើយ, ឈរនៅហើយ។ -**កាល** បុំ. កាលនៃ....តាំងនៅហើយ។ -**ភេទ** បុំ. ព្រានប្រមង់អ្នកឈរនៅហើយ, ព្រានសំណាញ់អ្នកឈរនៅហើយ។ -**ក្ខណ** បុំ. ខណ:នៃ....តាំងនៅហើយ, -ឈរនៅហើយ។ -**ដ្ឋាន** នបុំ. ទីនៃ....តាំងនៅហើយ, ... ។ -**ត្ត** នបុំ. ភាវ:នៃ... ជា

....តាំងនៅហើយ។ -**ទុព្ឋលរុក្ខសទិស** គុ. ប្រាកដស្មើដោយដើមឈើមានកម្លាំងគឺទោសប្រទូស្ត (មានកម្លាំងថយ, មានកម្លាំងខ្សោយ) តាំងនៅហើយ។ -**ឋិសិន្ធដ្ឋានាទិ** គុ. (ទី) មានទីនៃខ្លួនឈរហើយនិងទីនៃខ្លួនអង្គុយហើយជាដើម។ -**បុត្ត** បុ. បុត្រអ្នកតាំងនៅហើយ។ -**បុរិស** បុ. បុរសអ្នកឈរនៅហើយ។ - **ភាវ** បុ. ភាវៈនៃ.....ជា...តាំងនៅហើយ។ -**មជ្ឈន្តិក** បុ. សម័យនៃព្រះអាទិត្យប្រព្រឹត្តទៅក្នុងទីពាក់កណ្តាលតាំងនៅហើយ, វេលាថ្ងៃត្រង់តាំងនៅហើយ។ -**សរីរ** គុ. អ្នកមានសរីរៈតាំងនៅហើយ។

ឋិតក គុ. [ឋា + ត + ក-ស.] អ្នកឋិតនៅ, អ្នកឈរនៅ, វិ. **ឋិដ្ឋតីតិ>ឋិតោ, ឋិតោ ៦ឥ> ឋិតកោ**។

ឋិតិ ឥ. [ឋា + តិ, អានៃឋា>ឥ] កិ.ឋិតនៅ, កិ.តាំងនៅ (ដូច**ឋាន**), ការរស់នៅ (ដូច**ជីវិត**) វិ. **ឋានំ>ឋិតិ**, សព្ទនេះជាអត្ថនៃឋានសព្ទ។ - **ភាវ** បុ. ភាវៈនៃកិ.តាំងនៅ។

ឋិតិក គុ. [ឋា+តិ+ក-ស.] លំដាប់, ជាលំដាប់ (តាមទម្លាប់ថាអ្នកកាន់បញ្ជី), វិ. **ឋាបនំ>ឋិតិ , ឋិតិ ៦ឥ>ឋិតិកា**, (**ឋិតិកាតិ បដិបាដិ**) ។ យ. វិ. ។

ឋានាទិ គុ. [ឋាន + អាទិ] ឥរិយាបថមានកិ.ឈរជាដើម, វិ. **ឋានំ អាទិ យស្ស សោ >ឋានាទិ**។

ឋេ ធា. ១-**សទ្ធសទ្ធាតេសុ ឋីយតិ** "ចេញសំឡេង, ប្រហារ, រួមគ្នា" ភូ. ។
២- **ភេឋនេ ឋាយតិ** "ចង, រុំ, ជូត, ព័ទ្ធព័ន្ធ" ភូ. ។

ឧ

ឧដ្ឋ	គុ.	[ឧស + ត>ឧដ្ឋ] គឺ....ខាំហើយ, -ចឹកហើយ។
ឧបិ	ធា.	**សង្ឃាតេ ឆាបេតិ ឆាបយតិ** "សម្លាប់, ប្រហារ, រួមគ្នា,...″ ចុ. ។
ឧយ្ហនភាវ	បុ.	[ឧយ្ហន + ភាវ] ភាវ:គឺកិ.ដុត, -កិ.ឆេះ (ប្រើជា «**ឧយ្ហន**... » ក៏មាន។
ឧយ្ហនវស	បុ.	[ឧយ្ហន + វស] អំណាចនៃកិ.ឆេះ, -កិ.ដុត, -កិ.រោលរាល។
ឧយ្ហន្ត	គុ..	[ឧហ + យ + អន្ត] កាលដុត, កាលឆេះ, កាលរលាក។
ឧយ្ហន្ត	គុ.	[ឧហ + អ + អន្ត] កាលដុត, កាលឆេះ។
ឧយ្ហមាន	គុ.	[ឧហ + យ + មាន] គឺភ្លើងកាលឆេះ, -កំពុងឆេះ។ -**ឆ្ពេហ** នបុ. ផ្ទះគឺភ្លើងកំពុងឆេះ។
ឧយ្ហរេ	កិ.	[ឧហ + យ + តិ-រ. ឬអន្តិ-រ.] គឺភ្លើងរមែងឆេះ, គឺ.... ដុត។
ឧយ្ហិតុំ	អ.	[ឧហ + យ + ឥ-អា. + តុំ] ដើម្បីឆេះ, ដើម្បីរលាក។
ឧហតិ	កិ.	[ឧហ + អ + តិ-រ.] រមែងឆេះ, ដុត, រលាក។
ឧហតុ	កិ.	[ឧហ + អ + តុ-ប.] ចូរឆេះ, ចូរដុត, ចូររលាក។
ឧហិត្វា	អ.	[ឧហ + ឥ-អា. + ត្វា] ដុតហើយ ..... ។
ឆាក	បុ.	អន្លក់, បន្លែ (ដូច**សាក**) ។
ឆាហ	បុ.	[ឧហ + ណ] សេចក្តីក្តៅក្រហាយ, សេចក្តីរោលរាល, សេចក្តីអន្ទះអន្ទែង។
ឆាហក	គុ.	[ឧហ + ណ្ឍ] អ្នកដុត, ភ្លើង, ភ្លើងឆេះ។
ឌិ	ធា.	១-**ឍេហាសគតិយំ គមនមត្តេ ច ឌេតិ ឌយតិ ឌ្ឍេតិ** "ហោះ, ហើរ, ទៅព្ងដ៏អាកាស, ទៅ, ប្រព្រឹត្តទៅ, ដល់" ចុ. ។ **ឌេហ្ហណោ** កិ. គុ. "កាលហោះទៅ, កំពុងហើរទៅ" អា. **ឌ្ឍេ សកុណា ឌេហ្ហណា** -**ស**. ។ ២- **ខិបនឌ្ឍនេសុ ឌេតិ ឌ្ឍេតិ** "ផ្សាយទៅ, បោះទៅ, ហើរទៅ, ហោះទៅ, ឡើងទៅ" ភូ. ។ **បាសណ្ឌ** បុ. លទ្ធិ៣៤និងទិដ្ឋិ ៦២ហៅថាបាសណ្ឌោបោះទៅនូវលទ្ធិនិងទិដ្ឋិខ្ពស់។
ឌិបិ	ធា.	**សង្ឃាតេ ឌេបេតិ ឌេបយតិ** "សម្លាប់, ប្រហារ, រួមគ្នា" ចុ. ។
ឌំសិ	ធា.	**ឌំសនេ ឌំសតិ** "ចឹក, ខាំ, ចោះ, ចុច" (សត្ត) ភូ. ។ **ឌំស** បុ. "របោម , ខាំឬចោះ" ។

ឌី ធា. **គតិយំ ឌីយតិ ឌេហនោ ឌីនោ** "ទៅ, ដល់, ប្រព្រឹត្តទៅ" ទិ. ។

ឌំសន នបុં. [ឌំស + យុ] កិ.ចឹក, ជាទីចឹក, -ខាំ, -ទិច។ -**ដ្ឋាន** នបុំ. ទីជាទីចឹក, ... ។ -**ភយ** នបុំ. ខ្លាចអំពីកិ.ចឹក, ភ័យអំពីកិ.ខាំ។

ឌំសាបេតិ កិ. [ឌំស + ណាបេ + តិ-វ.] ញ្ជាំង....ឲ្យចឹក, -ឲ្យខាំ។

ឌំសាបេត្វា អ. [ឌំស + ណាបេ + ត្វា] ញ្ជាំង..... ឲ្យចឹកហើយ, -ឲ្យខាំហើយ។

ឌំសាបេន្ត គុ. [ឌំស + ណាប + អន្ត] កាលញ្ជាំង....ឲ្យចឹក, -ឲ្យខាំ។

ឌំសិ កិ. [ឌំស + អ + ណ្យ-អជ្ជ. + ស-អា.] ចឹកហើយ, ខាំហើយ។

ឌំសិតុំ អ. [ឌំស + ឥ-អា. + តុំ] ដើម្បីចឹក, -ខាំ។

ឌំសិត្វា អ. [ឌំស + ឥ-អា. + ត្វា] ចឹកហើយ, ខាំហើយ។

ឌំស បុំ. សត្វរបោម (ដូច **បិន្ត្ថលមក្ខិកា**)

ឌំហ គុ. [ឌហន្ត + សិ-វ., ជ្ជាស់ន្ត + សិ-វ.>អំ] កាលដុត, កាលឆេះ។

ណ

ណាទិ គុ. បច្ច័យមាន **ណ**ជាដើម, សព្ទនេះជាអត្ថម្យ៉ាងនៃបច្ចយសព្ទ ។

ត

តក្ក បុ. សេចក្ដីត្រិះរិះ (ដូច **ឱតក្ក** ដូច **អប្ឍនា**)។ ទឹកដោះរាវជូរថ្លា (ដូច **មថិត**), (ទឹកដោះនេះគេលាយដោយទឹក៣ភាគទឹកដោះ១ភាគ) ។ ឈើមានស្លឹកនិងផ្លែមានរសជូរ (សណ្ដាន់) (ដូច **សុចិផល**) ។

តក្ករ បុ. [ត + ករ + អ] អ្នកធ្វើនូវពុទ្ធវចនៈនោះ, អ្នកធ្វើនូវកម្មនោះ, អ្នកធ្វើនូវ...នោះ , វិ. **តំ ករោតីតិ>តក្ករោ។** បុ. ចោរ, អ្នកលួច (ដូច **ថេន**) ។

តក្កសិល អ.ន. ក្រុងឈ្មោះតក្កសិលា។ -**គ្គាមិសត្ថវាហ** បុ. ឈ្មួញអ្នកទៅកាន់ក្រុងតក្កសិលា, ពាណិជទៅកាន់ក្រុងតក្កសិលា, ជនអ្នកនាំទៅនូវពួកអ្នកទៅកាន់ក្រុងតក្ក-សិលា (**សត្ថវាហ**<សត្ថ + វហ + ណ ជាវេវចនៈនៃ **ឱណិជ** និង **អាបណិក**) ។ -**ជាតក** នបុ. តក្កសិល-ជាតក, ជាតកគឺបណ្ឌិតកំណត់ដោយព្រះរាជាជាធំក្នុងក្រុងតក្កសិលា។ -**នគរ** នបុ. ក្រុងតក្កសិលា។ -**មគ្គ** បុ. ផ្លូវជាទីទៅកាន់ក្រុងតក្កសិលា។ -**រជ្ជ** នបុ. ភាវៈនៃ...ជាស្ដេចក្នុងក្រុងតក្កសិលា។

តក្កសិលា ឥ. ឈ្មោះទីក្រុងមួយ ។

តក្កាទិអម្ពិល នបុ. [តក្កាទិ + អម្ពិល] រសជូរមានទឹកដោះជូរជាដើម។

តក្ការី ឥ. ដើមគន្ធា (ដូច **ទេជយន្តិកា**) ។

តក្ការ នបុ. របស់ដែលកើតហើយក្នុងកាលនោះ (ដូច **តទាតុ**) ។

តក្ការ នបុ. ក្រវាញ (ដូច **ភោលក**) ។

តក្ខ ធា. ១- **ភាសាយំ តក្ខេតិ តក្ខយតិ** "ពោល, និយាយ" ចុ. ។
២- **តបនេ** (**សំវរណេ**) **តក្ខតិ** "សង្រ្ដេម, រារាំង" ភ្វ. ។
៣- **ឱតក្ខេ តក្ខេតិ ឱតក្ខេតិ តក្ខយតិ ឱតក្ខយតិ** "ត្រិះរិះ, ឆ្ងៃគ្នាន់, គិតលើកចិត្ដកាន់អារម្មណ៍" ចុ. ។ **តក្ខោ ឱតក្ខោ** បុ. "តម្រិះ, គំនិត" ។ ក្នុងអភិធម្ម លោកបានពោលសព្ទជាវេវចនៈនៃ **តក្ក** នោះ៖ **តក្ខោ ឱតក្ខោ អប្ឍនា ញ្ឍប្ឍនា ចេតសោ អតិនិវេបនា** -ស. ។

តកិ ធា. ១- **ហសនេ តកតិ** "សើច" ភ្វ. ។
២- **ឥច្ឆជីវនេ តឆ្ឆតិ អាតឆ្ឆតិ** "រស់នៅដោយលំបាក, ឈឺ, ចុកចាប់, ចាក់ដោត" រុ. **អាតង្ខោ** បុ. "រោគ, ជំងឺ" ។ សព្ទជាវេវចនៈ៖ **អាតង្ខោ អាមយោ រោគោ ញ្ឍាធិ អាពាធោ គទោ រុជា អកល្ល គេលញ្ញ** -ស. ។

តគរ នបុ. [តគិ + អរ] ក្រស្នានិងចន្ទន៍, ក្លិននៃក្រស្នានិងចន្ទន៍។ -**ចន្ទន** នបុ. ក្រស្នានិងចន្ទន៍, ក្លិននៃក្រស្នានិងចន្ទន៍។ -**ចន្ទនី** ឥ. ក្រស្នានិងចន្ទន៍, ក្លិននៃក្រស្នានិងចន្ទន៍។ -**មល្លិកា** ឥ. ក្រស្នានិងក្លាំពាក់, ក្រស្នានិងម្ជិះ, ក្លិននៃក្រស្នានិងក្លាំពាក់។ -**សិខិប្បច្ចេកពុទ្ធ** បុ. ព្រះបច្ចេកពុទ្ធឈ្មោះតគរសិខី។

តគ្ឃ និ. ឯកំសត្ថវាចក:និបាតប្រាប់អត្ថគឺចំណែកមួយប្រៃថាដោយពិត, ចូរមើលអញ្ញទត្ថុខាងដើម។

តគ្ឃ ធា. **ចាលនេ តគ្ឃតិ** "រក្សា, ថែទាំ, ចិញ្ចឹម" ភូ. ។

តគិ ធា. **សំវរណគមនេសុ តគតិ តន្ត្តិ តន្ត្តនំ** "សង្រ្ទាម, រវាំង, ការពារ, ទៅ, ដល់, ប្រព្រឹត្តទៅ" ភូ. រុ. ។

តន្ត ធា. **ពន្ធនេ តន្ទេតិ តន្ទយតិ** "ចង, រឹតរួត,...″ ចុ. ។

តច បុ. [តច + អ] (អវយវ:) រក្សានូវសរីរ: (ស្បែក, សម្បក), វិ. **តចតិ ចាលេតីតិ> តចো**។ -**បញ្ចកកម្មដ្ឋាន** នបុ. កម្មដ្ឋានមានស្បែកជាគម្រប់៥, កម្មដ្ឋានមានប្រមាណ៥នៃស្បែក។ -**ឆ្ឌិច្ឆន្ន** គុ. គឺស្បែកបិទបាំងហើយ, ដែលបិទបាំងហើយដោយស្បែក។

តច បុ. ស្បែក (ដូច **ចម្ម**), សម្បកឈើ (ដូច **វក្ក**) ។

តចសារ បុ. ដើមឫស្សី (ដូច **វេណុ**) ។

តច្ឆ ធា. **ហឹសាយំ តច្ឆតិ** "បៀតបៀន" ភូ. ។

តច្ច គុ. ពិត (ដូច **សច្ច**) ។

តច្ឆក បុ. [តច្ឆ + ណ្ឍ] (ជន) អ្នកចាំងឬអ្នកឈូស (ជាងឈើ), វិ. **តច្ឆតិតនុ កវោតីតិ> តច្ឆកো**។

តច្ឆក បុ. ជាងឈើ (ដូច **វឌ្ឍកី**) ។

តច្ឆនី បុ. កាំបិតព្រា (ដូច **ឧាសី**) ។

តច្ឆន្ត គុ. [តច្ឆ + អ + អន្ត] កាលចាំង, កាលឈូស, កាលជម្រះ។

តច្ឆាបេត្វា អ. [តច្ឆ + ណាបេ + ត្វា] ញ៉ាំង...ឲ្យចាំងហើយ, -ឲ្យឈូសហើយ។

តច្ឆាបេសិ កិ. [តច្ឆ + ណាបេ + ណ្ស-អជ. + ស-អា.] ញ៉ាំង...ឲ្យចាំងហើយ, -ឲ្យឈូសហើយ, ឲ្យជម្រះហើយ។

តច្ឆិត កិ.,គុ. ចាំង, ឈូស (ដូច **តនុកត**) ។ របស់ដែលចាំងហើយឬឈូសហើយ ។

តច្ឆឺសុ កិ. [តច្ឆ + អ + ឧំ-អជ.] ចាំងហើយ, ច្រាសហើយ, ឈូសហើយ។

តច្ឆេត្វា អ. [តច្ឆ + ឯ + ត្វា] ចាំងហើយ, ច្រាសហើយ, ឈូសហើយ។

តច្ឆ ធា. **តនុករណេ តច្ឆតិ** "ឈូស, ចាំង, ច្រាស,បិត(ធ្វើឲ្យស្តើង) ភូ.។ **តច្ឆក** បុ. "ជាងឈូស, ជាងចាំង" ។ **តច្ឆនី** ឥ. "កាំបិត" ។

តចិ ធ. **សំវរណេ** (**រក្ខណេ**) **តចតិ** "សង្គ្រាម, រវាំង, រក្សា" ភ្ជ. ។ **តចោ** ប្ចុ. "ស្បែក, សម្បក" ។ **តចសារោ** ប្ចុ. "ឫស្សី" ។

តជ្ជនី ឥ. ម្រាមចង្អុលដៃ ។

តជ្ជារី ប្ចុ. មួយតជ្ជារីចំនួន៣៦អណុ ។

តជ្ជិស្សថ ក. [តជ្ជ + អ + ឥ-អា. + ស្សថ-ភ.] នឹងគម្រាម។

តជ្ជិត គុ. [តជ្ជ + ឥ-អា. + ត] គឺ...គម្រាមហើយ, -គ្រហឹម, -គម្ជរហើយ។

តជ្ជេត្វា អ. [តជ្ជ + ឯ + ត្វា] គម្រាមហើយ។

តជ្ជេន្ត គុ. [តជ្ជ + ឯ + អន្ត] កាលគម្រាម ... ។

តជ្ជេស្សតិ ក. [តជ្ជ + ឯ + ស្សតិ-ភ.] នឹងគម្រាម ,... ។

តដ្ឋ ធ. ១-**ភស្សនេ តដ្ឋតិ** "ធ្លាក់, របូត, ពោល, ភ្ជ្ជាស្ងាង" ភ្ជ. ។
២-**សន្ត្ជនេ តជ្ជេតិ តជ្ជយតិ សន្ត្ជេតិ សន្ត្ជយតិ តជ្ជិតោ មរណតយតជ្ជិតោ** "គម្រាម, សម្ជុត, កំហែង, ជម្លាប, បន្ទាច" ចុ. ។ **តជ្ជនី** ឥ. "ចង្អុលដៃ" ។ សព្ទដែលប្រែថាម្រាមដៃទាំង៥ៃ **អङ្គុដ្ឋោ** "មេដៃ" **តជ្ជនី** "ចង្អុលដៃ" **មជ្ឈិមា** "ម្រាមដៃ" **អនាមិកា** "នាងដៃ" **កនិដ្ឋា** "ក្មេងដៃ" (**សូចិ**) ។

តញ្ជ ធ. **ភតិយំ តញ្ជតិ** "ទៅ, ដល់, ប្រព្រឹត្តទៅ" ភ្ជ. ។

តដតដាយន្ត គុ. [តដតដ + អាយ + អន្ត] កាលប្រព្រឹត្តនូវសំឡេងថា **តដតដ:**។

តដតដាយមាន គុ. [តដតដ + អាយ + មាន] កាលប្រព្រឹត្តនូវសំឡេងថា **តដតដ:**។

តដ ប្ចុ. ជ្រោះភ្នំ (ដូច **បបាត**), ច្រាំងទន្លេ, ត្រើយទន្លេ, ឆ្នេរទន្លេ (ដូច **តីរ**) ។

តដ ធ. **ឧស្សយេ** (**អវកេហេ**) **តដតិ** "ឡើងខ្ពស់,..." ភ្ជ. ។ **តដ** ប្ចុ. "ជ្រោះ" ទីធ្លាក់ចុះនៃភ្នំ។ **តដ** នប្ចុ. តដីឥ. "ឆ្នេរ, ច្រាំង" ។ **គិរិតដ** "ជ្រោះភ្នំ" ។ **នទីតដំ** ឬ **នទីតដោ** "ឆ្នេរស្ទឹង" ។

តឌ ធ. **ភាឍ្ឍនេ តណ្ហតិ ឱតណ្ហតិ** "គោះ, វាយ, ប្រហារ" រុ. ។ **ឱតណ្ហោ** ឥ. "សម្ដីគោះលេង, ពាក្យពោលលេងឥតប្រយោជន៍" ។

តណ្ហុល ប្ចុ. អង្ករ។ -**ភណ្ឌមត្ត** គុ. មានអង្ករបាក់ជាប្រមាណ, មានចុងនៃអង្ករជាប្រមាណ។ -**ទោណ** នប្ចុ. ទោណ:នៃអង្ករ, អង្ករមានទោណ:ជាប្រមាណ។ -**នាឡិមត្ត** គុ. វត្ថុត្រឹមតែនាឡិនៃអង្ករ, អង្ករមាននាឡិជាប្រមាណ។ -**នាឡិ** ឥ. នាឡិនៃអង្ករ, នាឡិដ៏ពេញដោយអង្ករ។ -**អនិបាតេយ្ យ** នប្ចុ. វត្ថុជាប្រយោជន៍ក្នុងផ្លូវមានអង្ករជាដើម, ស្បៀងមានអង្ករជាដើម។

តណ្ហុលីយ ប្ចុ. ម្រះព្រៅ,សព្ទនេះជាអត្ថនៃមារិសសព្ទ។

តណ្ហុលេយ្ យ ប្ចុ. ម្រះព្រៅ (ដូច **អប្ប្ យមារិស**) ។

តណ្ហាក្ខយ បុ. [តណ្ហា + ខយ] ធម៌ជាទីអស់ទៅនៃតណ្ហា, វិ. **តណ្ហានំ ខយោ**> **តណ្ហាក្ខយោ** (**តណ្ហាក្ខយ**បើជាឈ្មោះរបស់មគ្គ ត្រូវប្រែថា ជាគ្រឿងអស់ទៅនៃតណ្ហា, ជាឈ្មោះរបស់ផលត្រូវប្រែថា សេចក្ដីអស់ទៅនៃតណ្ហា, ជាឈ្មោះរបស់និព្វានត្រូវប្រែថា ជាទីអស់ទៅនៃតណ្ហា)។ -**អន្ត** បុ. ទីបំផុតនៃធម៌ជាទីអស់ទៅនៃតណ្ហា។ -**រត** គុ. អ្នកត្រេកអរហើយក្នុងធម៌ជាទីអស់ទៅនៃតណ្ហា។

តណ្ហាក្ខយ បុ. ព្រះនិព្វាន (ដូច**និរោធ**) ។

ថោមិ	ធា.	**សិលាឃាយំ ថោមេតិ ថោមយតិ ថោមិតោ ថោមនា**" សរសើរ, ស្ងើច" ។

ទ

ទករក្ខស បុ. [ទក + រក្ខ + ស] យក្សជាដែនរក្សានូវខ្លួនក្នុងទឹក (នៃជន) ឬ បិសាចអ្នករក្សានូវទឹក (អារក្សទឹក), បិសាច ឬ ខ្មោចទឹក), វិ. **ទកេ រក្ខន្តិ អត្តានំ ឯតស្មា-តិ>ទករក្ខសោ**, **ទកំ រក្ខតីតិ វា> ទករក្ខសោ**។ -**ការ** បុ. កាលនៃ... ជាអារក្សទឹក, -ជាបិសាចអ្នករក្សានូវទឹក, -ជាខ្មោចទឹក។

ទកសីតលិក នបុ. ស្ពន្ធ, ចង្កុលណ៏ (ដូច**សោគន្ធិកំ**) ។

ទក្ខិណ គុ. នបុ. ខាងស្តាំ, ខាងត្បូង, ទាន (**កម្មផលំ សទ្ធហិត្វា ទាតព្ពទានំ**) ។ -**អំសកូដ** បុ. ចង្កាយនៃស្មាខាងស្តាំ។ -**កណ្ណសោត** នបុ. ប្រហោងនៃត្រចៀកខាងស្តាំ។ -**អក្ខি** នបុ. ភ្នែកខាងស្តាំ។ -**ចក្ក**ាឡ**មុខ**ាឡ**ន្ត** ឥ. កណ្តាប់នៃមាត់នៃចក្កវាឡក្នុងទិសខាងត្បូង។ -**ទិសា** ឥ. ទក្ខិណទិស, ទិសខាងត្បូង។ -**ទ្វារ** នបុ. ទ្វារខាងត្បូង។ -**នាសិកា-សោត** នបុ. ប្រហោងនៃច្រមុះខាងស្តាំ។ -**បស្ស** នបុ. ខាងខាងស្តាំ, ចំហៀងខាងស្តាំ។ -**ចាទតល** នបុ. ផ្ទៃនៃជើងខាងស្តាំ។ -**ភិត្តិ** ឥ. ជញ្ជាំងខាងត្បូង, ជញ្ជាំងក្នុងទិសខាងត្បូង។ -**ហត្ថតល** នបុ. ផ្ទៃនៃដៃខាងស្តាំ។ -**ហត្ថ** បុ. ដៃខាងស្តាំ។ -**ហត្ថបស្ស** នបុ. ខាងនៃព្រះហស្តខាងស្តាំ, ចំហៀងនៃ..... ។

ទក្ខិណាត្ថិ បុ. ទក្ខិណេយ្យគ្គិភ្លើងបានខាងបុគ្គលដែលគួរទទួលនូវទាន ។

ទក្ខិណាយន នបុ. រដូវជាទីដើរទៅកាន់ទិសខាងត្បូងនៃព្រះអាទិត្យ ។

ទក្ខិណុត្តរទ្វារ នបុ. [ទក្ខិណ + ឧត្តរ + ទ្វារ] ទ្វារខាងត្បូងនិងទ្វារខាងជើង, ទ្វារមានក្នុងទិសខាងត្បូងនិងទ្វារមានក្នុងទិសខាងជើង។

ទក្ខិណេយ្យ គុ. [ទក្ខិណា + ណេយ្យ] អ្នកគួរនូវទក្ខិណាទាន, អ្នកគួរ (ដើម្បីទទួល) នូវវត្ថុមានបាយជាដើមគឺបុគ្គលគប្បីឲ្យ (ទក្ខិណេយ្យបុគ្គល), វិ. **ទាតព្ពាតិ>ទក្ខិណា**, **តំ អរហតីតិ>ទក្ខិណេយ្យោ** (ទក្ខិណា<ទា + ក្ខិណ + អា-ឥ.) អ្នកគួរនូវទានគឺបុគ្គលគប្បីជឿនូវផលនៃកម្ម ហើយឲ្យ, មួយទៀតអ្នកគួរនូវធម្មជាតិជាហេតុចម្រើនដោយសម្បត្តិតាមបំណង (នៃសត្ត), វិ. **កម្មផលំ សទ្ធហិត្វា ទាតព្ពទានំ > ទក្ខិណា**, **ទក្ខន្តិ ឥឌ្ឍន្តិ សត្តា ឯតាយ យថាធិប្បេតាហិ សម្បត្តីហីតិ វា>ទក្ខិណា**, **តំ អរហតីតិ>ទក្ខិណេយ្យោ** (ទ$\bar{\text{ក}}$ + ឥណ + អា-ឥ.) ។ -**បុគ្គល** បុ. បុគ្គលអ្នកគួរនូវទក្ខិណាទាន, បុគ្គលជាទក្ខិណេយ្យ:, ... ។ -**សម្ឆា** ឥ. កិ.ដល់ព្រមដោយ

ទក្ខិណេយ្យបុគ្គល, សម្ផទាគឺទក្ខិណេយ្យបុគ្គល។

ទក្ខិណោទក នបុં. [ទក្ខិណ+ឧទក] ទឹកគឺបុគ្គលគប្បីឲ្យដើម្បីទានសម្បត្តិជាគ្រឿងចម្រើន, ទឹកជាគ្រឿងចម្រើន (ទឹកស្ពោទក), វិ. **ទក្ខន្តិ ឯតាយាតិ> ទក្ខិណា, ទក្ខិណាយ ទានត្ថំ ឧទកំ>ទក្ខិណោទកំ**។ -**ឋ្យតិដ្ឋាន** នបុំ. កិ. ញ្ចុំងទក្ខិណោទក:ឲ្យតាំងនៅចំពោះ, កិ.តាំងទុកចំពោះនូវទឹកស្ពោទក។

ទក្ខិស្សតិ កិ. [ទិសិ>ទក្ខ + អ + ឥ-អា. + ស្សតិ-ភ.] នឹងឃើញ។

ទក្ខេមុ កិ. [ទិសិ>ទក្ខ + អ + ឯយ្យាម-ស., ឯយ្យាម>ឯមុ] គប្បីឃើញ។

ទក្ខ ធា. ១-**ឍុឌ្ឍ្ឌ្ឍ្ឌ្ឍ្

-**ភោដិ** ឥ. ចុងនៃឈើច្រត់, ទីបំផុតនៃឈើច្រត់។ -**ឥដ្ឋិត** គុ. អ្នកគឺអាជ្ញាគម្រាមហើយ, អ្នកគឺ....គម្រាមហើយដោយអាជ្ញា។ -**ទីបក** នបុં. ប្រទីបមានដង។ -**ឋាយន** គុ. អ្នកមានឈើច្រត់ជាទីប្រព្រឹត្ត ទៅក្នុងខាងមុខ។ -**ពលិអណ្ណ** ទិគុ. (កម្ម) មានកំណាត់ឈើនិងពលី (គ្រឿងបូជា) និងអាជ្ញាជាដើម។ -**ឥត្ថឥណ្ណូនា** ឥ. កថាជាគ្រឿងពណ៌នានូវទណ្ឌវគ្ម។ -**ហត្ថគោបាលកសទិស** គុ. ប្រាកដស្មើដោយបុគ្គលអ្នករក្សានូវគោមានដំបងក្នុងដៃ, ដូចជាបុរសអ្នកឃ្វាលនូវគោមានដំបងក្នុងដៃ។

ទណ្ឌក បុં. [ទណ្ឌ + ក-ស.] កំណាត់ឈើ, ឈើច្រត់, ដំបង, ដង, បង្គង។ -**ឆុបជ្ជ**នបុំ. ផ្ទៃតនៃឃ្ម៉ុទាំងបង្គង, ផ្ទៃតនៃឃ្ម៉ុមួយអន្លើដោយបង្គង, សម្ប្រកនៃ..... ។

ទណ្ឌនីតិ បុં. ទណ្ឌនីតិសាស្ត្រ ។

ទណ្ឌាភិហត គុ. [ទណ្ឌ+អភិហត] គឺដំបងបៀតបៀនចំពោះហើយ, គឺ...សំពងហើយដោយដំបង, គឺបុគ្គលគោះហើយដោយដំបង, គឺ...បៀតបៀនចំពោះហើយ ដោយដំបង។

ទណ្ឌ ធា. **ទណ្ឌវិនិបាតនេ ទណ្ឌេតិ ទណ្ឌយតិ** "ធ្វើទោស, ផ្តន្ទាទោស, ទូន្មាន, ពិន័យ, វាយ, សំពង" ចុ. ។ **ទណ្ឌោ** បុំ. "ដំបង, ឈើច្រត់, អាជ្ញា, ការធ្វើទោស, ទូន្មាន, ពិន័យ, វាយ, ឧបាយសម្រាប់ផ្ចាញ់សត្រូវ, ដើមនៃឈូកជាដើម" ។

ទត្ត បុំ,អ.ន. ឈ្មោះទត្ត:។

ទត្តុ បុំ. បុគ្គលលូងខ្លៅ (ដូច **ពាល**) ។

ទន្ទរិ បុំ. ស្គរម្យ៉ាង, ស្គរមានត្រចៀកជាស្គរធំ ។

ទន្ទុរ បុំ. សត្វកង្កែប (ដូច **មណ្ឌូក**) ។

ទធि នបុំ. [ធា-ធា + ឥ] ទធि, ទឹកដោះជូរ (វិ. **ឃតមាទធាតីតি>ទធि**) ។ ម្យ៉ាងទៀត (ទធि<ទធ + ឥ = វត្ថុទ្រទ្រង់នូវសេចក្តីត្រេកអរនៃជន, វិ. **ជនស្ស តុដ្ឋึ ទធតេតি >ទធि**) ។ -**តេលកជុកភណ្ឌ** នបុំ. ទធិនិងប្រេងនិងភណ្ឌ:ដ៏ហឹរក្តៅ, ទធិនិងប្រេងនិងគ្រឿងទេស។ -**ភាជន** នបុំ. ភាជន៍សម្រាប់ដាក់នូវទធि, ភាជន៍ដ៏ពេញដោយទធि, ដបដ៏ពេញដោយទធि។

ទធिមណ្ឌ នបុំ. ទឹកដោះរាវថ្លា (ដូច **មត្ថុ**) ។

ទធ ធា. ១-**ឆារណេ ទធតি ទហតি** "តាំងទុក, ទ្រទ្រង់ទុក" ភ្វ. ។ **ទធि** ឥ. "ទឹកដោះខាប់"។ **សមាទហាតព្ពំ** កិ.គុ. "គប្បីតាំងទុកដោយល្អ" (សំ+អា+ទធ+តព្ព) អា. **ចិត្តំ សមាទហាតព្ពំ** "គប្បីតាំងចិត្តទុកដោយល្អ" -ស. ។ ២-**អសីយចារេ ទន្ធតি ទន្ធោ** "យឺតយូរ, លូង"

រុ.។ **ទន្ធប្បញ្ញោ** គុ. "មានប្រាជ្ញាយឺតយូរ, លង់, ខ្លៅ" ។

ទនុ	ឥ.	មាតានៃអសុរ (**ទានវមាតា**) ។
ទន្ត	បុ.	[ទា + អន្ត] អវយវ:ជាគ្រឿងកាត់ផ្តាច់នូវចំណី (ធ្មេញ, ភ្លុក), វិ. **ទាយតិ ភក្ខមនេនាតិ>ទន្តោ**។
ទន្តកដ្ឋ	នបុ.	[ទន្ត + កដ្ឋ] ឈើសម្រាប់ជម្រះនូវធ្មេញ (ឈើស្នន់), វិ. **ទន្តសោ ធនំ កដ្ឋំ> ទន្តកដ្ឋំ**។ -**កិលិដ្ឋ** គុ. ដ៏សៅហ្មងដោយឈើស្នន់។
ទន្តច្ឆទ	បុ.	រិមបបូរមាត់ (ដូច **ទន្តាវរណ**) ។ សព្ទនេះជាអត្ថនៃ **អធរ**សព្ទ ។
ទន្តឆាវន	បុ.	ដើមគគីរ, ពពេល (ដូច **ខទិរ**)
ទន្តន្តរ	នបុ.	[ទន្ត + អន្តរ] ចន្លោះនៃធ្មេញ, រវាងនៃធ្មេញ។ -**គត** គុ. ទៅហើយក្នុងចន្លោះនៃធ្មេញ, បិតក្នុងចន្លោះនៃធ្មេញ។
ទន្តបុរនគរ	នបុ.	[ទន្តបុរ + នគរ] ក្រុងឈ្មោះ **ទន្តបុរ:**។
ទន្តបោណ	បុ.	ឈើស្នន់ (ដូច **ទន្តកដ្ឋ**)
ទន្តភាវ	បុ.	[ទន្ត + ភាវ] ភាវ:នៃ...ជាអ្នកទូន្មានហើយ (**ទន្ត**គុ. <ទមិ + ត = ទូន្មានហើយ, អ្នកមានឥន្ទ្រិយទូន្មានហើយ) ។
ទន្តភូមិ	ឥ.	[ទន្ត + ភូមិ] ភូមិនៃបុគ្គលអ្នកមានខ្លួនទូន្មានហើយ។
ទន្តវលយ	នបុ.	[ទន្ត + វលយ] កងជាវិការ:នៃភ្លុក (កងភ្លុក) ។
ទន្តសដ្ឋ	បុ.	ដើមក្រូចឆ្មារ (ដូច **ជម្ពីរ**)
ទន្តសម្បត្តិ	ឥ.	[ទន្ត+សម្បត្តិ] កិ.ដល់ព្រមដោយធ្មេញ, -នៃធ្មេញ, សម្បត្តិគឺធ្មេញ។
ទន្ធាវរណ	នបុ.	[ទន្ត + អា + រ + យុ] អវយវ:ជាគ្រឿងបិទនូវធ្មេញ, (រិមមាត់, បបូរមាត់), វិ. **ទន្តេ អាវរតិ ឆាទយតិ ឯតេនាតិ>ទន្ធាវរណំ**។
ទន្ធិ	ឥ.	ការទូន្មាន (ដូច **ទមថោ**)
ទន្ធី	បុ.	សត្វដំរី (ដូច **ឥភ**)
ទន្ធ	គុ.	[ទធ + អ, ចុះនិ-អា.] លង់, ខ្លៅ, យឺតយូរ។ -**តា** ឥ. ភាវ:នៃ..ជាអ្នកខ្លៅ។ - **ឫញ្ញ** គុ. អ្នកមានប្រាជ្ញាខ្លៅ។ -**ភិក្ខុ** បុ. ភិក្ខុខ្លៅ។ -**រាជ** បុ. ព្រះរាជាខ្លៅ។
ទប្ប	បុ.	**ភញ្ជក** (ដូច **អាទាស**)
ទបិ	ធាតុ	**ហាសេ ទប្ប**តិ "សើច" ទិ. ។
ទធ	ធាតុ	**ភតិយំ ទធ**តិ **ទ**ញ្ជ**តិ** "ទៅ, ដល់, ប្រព្រឹត្តទៅ" ភ្វ. ទិ. ។
ទព្ព	បុ.	បុគ្គលគួរដល់អរហត្តផល (**ឥ**ម**ុ**ត្ត**ារ**ហ), បុគ្គលមានគុណជាទីអាស្រ័យ (ដូច **គុ**ណ**ាធ**ារ), អ្នកប្រាជ្ញ (ដូច **ពុ**ធ),(អ.ន.) ឈ្មោះ **ទ**ព្ព:។ នបុ. ទ្រព្យ (ដូច **ឥ**ត្ត), កំណាត់ឈើ (ដូច **ទ**ារ**ុ**), ស្ស្ងរ**ាំ**ង, ស្ពារ (ដូច **ក**ុ**ស**), ។

ទព្ធវិទ្ធសុ បុ. អ្នកប្រាជ្ញ (ដូច **ពុទ្ធ**) ។

ទព្ធិមុខទ្ធិជ បុ. សត្វអាដ (ដូច **អាជ**) ។

ទព្ធសម្ភារ បុ. [ទព្ធ + សម្ភារ] គ្រឿងទព្ធសម្ភារ:, វត្ថុជាគ្រឿងទំនុកបម្រុងគឺទព្ធ:, គ្រឿងប្រុង (ទព្ធ<ទុ + អព្ធ = សព្ទនេះប្រើច្រើនយ៉ាងគឺវត្ថុ, របស់, របស់ដ៏សមគួរ, ទ្រព្យ, សម្បត្តិ, បញ្ញា, ឈើ, ដើមឈើ)។ -**អត្ថិក** គុ. អ្នកមានសេចក្ដីត្រូវការដោយទព្ធសម្ភារ:, -គ្រឿងប្រុង។

ទញ្ជិ , ទញ្ជី ឥ. [ទុ + ពិ + ណ្ឌ្ឍ + ពី] ប្រដាប់ជាគ្រឿងបំបែកនូវវត្ថុមានបាយជាដើម (រ៉ែក), វិ. **ឱទនាទីនិ អនេន ទារេន្តីតি>ទញ្ជិ, ទញ្ជី**។ -**ភណ្ណ** នបុ. ផ្ទៀងនៃរ៉ែក។ -**មត្ត** គុ. មានរ៉ែកជាប្រមាណ, ប៉ុនរ៉ែក។

ទពិ ធា. **សទ្ធេ ទម្ភតি** "ចេញសំឡេង, ពោល, ស្រែក" រុ. ។

ទភি ធា. ១-**សទ្ធេ ទម្ភតি** "ចេញសំឡេង, ពោល, ស្រែក" រុ. ។ ២-**ភយេ ទភេតি ទភយតি** "ខ្លាច, ភ័យ" ចុ. ។

ទម បុ. [ទមិ + អ] កិ.ទូន្មាន, ការបង្ហ្ងិល, ការបង្ហាត់, វិ. **ទមនំ>ទមោ**។ បញ្ញា, ការរក្សា, ការចាំ (ដូច **ឧបទាស**), សេចក្ដីអត់ធន់ (ដូច **ខន្តি**), ការទូន្មានឥន្ទ្រិយ, ការសង្រ្ងមឥន្ទ្រិយ (ដូច **ឥន្ទ្រិយសំវរ**) ។

ទមក បុ. អ្នកស៊ីដែល (ដូច **ទិយាសាទ**) ។

ទមថ បុ. [ទមិ + ថ] កិ.ទូន្មាន, ការបង្ហ្ងិល, ការបង្ហាត់, វិ. **ទមនំ>ទមថো**។

ទមន នបុ. [ទមិ + យុ] កិ.ទូន្មាន, កិ.បង្ហ្ងឹក, កិ. បង្ហាត់, វិ. **ទម្យតে>ទមនំ**។

ទមយំ គុ. [ទមយន្ត + សិ-រ., ផ្ទាស់ន្ត + សិ-រ.>អំ] កាលទូន្មាន,.. ។

ទមសច្ច នបុ. [ទម + សច្ច] ទម:និងសច្ច:, កិ.ទូន្មាននិងសេចក្ដីពិត។

ទមិឡមទ្ទន នបុ. [ទមិឡ + មទ្ទន] កិ.ញ្ចាំញ្ចីនូវព្រះរាជាឈ្មោះទមិឡ:, នូវទមិឡ។

ទមេតព្ព គុ. [ទមិ + អ, អ>ឯ + តព្ព] គឺ...គប្បីទូន្មាន, ... ។

ទមេតុំ អ. [ទមិ + អ + តុំ] ដើម្បីទូន្មាន, ... ។

ទម្ម បុ. សេចក្ដីកោង, ការបញ្ជោត, ការបោកប្រាស់, ការបំបាត់ (ដូច **ភ្ជ**) ។

ទម្មិ កិ. [ទា + អ + មិ-រ.] ឲ្យ។

ទម្ម បុ. ក្ងានគោស្ទារ, គោស្រករ, គោលួមទូន្មាន, លួមពង្រាប (ដូច **ទម្ពករ**) ។

ទម្ហ កិ. [ទា + អ + ម្ហា-អជ្ជ.] ឲ្យហើយ។

ទមិ ធា. **ភតিទមនេសុ ទមតি ទន្តো** "ទៅ, ដល់, ប្រព្រឹត្តទៅ, ទូន្មាន, ហាត់, ហ្ងឹកហ្ងឹន" ភូ. ។ កម្ម. **ទមីយតি ទម្យតে ទន្តো ទមិតো**។ ការិត. **ទមেតি ទមយតি**។ **ទមো** បុ. ភ. ន. "ការទូន្មាន,..." មានអត្ថន័យ៤យ៉ាងៃ

១/ ឥន្ទ្រិយសំវរ: គឺការសង្រ្ងមឥន្ទ្រិយមានចក្ខុឥន្ទ្រិយជាដើម បាលីថា **សច្ចេន ទន្តো ទមសា ឧបេតো**។

២/ ប្រាជ្ញា បាលីថា **យតি ទមា ចាតো**។ល។

		៣/ ឧបោសថសីលបាលីថា **ទានេន ទមេន សំយមេន សច្ចវជ្ជេន**។ ៤/ **ខន្តិ**, អំណាត់អត់ធន់បាលីថា **ទមូបសមេន** -ស. ។ **ទន្តិ** ឥ. **ទមនំ** នបុ. "ការទូន្មាន, ការពង្រាប, ការបង្វឹក។ **ទម្មោ** បុ. "គោស្នាវ, កូនគោដែលល្មមពង្រាប" (សូចិ) ។ **ទមកោ** បុ. "អ្នកស៊ីរបស់សំណាល់" =**ឱិយាសាទោ** (**សូចិ**)។
ទយា	ឥ.	សេចក្តីករុណា, សេចក្តីអាណិត (ដូច **ការុញ្ញ**) ។
ទយាលុ	គុ.	អ្នកមានសេចក្តីករុណាច្រើន (ដូច **សូរត**) ។
ទយិតា	ឥ.	ស្រី (ដូច **ឌារី**) ។
ទយិត	បុ.	សេចក្តីស្រឡាញ់, សេចក្តីស្និទ្ធស្នាលសេចក្តីគាប់ចិត្ត (ដូច **ឱិយ**) ។
ទយ	ធា.	**ទានគតិហឺសាទានរក្ខាសុ ទយតិ** "ឲ្យ, ទៅ, បៀតបៀន, កាន់យក, រក្សា,...″ ភូ. អា. **ឥជ្ជោ... ម៉ំសបេសឺ អាទាយ ទយេយ្យ** "ត្មាតពាំដុំសាច់គប្បីហើរទៅ" ។ **បុត្តេសុ មន្ទិ ទយេសិ** "ព្រះនាងមទ្រីទ្រង់គួរមេត្តាករុណាចំពោះព្រះរាជបុត្រទាំងឡាយ" -ស. ។ **ទយា** ឥ. "សេចក្តីមេត្តាឬករុណា, ការអនុគ្រោះ, សេចក្តីស្រឡាញ់ =**មេត្តា**=**ករុណា**, (**សូចិ**) ។ **ទយិតោ** គុ. "ដែលគួរកាន់យក, គួរប្រាថ្នាឬជាទីគាប់ចិត្ត" ។ **ទយិតា** ឥ. "ស្ត្រីសាមញ្ញ" ដែលគួររក្សាថែទាំដោយប្រុងប្រយ័ត្ន (សូចិ) ។ ឯ **ទយ** សព្ទនុះ តាមមតិ ស. សម្តែងទុកមកមានន័យ៥យ៉ាងៈ ១/ **ទាន** "ឲ្យ" គឺឲ្យអភ័យដល់សត្វទ. ។ ២/ **គតិ** "ទៅ" គឺទៅស្មើគ្នាក្នុងមនុស្សល្អនិងមនុស្សអាក្រក់។ ៣/ **ហឺសា** "បៀតបៀន" គឺដាស់តឿនអ្នកមានករុណាចិត្តឲ្យជួយដោះទុក្ខរបស់អ្នកដទៃ។ ៤/ **អាទាន** "កាន់យក" គឺលះបង់សុខផ្ទាល់ខ្លួនហើយទទួលយកសេចក្តីលំបាកហត់នឿយវិញ។ ៥/ **រក្ខ** "រក្សា" គឺរក្សាសត្វទ. ។
ទរ	បុ.	[ទរ + អ] សេចក្តីក្រវក់ក្រវាយ, វ. **ទរណំ**>**ទរោ**។សេចក្តីខ្លាច(ដូច **ភីតិ**) ។
ទរ	ធា.	១-**ភយេ ទរតិ** "ខ្លាច, ភ័យ, តក់ស្លុត" ភូ. ។ **ទរី** ឥ. "ច្រក, ជ្រោះ, អូរ" គួរឲ្យខ្លាច។ **ទរិសយា** គុ. "អ្នកដេកនៅក្នុងជ្រោះ" ។ ២-**ឱិទារណេ ទរតិ** "បំបែក, ទម្លាយ" ភូ. ។ អា. **ភូមឺ ទរតិ ភុជ្ជាណោ** "ចបកាប់ឬចបជីករមែងបំបែកដី" -ស. ។ ៣-**ទាហេ ទរតិ** "ក្តៅ, ឆេះ, ដុត, ក្រវល់ក្រវាយ" ភូ. ។ អា. **ភាយោ ទរតិ** "កាយរមែងក្តៅក្រហាយឬក្រវល់ក្រវាយ" ។ **ទរោ ទរថោ** បុ. "សេចក្តីក្តៅក្រហាយឬក្រវល់ក្រវាយ (ជាផ្នែកកាយក៏បានផ្នែកចិត្តក៏បានឬព្រោះកិលេស

ក៏បាន) ស. ។ អា. **ឱ៑ឥ ន្ធ្ងេ ឱ៑ឥ សោ ភ្ងេ ឱ៑ឥ ស ណ្ឌ្ងេ**... (ស្ងួចិ)។ ៤-**អ ន ១ អ ន ១ ន ១ ស ១ ១ ១

១០យ៉ាង។ -**សហស្សចក្ខុវាឡ-ទេវតា** ឥ. ទេវតាក្នុងចក្កវាឡ មានពាន់១០ជាប្រមាណ , ទេវតាក្នុងចក្កវាឡមួយហ្នឹន។ -**សហស្ស-មហាព្រហ្មបរិវារ** គុ. មានមហាព្រហ្មមួយហ្នឹនជាបរិវារ។ -**សហ-ស្សមូលក** គុ. មានមូលមានពាន់១០ជាប្រមាណ, មានទ្រព្យជាមូលមានពាន់១០ជាប្រមាណ, មានតម្លៃមួយហ្នឹន។ -**សហស្សីលោកធាតុ** ឥ. លោកធាតុមានពាន់១០ជាប្រមាណ, លោកធាតុមួយហ្នឹន។

ទសនច្ឆទ បុ. រ៉ាមបបូរមាត់ (ដូច **ទន្ត្ថាវរណ**) ។

ទសន បុ. ធ្មេញ (ដូច **ទន្ត**) ។

ទសន្តមត្ត គុ. [ទសា + អន្ត + មត្ត] គ្រាន់តែទីបំផុតនៃជាយសំពត់, ត្រឹមតែចុងនៃជាយ។

ទសពល បុ. ព្រះនាមព្រះពុទ្ធជាម្ចាស់។

ទសសតនយន បុ. ព្រះឥន្ទ, ទេវរាជមានព្រះនេត្រ១000 (ដូច **ទ្ទាសទ**) ។

ទសា ឥ. ជាយ, ជាយសំពត់។ស្រីអាក្រាត (ដូច **អ**ទ**ត្ថា**) ។

ទសិកសុត្ត នបុ. [ទសិក + សុត្ត] អំបោះជើងជាយ, អំបោះមានជាយ, អំបោះមានក្នុងជាយ។

ទស្សន នបុ. [ទិសិ + យុ] កិ.ឃើញ, កិ.សម្តែង, វិ. **ទ**ស្ស**ិ**យ**ត**េ>**ទ**ស្ស**ន**ំ។ -**អ**ត្ថ បុ. ប្រយោជន៍ដល់កិ.ឃើញ, ត្រូវការដល់កិ.ជួប។ -**ភ**យ នបុ. កិ. ខ្លាចអំពីកិ.ឃើញ, ភ័យអំពីការឃើញ។ -**ទ**ស បុ. អំណាចនៃកិ.ស ម្តែង។ -**ស្ស**ទ**ន**ស**ម**ុ**ល្ល**ប**ន**ប**រ**ិ**ភ**ោ**គ**ត**ា ឥ. ភាវ:នៃកិ.ឃើញ និងកិ.ស្តាប់និងកិ.និយាយរកនិងកិ.បរិភោគ (**ស**ម**ុ**ល្ល**ប**ន<សំ + ឧ + លប៊+យុ = កិ.ពោលទ្បើងព្រម, ការចរចា, ការនិយាយឆ្លើយឆ្លង) ។ -**អ**ាការ បុ. អាការ:គឺកិ.ឃើញ។ រូបារម្មណ៍ (ដូច **ទ**ិ**ដ្ឋ**) ។ សោតា-បត្តិមគ្ត (**អ**ាទ**ិ**ម**ត**្ត) ។ ញាណ, ភ្នែក (ដូច **អ**ក្ខ**ិ**) ។ សេចក្ដីប្រកាន់ (ដូច **ល**ទ្ធ**ិ**) ។ ការក្រទ្បេកមើល (ដូច **អ**ាណ**ោ**ក**ន**ំ) ។

ទស្ស**ន**ីយ**ត**រ គុ. [ទ**ស្ស**ន**ីយ** + **ត**រ] ជាអ្នកគឺបុគ្គលគួ**ស**ម**ិ**ល**ម**ើ**ល**ជ**ាង, -**ត**ឺ**ប**ុ**ត**្ត**ល**ត**ប**្ប**ី**ឃ**ើ**ញ**ដ**ោ**យ**ិ**ស**េ**ស។

ទស្ស**ន**ោ**ភ**ាស-**ម**ណ្ឌ**ល** នបុ. [ទ**ស្ស**ន+ឱ**ភ**ាស+**ម**ណ្ឌ**ល**] **ម**ណ្ឌ**ល**នៃ**ឱ**ភ**ាស**ជ**ាគ្ប**ឿ**ងស**ម**្ដ**ង។

ទស្ស**ិ**ត គុ. [ទ**ិ**ស**ិ** + **ត**-**អ**ា. + **ត**] **ត**ឺ....**ស**ម្ដ**ង**ហ**ើ**យ, -**ប**ង្ហ**ា**ញ**ហ**ើ**យ។ -**ន**ិ**យ**ាម បុ. ទ**ំ**ន**ង**ន**ៃ...**ត**ឺ....**ស**ម្ដ**ង**ហ**ើ**យ។ -**ឋ**ាទ**េ**ស បុ. ប្រ**ទ**េ**ស**ត**ឺ.... **ស**ម្ដ**ង**ហ**ើ**យ។

ទស**ិ** ធ. **ទ**ំ**ស**ន**េ ទ**ំ**ស**ត**ិ ว**ิ**ទ**ំ**ស**ត**ិ ទ**ំ**ស**េ**ត**ិ ទ**ិ**ស**យ**ត**ិ "ខ**ាំ**, ក**ាត**់, ទ**ំ**ព" ភ**ូ**. ចុ. ។ **ទ**ន្ត**ោ ទ**ំ**ស**ន**ោ** បុ. "ធ្ម**េ**ញ, ភ្ល**ុ**ក" ។ **ស**ូ**ច**ិ**ថ**ា **ទ**ន្ត**ោ** (<**ទ**ា+ អ**ន**្ត) **ว**ิ. **ទ**ាយ**ត**ិ **ภ**ก្ខ**ม**ន**េ**ន**ว**ាត**ิ ទ**ន**្ត**ោ**។

ទហាន បុ. ភ្លើង (ដូច**ជាវ**ក) ។

ទហរ គុ. [ទហ + អរ] ក្មេង, កំលោះ, ក្រមុំ។ -**ការ** បុ. កាលនៃ....នៅក្មេង, -នៅកម្លោះ។ -**ត** គុ. ក្មេងជាង, កម្លោះជាង។ -**ទហ** គុ. ក្មេងៗ, កម្លោះៗ, ។ -**ទារ**ក បុ. ទារកក្មេង។ -**ភិក្ខុ** បុ. ភិក្ខុកម្លោះ, -ក្មេង។ -**សាមណេ**ร បុ. សាមណេរកម្លោះ, -ក្មេង, ភិក្ខុកម្លោះនិងសាមណេរ។

ទហ បុ. ស្រះ (ដូច **អម្ពុជ**ក**ร**)

ទហ ធា. ១-**ឋ**ស្ម**ីក**ร**ណ ធ**ារ**ณ ច ទ**ห**ติ "ឆេះ, ដុត, ធ្វើឲ្យទៅជាផេះ, ទ្រទ្រង់, តាំងទុក"ភ.។ **ទห**ធាតុនេះជួនកាលផ្លាស់ជា **ឌห** វិញក៏មាន **ឌห**ติ បាលីថា **ឌห**ន្តํ ពาลมเญติ "រមែងអន្ទោលតាមនូវបុគ្គលពាលកំពុងឆេះ"។ កម្ម. **ទห្ยติ ឌห្ยติ**។ កិ. គុ. **ទห្ฆา** (ទ ហ+ต) ។ **ទห**ติ "ឆេះ" បាលីថា **ห**ค**ห**ณิ **ទห**ติ។ **ទห**ติ "ទ្រទ្រង់" បាលីថា **ส**ม**ํ ส**ตฺ**ถี ห**ยฺ**ริกํ ទห**ติ "តាំងស្រីនេះទុកជាជីដូន" -ส.។ ២-**ห**ึ**ส**ากุฆฺ**ฌี**สุ **ទห**ติ "ចៀតចៀន, ចម្រើន" ភ. ។

ទឍ្ឍ បុ. អ្នកទ័លក្រ, អ្នកកម្សត់ (ដូច **ទ**ីน) ។

ទឍ្ឍីก**ម្ម** នបុ. [ទ ឍ្ឍ + ក**ម**, ចុះ**ណ**-**ណ**.] ក.ធ្វើឲ្យមាំ, ក**ម**ដ៏**ម**ាំ។ -**ត្ថ** បុ. ប្រយោជន៍ដល់ក.ធ្វើឲ្យមាំ, ប្រយោជន៍ដល់ក**ម**ដ៏**ម**ាំ។ **ส**ព្ព**ន**ះ**ជ**ា**ត**ត្ថ**ន**ៃ **ส**ห**ชุ** **ส**ព្ព។

ទឍ្ឍ គុ. [ទ**ห** + ឍ្ឍ] **ม**ាំ, **ม**ាំ**ม**ួ**ន**, ខ្លាំ**ง**។ ២-ធាត់, ធំ, ថ្លោ**ส** (ដូ**ช** **ช**ู**ล**) ។ ៣-**ร**ឹ**ง**, **ร**ឹ**ง**រ**ส** (ដូ**ช** **ก**ฤ**ล**) ។

ទឍ្ឍ**ป**ร**ก**ฺ**ม** គុ. [ទ ឍ្ឍ + ป**ร**ก**ม**] អ្ន**ก**ម**ាน**ก.ឈ**ាน**ទ**ៅ**ក**ុ**ង**ខ**ាង**ម**ុ**ខ**ដ**ាំ**ม**, អ្ন**ก**ម**ាน**ព្យ**ាយ**ាម**ដ**ាំ**ม**, អ្ন**ก**ម**ាน**ส**េ**ច**ក**ី**ប្រ**ឹ**ង**ប្រ**ែ**ង**ដ**ាំ**ม**។

ទឍ្ឍ**ม**ิ**ต**ฺ**ต** បុ. **ม**ิ**ต**ฺ**ร**ส**ิ**ท**ธ**ส**ฺ**ส**ាล**ม**ាំ (ដូ**ช** **ส**ม**ฺ**ภ**ฺ**ต**) ។

ទឍ្ឍ**ว**ิ**ส**ฺ**ส**ฺ**ว**ส**ิ**ก គុ. [ទ ឍ្ឍ + **ว**ิ**ส**ฺ**ส**ฺ**ว**ส**ิ**ก] អ្ন**ก**ម**ាน**ส**េ**ច**ក**ី**ส**ฺ**ว**ิ**ท**ธ**ส**ฺ**ส**ាล**ដ**ាំ**ม**, អ្ন**ก**ប្ร**ก**ប**ដ**ោ**យ**ส**េ**ច**ក**ី**ส**ฺ**ว**ิ**ท**ธ**ส**ฺ**ส**ាล**ដ**ាំ**ม**។

ទឍ្ឍ**ก**ร**ณ** នបុ. [ទ ឍ្ឍ + ก**ร** + ยุ, ចុ**ណ**-**ណ**.] ក.ធ្វើ**ឲ**្យ**ม**ាំ។

ទា ធา. ១-**ទ**ាเ**ธ ទ**ាติ **ธ**ेติ "ឲ្យ, ផ្តល់, ប្រគ**ន**, ថ្វាយ, ជ**ួ**ន, ហុ**ច**" ភ. ។ **ទ**ាน**ํ** នបុ. "ទ**ាน**, **អ**ំ**ណ**ោ**យ**, ការ**ឲ**្យ, ការ**ប**ริ**ច**្ច**ค**, **ส**េ**ច**ก**ี**ប**ริ**ส**ุ**ท**ธ, ការ**ช**ម្រ**ះ**, ការ**ป**ូ**ช**ា**ท**េ**ว**ត**ា**, ការ**ก**ាត់, ការ**អ**ស់**ท**ៅ, **ส**ូ**ន**្ម**ท**ៅ, ប្រ**ช**ង**ด**ំ**ร**ី" ។ **ธ**ेย**ฺ**ย គុ. "**ค**ួ**ร**ឲ**ย**"។ **ท**ាตุ**ํ ป**ท**ាตุ**ํ** អ**ว**ย. "ការ**ឲ**ย, **ด**ើ**ม**្ប**ី**ឲ**ย**" ។ **ธ**ตฺ**ว**า **ธ**ิ**ต**ฺ**ว**า **ธ**ิ**ย ธ**ฺ**ว** អ**ว**ย. "ឲ**ย**ហ**ើ**យ" (ท+ตฺ**ว**า) ។ **ท**ាท**ាตุ** **ธ**ะ**ป**ើ**ม**ាน **อ**ា **ป**ุ**ព**ฺ**ว**ป**ท** ប្រ**ช**ា "**ก**ាន់, **ก**ាន់ខ្ជ**ា**ប់, **ส**ម**ា**ท**ាน**, **ธ**ាំ**ท**ៅ ,..." **ม**ាន**ร**ូ**ป**ส**ิ**ท**ธ**ิ**ด**ូ**ช**ន្ម**ะ**ះ **อ**ท**ท**ាติ **อ**ท**ธ**ेติ, ឧ. **ส**ี**ล**ํ **อ**ท**ท**ាติ "**ก**ាន់**ส**ីល" ។ **อ**ท**ิ**ยติ **ก**ត្ត. ទ. **ก**ម្ម. ภ., ឧ. **ส**ี**ล**ํ **อ**ท**ิ**ยติ ឬ **ส**ม**า**ท**ิ**ยติ "**ส**ីលដ**ែ**ល**ค**េ**ก**ាន់**ส**ម**ា**ท**ាน**ឬ**ป**ុ**ค**្គ**ล**ก**ា**ន់**ส**ម**ា**ท**ាน

ន្ទវសីល" ក៏បាន -ស. ។ ការិត. **អាទបេតិ សមាទបេតិ អាទបយតិ សមាទបយតិ**ឲ្យកាន់ឲ្យកាន់ខ្ជាប់, ឲ្យកាន់យកព្រម (បបួល) ។ អា. **យេ ធម្មមេវាទបយន្តិ សន្តោ** "បុគ្គលជាសប្បុរសទ. ណាញ៉ាំងគេឲ្យកាន់យកនូវធម៌តែម្យ៉ាង" -ស. ។ បំបែក **ទាតុ** ប្រែថា "ឲ្យ" ជាបទមាលាតាមមតិស. ដូចតទៅនេះ៖១-បែប**ទទាតិ**៖ វត្ត. **ទទាតិ ទទន្តិ ទទាសិ ទទាថ ទទាមិ ទទាម**, ។ល។ បញ្ច. **ទទាតុ ទទន្តុ ទទាហិ ទទាថ ទទាមិ ទទាម**, ។ល។ សត្ត. **ទទេយ្យ ទទេ ទទេយ្យុं ទជ្ជុं ទទេយ្យាសិ ទជ្ជាសិ ទជ្ជសិ ទទេយ្យាថ ទជ្ជាថ, ទទេយ្យាមិ ទជ្ជាមិ ទទេយ្យាម ទជ្ជាម, ទទេថ ទទេរំ, ទទេថោ ទទេយ្យាវ្ហោ ទជ្ជវ្ហោ, ទទេយ្យុं ទជ្ជុं ទទេយ្យាម្ហេ ទជ្ជាម្ហេ**។ អា. **ទជ្ជា សប្ផុរិសោ ទានំ** "សប្បុរសគួរឲ្យទាន" ។ **មាតា បិតា ច តេ ទជ្ជុं** "មាតាបិតាគប្បីឲ្យដល់អ្នក" ។ **ទជ្ជាសិ អភយំ មម** "អ្នកគប្បីឲ្យអភ័យដល់ខ្ញុំ" ។ **សីលវន្តេសុ ទជ្ជេសិ ទានំ មទ្ធិ យថារហំ** "នែ!នាងមទ្រីនាងគួរឲ្យទានចំពោះអ្នកមានសីលទ.តាមសមគួរ" -ស.។ បរោ. **ទទ ទទុ ទទូ ទទេ ទទិត្ថ ទទំ ទទិម្ហ** ។ល។ ហិយ្យ. **អទទា អទទុ អទទោ អទទត្ថ អទទំ អទទម្ហា**។ល។ អជ្ជ. **អទទិ អទទុं អទទីសុ អទទោ អទទិត្ថ, អទទិ អទទិម្ហា**។ល។ ភវิ. **ទទិស្សតি ទទិស្សន្តি** ។ល។ កាលา. **អទទិស្សา ទទិស្សា អទទិស្សុं ទទិស្សុं**។ល។ ២-បែប **ទេតি**៖ វត្ត. **ទេតি ទេន្តি ទេសি ទេថ, ទេមি ទេម្ហি ទេម ទេម្ហ**។ល។ បញ្ច. **ទេតু ទេន្តু**។ល។ សត្ត. និងបរោ. មិនមានទីប្រើទេ។ ឯហិយ្យ. និងអជ្ជ. ប្រើដោយចំពោះពាក្យមិនទូទៅទេ, អា. **អទា ទានំ បុរិន្ទទោ** "ព្រះឥន្ទ្របានឲ្យទានហើយ" ។ **ភវញ្ហេ មេ អទោ សក្ក** ! "បពិត្រសក្កទេវរាជបើព្រះអង្គបានព្រះរាជទានពរដល់ខ្ញុំម្ចាស់" ។ **ព្រាហ្ម-ណានំ អទំ ភវំ** "ខ្ញុំបានឲ្យទានដំរីដល់ព្រាហ្មណ៍ទ.″ ។ **អទាសি មេ** "គេបានឲ្យហើយដល់ខ្ញុំ" ។ **អទំសុ តេ មហោកាសំ** "គេទ. បានឲ្យឱកាសដល់ខ្ញុំ" -ស. ។ ភវิ. **ទស្សតি ទស្សន្តি** ។ល។ កាលา. **អទស្សា ទស្សា អទស្សុं ទស្សុं** ។ល។ ២-**ទានេ ទាយតি** កម្ម. **ទីយតি** "ឲ្យ, ថ្វាយ, ប្រគេន" ទិ. ។ អា. **បុរិសោ ទានំ ទាយតি បុរិសេន ទានំ ទីយតি** -ស. ។ នៅមានពាក្យថា **ទត្តោ** មកក្នុងពាក្យ **ទេវទ-ត្តោ ព្រហ្មទត្តោ ពុទ្ធទត្តោ** ជាដើមជាឈ្មោះនៃបុគ្គលនោះ។ ប្រែថា "ទេវតាឲ្យ, ព្រហ្មឲ្យ, ព្រះពុទ្ធឲ្យ" នេះគឺផ្លាស់មកពី **ទិន្ន** ទៅជា **ទត្ត** ជាបទសមាសមិនមានប្រើតែឯកឯងថា **ទត្តោ ទត្តា ទត្តំ** ដូច្នេះទេ ប្រើតែពាក្យថា **ទិន្នោ ទិន្នា ទិន្នំ**។ សូមជ្រាបថាក្នុងភាសាសំស្ក្រឹតប្រើតែពាក្យថា **ទត្តោ** មិនមានពាក្យថា **ទិន្នោ** ទេគឺ

អនុលោមតាមសំស្ក្រឹតទាំងស្រុងចំណែកភាសាបាលីវិញប្រើ **ទិន្ន** ឯ **ទត្ត** មិនឃើញប្រើទោលតែឯកឯងមានខ្លះ ដូចពាក្យ **ទត្តិយ** អា. **ទេវ- ទត្តិយបត្តោ ច អស្សរោ សក្ករទត្តិយោ** -ស. ។ **ទិនំ** នបុં. "ថ្ងៃ, វេលាថ្ងៃ" ចាក **ទា** ធាតុ "ឲ្យ" **ឥន** បច្ច័យសូចិថាចាក **ទិវ** ធាតុ "លេង" ឬ **ទី**ធាតុ "អស់" ។ **ទិនករោ** បុំ. "ព្រះអាទិត្យ" ធ្វើថ្ងៃ។ **ទិន-បតិ** បុំ. "ព្រះអាទិត្យ" ម្ចាស់របស់ថ្ងៃ (**សូចិ**) ។ ៣-**ឥច្ឆិតកមណេ ទាតិ សុទ្ធាតិ** "ទៅគួរខ្ពើម" ភ្ញ. ។ **សុទ្ធো** បុំ. **សុទ្ធី** ឥ. ជា **សូទោ**ក៏មាន "អ្នកគ្រូ, អ្នកចម្អិនអាហារ" ។ ៤-**សោធនេ ទាយតិ ទានំ ទត្វា ទាបនំ** "ជម្រះ, ធ្វើឲ្យស្អាត" ទិ. ។ អា. **អនុយោគំ ទាបនត្ថំ** "ដើម្បីកិ.ញ្ជាំងសំណួរឲ្យស្អាត, ដើម្បីឆ្លើយតបសំណួរ" ។ **ទានំ ទត្វា** "ជម្រះនូវទាន, នូវចេតទាន" -ស. ។ ៥-**សុបនេ ទាយតិ និទ្ទាយតិ និទ្ទាយមានោ និទ្ទាយន្តោ និទ្ទាយិត្វា** "ដេកលក់, ផ្ទំ,សឹង, សម្រាន្តលក់" ទិ. ។ **និទ្ទា** ឥ. "ការដេកលក់" អា. **និទ្ទាសីលី សតា-សីលី** "ហៅខាងដេកលក់, ហៅខាងប្រជុំ" ។ ៦-**អវខណ្ឌនេ ទិយតិ ទាយតិ ទានំ** "កាត់, ដាច់" ទិ. ។ **ទន្តো** កិ. គុ. "ដាច់ហើយ, កាត់ហើយ" បុំ. "ធ្មេញ, ភ្លុក" ។ ៧-**សុទ្ធិយំ ទាយតិ ទោទាយតិ បរិ-យោទាយតិ** "បរិសុទ្ធម៉ត់ចត់, ផ្ទរផង់, ស្អាត" ទិ. ការិត. **បរិយោទ-បេតិ** "ឲ្យបរិសុទ្ធ, ឲ្យផ្ទរផង់, ឲ្យម៉ត់ចត់ (បរិ+ឱ+ទា+ណាបេ) **ទោ-ទានំ** នបុំ. "សេចក្តីបរិសុទ្ធ, សេចក្តីផ្ទរផង់" (រិ+ឱ+ទា+យុ) ។

ទាខ	ធា.	**សោសនអលមត្ថេសុ ទាខតি** "ស្ងួត, ហៃងហួត, ហាម, ឃាត់" ភ្ញ. ។
ទាយ	ធា.	**សាមត្ថិយអយាសេសុទាយតি** "អាច, មានសមត្ថភាព, លំបាក, ហត់នឿយ" ភ្ញ. ។ **និទាយោ** បុំ. "រដូវក្តៅ,និទាយរដូវ" (និ+ទាយ) **សូចি**ថា (និ+ទហ+ណ, ហ >យ។
ទាថ	ឥ.	[ទិសិ>ទា + ឋ + អា-ឥ.] ចង្កូម។
ទាតព្ព	គុ.	[ទា+តព្ព] គឺ..គប្បីឲ្យ, -គួរឲ្យ, -ត្រូវឲ្យ។ -**យុត្តក** គុ. ជារបស់គួរគឺបុគ្គលគប្បីឲ្យ។
ទាតុកាម	គុ.	[ទាតុំ + កាម] អ្នកចង់ដើម្បីឲ្យ, អ្នកមានប្រាថ្នាដើម្បីឲ្យ។ -**តា** ឥ. ភាវៈនៃ...ជាអ្នកចង់ដើម្បីឲ្យ។
ទាត	គុ.	កាត់, ដក, ដាច់ (ដូច **លូនោ**) ។
ទាត្ត	នបុំ.	ក្ណៀវ (ដូច **លវិត្ត**) ។
ទាត្យុហ	បុំ.	ក្អែកទឹក, កុកដំបងគ្រញូង (ដូច **ការ្ឍកណ្ណក**)
ទាន	នបុំ.	[ទា + យុ] កិ.ឲ្យ, ការឲ្យ, រិ. **ទីយតេតি>ទានំ។** (វត្ថុ) ជាគ្រឿងឲ្យ, រិ. **ទេតি ឯតេនាតি>ទានំ**។ (ទី) ជាទីឲ្យ, រិ. **ទេតি ឯតស្មិន្តি>ទានំ**។ -**កថា** ឥ. ទានកថា, វាចាជាគ្រឿងពោលនូវទាន, វាចាជាហេតុ

ពោលប្រារព្ធនូវទាន, វាចាជាហេតុពោលដោយអំណាចនៃទាន។ -**កថាទិភេទ** គុ. ផ្សេងដោយកថាមានទានកថាជាដើម, មានកថាមានទានកថាជាដើមជាប្រភេទ។ -**ការ** បុ. កាលជាទីឲ្យ, កាលនៃកិ.ឲ្យ។ -**អគ្ត** នបុ. ពោងនៃទាន។ -**បរិច្ចាគ** បុ. កិ.បរិច្ចាគនូវទាន, ការលះនូវទាន។ -**ញ្ញាវជ** បុ. អ្នកខ្ជល់ខ្ជាយក្នុងទាន, អ្នកចាត់ចែងនូវទាន។ -**មុខ** នបុ. មាត់នៃទាន, ជាប្រធាននៃទាន។ -**រសតិ** ឥ. ទាននិងរសនិងសេចក្ដីត្រេកអរ។ -**ឋត្ត** នបុ. វត្ថុគឺវត្ថុដែលបុគ្គលគប្បីឲ្យ, វត្ថុគឺវត្ថុជាគ្រឿងឲ្យ, វត្ថុគឺបុគ្គលឲ្យប្រព្រឹត្តទៅក្នុងទាន (ប្រើជាទានវដ្ដក៏មាន) ។ -**សំវិភាគរត** គុ. អ្នកត្រេកអរហើយក្នុងទាននិងកិ.ចែករំលែក។ -**សីលាទិ** គុ. មានទាននិងសីលជាដើម។ ការលះបង់ (ដូច **ចាគ**) ។ ប្រេងនៃដំរី, ប្រេងជាគ្រឿងស្រវឹងនៃដំរី (**ករិមទ**), ឧបាយនៃសេចក្ដីឈ្នះអរិភាព (ដូច **ភេទ**)។ ហ្មត់ចត់, ស្អាត (ដូច **សុទ្ធ**) ។ ការកាត់ (ដូច **ខណ្ឌន**) ។ ការច្រូត (ដូច **លវន**) ។

ទានវ	បុ.	អសុរសាមញ្ញ (ដូច **សុរិបុ**) ។
ទានសោណ្ឌ	បុ.	អ្នកលេងទាន, អ្នកខ្ជល់ខ្ជាយក្នុងទាន (ដូច **ពហុប្បទ**) ។
ទានានុច្ឆវិក	គុ.	[ទាន + អនុច្ឆវិក] ដ៏សមគួរដល់ទាន។
ទានានុមោទន, -**នា**	នបុ., ឥ.	[ទាន + អនុ + មុទ + យុ] កិ.រីករាយតាមនូវទាន, ធម្មកថាជាគ្រឿងរីករាយតាមនូវទាន, ធម្មកថាជាគ្រឿងរីករាយរឿយៗដោយអំណាចនៃទាន , ការអនុមោទនាចំពោះទាន,... ។ -**បុញ្ញ** នបុ. បុណ្យគឺសេចក្ដីរីករាយតាមនូវទាន,..។
ទានានុរូប	គុ.	[ទាន + អនុរូប] ដ៏សមគួរដល់ទាន, មានសភាពប្រព្រឹត្តទៅតាមនូវទាន។
ទានារហ	បុ.	បុគ្គលគួរដល់ទាន (ដូច **ទក្ខិណេយ្យ**) ។
ទានុបករណ	នបុ.	[ទាន + ឧបករណ] គ្រឿងឧបករណ៍របស់ទាន, វត្ថុជាគ្រឿងធ្វើនូវសេចក្ដីទំនុកបម្រុងដល់ទាន។
ទានិ	ធា.	**អវខណ្ឌនេ ទានតិ ទានំ** "កាត់, ដាច់" ភូ. ។
ទាឡិ	ឥ.	ដើមរមៀត (ដូច **ទារុហត្ថិឡា**), ឈើនេះមានសម្បុរដូចមើមរមៀត ។
ទាម	នបុ.	ខ្សែ (គោ) (ដូច **សន្ទន**)
ទាយ	នបុ.	[ទា + ណ, ផ្លាស់អានៃទា>អាយ, លុបណ] (វត្ថុ) ដែលជនគួរឲ្យ (រង្វាន់), វិ. **ទាតព្ពន្តិ>ទាយំ**។ ទ្រព្យដែលគួរចែក (**ទាតព្ពធន**), ទ្រព្យនៃមាតានិងបិតា, ទ្រព្យមត៌ក (**បិតូនំ ធនំ**) ។ បុ. ព្រៃ (ដូច **ឋន**, **ភាកន**) ។

ទាយជ នបុ. [ទាយាទ + ណ្យ] ភាវៈនៃជនអ្នកកាន់យកនូវទ្រព្យដែលមាតានិងបិតា (ដែលត្រកូលឬដែលអ្នកណាមួយ) គប្បីឲ្យ (មតិក, ទ្រព្យជាមតិក) វិ. **ទាយំ អាទិយន្តីតិ>ទាយាទា** (ជនា), **ទាយាទានំ ភាវោ>ទាយជ្ជំ**។

ទាយាទ បុ. ផៅពង្ស, ញាតិ (ដូច **ពន្ធវ**), កូន (ដូច **បុត្ត**) ។

ទារ បុ. [ទ្រ + អ] ប្រពន្ធ។

ទារក បុ. [ទ្រ+ណ្ឍ] ជនអ្នកទម្លាយគឺគូសវាសនូវផែនដីដោយអំណាចនៃកិ.លេង (ទារក, ក្មេងប្រុស), វិ. **ទរតិ ភីឡនវសេន ភូមឺ ទ្ធិលិខតីតិ> ទារកោ**។ -**ហ្ការ** ឥ. មាននៃទារក។ -**ស្ត** នបុ. រយនៃទារក។ -**ស្ទ** បុ. សំឡេងឬសូរនៃទារក។

ទារិកា ឥ. [ទ្រ + ណ្ឍ] ក្មេងស្រី, ទារិកា។

ទារិត គុ. បែក, ធ្លាយ, ទម្លាយ (ដូច **ភេទិត**) ។

ទារុ នបុ. [ទ្រ+ណុ] (ឈើ) ដែលជនទម្លាយឬបំបែក (ឧស, ឈើ), វិ. **ទរិយតីតិ> ទារុ** (**ឈ្ជ**) ។ -**អម្ពណ្ណាមត្ត**គុ. មានស្នូកជាវិការៈនៃឈើជាប្រមាណ, ប៉ុនស្នូកឈើ។ -**អាទិ**គុ. (វត្ថុ) មានឈើជាដើម, មានឧសជាដើម។

ទារុក នបុ. [ទារុ + ក-ស.] ឈើ, ឧស។

ទារុក្ខន្ធសទិស គុ. [ទារុ+ខន្ធ+សទិស] ប្រាកដស្មើដោយកំណាត់ (ដុំ, គំនរ) នៃឈើ។

ទារុខណ្ឌ បុ. កំណាត់នៃឧស, សព្ទនេះជាអត្ថន័យ **ឋីឍ** សព្ទ ។

ទារុចីរិយត្ថេរ បុ. [ទារុចីរិយ + ថេរ] ព្រះថេរៈឈ្មោះទារុចីរិយៈ, ព្រះថេរៈអ្នកស្លៀកនូវសំបកឈើ។

ទារុចីរ នបុ. [ទារុ + ចីរ] សំពត់ជាវិការៈនៃសំបកឈើ, សំពត់គឺបុគ្គលក្រងដោយសំបកឈើ, សំពត់សំបកឈើ។

ទារុជបព្ទជ គុ. [ទារុជ + បព្ទជ] ដែលកើតអំពីឈើនិងជាវិការៈនៃស្មៅដំណេកទន្សាយ, ដែលកើតអំពីឈើនិងកើតអំពីស្មៅដំណេកទន្សាយ។

ទារុណ គុ. [ទ្រ + ឧណ] អាក្រក់, អំពើអាក្រក់, ទារុណកម្ម។ -**តា** ឥ. ភាវៈនៃ... ជាអ្នកអាក្រក់។ នបុ. ភ័យសាមញ្ញ, សេចក្តីខ្លាច (ដូច **ភេរវ**) ។

ទារុតេលាទិ គុ. [ទារុតេល + អាទិ] (វត្ថុ) មានឧសនិងប្រេងជាដើម , វិ. **ទារុតេលំ អាទិ យស្ស តំ >ទារុតេលាទិ**។

ទារុទកាទិ គុ. [ទារុទក + អាទិ] (វត្ថុ) មានឧសនិងទឹកជាដើម។

ទារុទណ្ឌក នបុ. [ទារុ + ទណ្ឌក] កំណាត់ឈើគឺឧស។

ទារុបណ្ណាទិ គុ. [ទារុបណ្ណ + អាទិ] (វត្ថុ) មានឧសនិងស្លឹកឈើ (បន្លែ) ជាដើម, វិ. **ទារុ ច បណ្ណ ច>ទារុបណ្ណ, ទារុបណ្ណ អាទិ យស្ស តំ> ទារុបណ្ណាទិ**។

ទារុមណ្ឌលិក គុ. [ទារុមណ្ឌល + ណិក] ប្រកបដោយមណ្ឌលជាវិការៈនៃឈើ, មានមណ្ឌលជាវិការៈនៃឈើ, វិ. **ទារុមណ្ឌលេន និយុត្តំ>ទារុមណ្ឌលិកំ**។

ទារុមយ គុ. [ទារុ + មយ] ជាវិការៈនៃឈើ, សម្រេចហើយដោយឈើ(វិការតទ្ធិត, និបន្ទតទ្ធិត) ។ -**បត្ត** បុ. បាត្រជាវិការៈនៃឈើ, ... ។

ទារុរាសិ បុ. [ទារុ + រាសិ] គំនរនៃឈើ, គំនរនៃឧស។

ទារុសកដ នបុ. [ទារុ+សកដ]រទេះសម្រាប់នាំទៅនូវឧស,រទេះដ៏ពេញដោយឧស។

ទារុសាកដិក គុ. [ទារុ + សកដ + ណិក] (ជន) អ្នកត្រាច់ទៅដោយរទេះព្រោះឧស, អ្នកនាំទៅនូវភណ្ឌៈដោយរទេះព្រោះឧស(ចរតិតទ្ធិត, នេតិតទ្ធិត)។ -**ឋត្ត** នបុ. រឿងនៃបុរសអ្នកត្រាច់ទៅដោយរទេះព្រោះឧស។

ទារុហត្ថី បុ. [ទារុ + ហត្ថី] ដំរីជាវិការៈនៃឈើ, ដំរីដែលគេធ្វើហើយដោយឈើ (វិការតទ្ធិត, បកតតទ្ធិត) ។

ទារុហលិទ្ធា ឥ. ដើមរមៀត (ដូច **ទារ្ធិ**) ។

ទារុហលិទ្ធា ឈើនេះមានសម្ផុរដូចដើមរមៀត ។

ទាលិទ្ធិយ នបុ. [ទលិទ្ធ + ណិក] ភាវៈនៃស្តេចកម្សត់ឬភាវៈនៃបុគ្គលអ្នកទ័លក្រ, វិ. **ទលិទ្ធស្ស ភាវោ>ទាលិទ្ធិយំ**។

ទាលិម បុ. ដើមទទិម (ដូច **ករក**) ។

ទាវគ្គិ បុ. [ទាវ + អគ្គិ] ភ្លើងដែលឆេះនូវព្រៃ, ភ្លើងព្រៃ។ -**សទិស** គុ. ប្រាកដស្មើដោយភ្លើងដែលឆេះនូវព្រៃ, ប្រាកដស្មើដោយភ្លើងព្រៃ។

ទាស បុ. [ទាសិ + អឬទា + ស] ទាសៈ, ខ្ញុំ, ខ្ញុំប្រុស។ -**កម្មករ** បុ. ទាសៈនិងកម្មករ, ខ្ញុំនិងជនអ្នកធ្វើនូវការងារ។ - **កម្មករបោរិស** បុ. ទាសៈនិងកម្មករនិងពួកនៃបុរស។ - **កម្មករាទិ**បុ. (ជន) មានទាសៈនិងកម្មករជាដើម។ - **ចណ្ឌាលាទិ** គុ. មានទាសៈនិងមនុស្សចណ្ឌាលជាដើម។ -**ទារក** បុ. ទាសៈនិងទារក។ -**ទាសី** ឥ. ទាសៈនិងទាសី, ខ្ញុំប្រុសនិងខ្ញុំស្រី។

ទាសញ្ញ នបុ. [ទាស + ណ្យ] ភាវៈនៃទាសៈ, ភាវៈនៃ...ជាខ្ញុំ (ភាពជាខ្ញុំគេ), វិ. **ទាសស្ស ភាវោ >ទាសញ្ញំ**។

ទាសញ្ញោបគត គុ. អ្នកដែលព្រមចូលខ្លួនធ្វើខ្ញុំកំដរគេ ។

ទាសី ឥ. [ទាស+ណ្យ] ទាសី, ខ្ញុំស្រី។ -**ធីតា** ឥ. ធីតានៃទាសី, កូនស្រីនៃទាសី។ -**បុត្ត** បុ. បុត្រនៃទាសី, កូនប្រុសនៃទាសី។ -**ភោគ** បុ. ការប្រើប្រាស់ដូចជាទាសី។ ២-ដើមសិរមាន់, ដើមស្លាផ្ងា (ដូច **សេរេយ្យក**) ។

ទាសិ ធា. ១-**ហឺសាយំ ទាសុណាតិ** "បៀតបៀន" សុ. ។ ២-**ទានេ ទាសតិ** "ឲ្យ, ផ្តល់, ថ្វាយ, ជូន, ប្រគេន" ភូ. ។

ទាហិ ធា. **និទ្ធក្ខយេ ទាហតិ** "ភ្ជាក់អស់ការដេកលក់" ភូ. ។

ទាឡ ធា. **ឌិទារណេ ទាឡតិ** "បំបែក, ទម្លាយ, ញែក" ភ្ជ. ។

ទិក្ខណាបថ បុ. [ទក្ខិណ + អាបថ] ជនបថឈ្មោះទក្ខិណាបថ។

ទិក្ខា ឥ. ទេវបូជា (ដូច **យជន**) ។ ការបូជា, គោរព, កោតក្រែង (ដូច **អច្ចន**) ។

ទិក្ខ ធាតុ **ហឹសាយំ ទិក្ខុណាតិ** "បៀតបៀន" ភ្ជ. ។

ទិគម្ពរ បុ. មនុស្សអាក្រាត (ដូច **ឌគ្គ**) ។

ទិគុណ គុ. [ទ្វិ>ទិ + គុណ] គុណដោយចំណែកពីរ, គឺបុគ្គលគុណដោយចំណែកពីរ (ពីរជាន់), វិ. **ទ្វីហិ គុណំ>ទិគុណំ**។ -**តិគុណ** គុ. ទាំងគុណដោយចំណែកពីរ ទាំងគុណដោយចំណែកបី, គឺបុគ្គលគុណដោយចំណែកពីរនិងគឺបុគ្គលគុណដោយចំណែកបី (ពីរជាន់និងបីជាន់) ។

ទិគ្ឃិកា ឥ. ឆ្ងូ, ស្នាមភ្លោះ (ដូច **បរិខា**)

ទិឃម្ពរ បុ. **ឌិក្រន្ត** (ដូច **អចេលក**) ។

ទិច ធា. **ថុតិយំ ទិចតិ** "សរសើរ, ស្ងើច" ភ្ជ. ។

ទិជ គុ. [ទ្វិ>ទិ + ជនិ + ក្ឋិ] អ្នកកើតអស់វារៈពីរដង (សត្វស្លាប), វិ. **ទិក្ខត្តុំ ជាយតីតិ >ទិជោ**។

ទិដ្ឋ គុ. [ទិស+ត, ស+ត>ដ្ឋ] គឺ...ឃើញហើយ, -គប្បីឃើញ។ -**កហាបណ** បុ. នបុ. កហាបណៈគឺ...ឃើញហើយ។ -**កាល** បុ. កាលនៃ..គឺ...ឃើញហើយ។ -**ដ្ឋាន** នបុ. ទីនៃ..គឺ..ឃើញហើយ។ -**ត្ត** នបុ. ភាវៈនៃ..ជា..គឺ..ឃើញហើយ។ -**ធម្ម** បុ. ធម៌គឺសត្វឃើញហើយ, ធម៌គឺសត្វគប្បីឃើញ, អ្នកមានធម៌ឃើញហើយ, (បច្ចុប្បន្ន) ។ -**ធម្មគរុក** គុ. អ្នកធ្ងន់ក្នុងធម៌គឺសត្វឃើញហើយ, -គឺសត្វគប្បីឃើញ, អ្នកធ្ងន់ក្នុងបច្ចុប្បន្ន។ -**ធម្មសុខវិហារ** បុ. កិ.នៅនាំមកនូវសេចក្តីសុខក្នុងធម៌គឺសត្វគប្បីឃើញ, នៅជាសុខក្នុងបច្ចុប្បន្ន។ -**ធម្មិកសម្ប-រាយិក** គុ. ទាំងប្រព្រឹត្តទៅក្នុងធម៌គឺសត្វគប្បីឃើញទាំងប្រព្រឹត្តទៅក្នុងលោកគឺសត្វគប្បីដល់ព្រមក្នុងខាងមុខ, ទាំងបច្ចុប្បន្នទាំងបរលោក (**ទិដ្ឋធម្មិក**<ទិដ្ឋធម្ម + ណិក = វិ. **ទិដ្ឋធម្មេ ភវត្តីតិ> ទិដ្ឋធម្មិកោ**) ។ -**បុព្ព** គុ. គឺ...ធ្លាប់ឃើញហើយ។ -**ភាវ** បុ. ភាវៈនៃ..ជា..គឺខ្លួនឃើញហើយ។ -**មត្ត** គុ. គ្រាន់តែគឺ..ឃើញហើយ។ -**សច្ច** គុ. មានសច្ចៈឃើញហើយ។ ២-ជនជាសត្រូវ (ដូច**អរិ**) ។

ទិដ្ឋមត្តក បុ. មិត្រដែលគ្រាន់តែជួបគ្នាតែម្តងៗ (ដូច **សន្ទិដ្ឋ**) ។

ទិដ្ឋា និ. **អានន្ទត្ថវាចកៈ** និបាតប្រាប់អត្ថគឺត្រេកអរ, **សំ** ក៏ជាអានន្ទត្ថវាចកៈដែរ។

ទិដ្ឋានុគតិ ឥ. [ទិដ្ឋិ + អនុគតិ] កិ.ប្រព្រឹត្តទៅតាមនូវសេចក្តីយល់ឃើញ, -នូវទិដ្ឋិ, -ដោយអំណាចនៃទិដ្ឋិ (តម្រាប់, យកជាតម្រាប់) ។

ទិដ្ឋានុភូត គុ. [ទិដ្ឋ + អនុភូត] ទាំងគឺខ្លួនឃើញហើយទាំងគឺខ្លួនរងហើយ, គឺខ្លួនឃើញហើយគឺខ្លួនរងហើយ (**អនុភូត**<អនុ+ភូ+ត=រង, សោយ) ។

ទិដ្ឋិ ឥ. [ទិសិ+តិ, តិ>ដ្ឋិ, លុបស] ទិដ្ឋិ, កិ.ឃើញ, ការយល់ឃើញ,យោបល់ (ដូច **លទ្ធិ**) រ. **ទស្សនំ>ទិដ្ឋិ**។ -**សច្ច**នបុ. **សច្ច:** គឺ **ទិដ្ឋិ**។

ទិត្ត គុ. ភ្លឺ, រុងរឿង, ក្តៅ (ដូច **អាទិត្ត**) ។ ២-ឆ្មើង, ព្រហើន, កាន់ខ្លួន (ដូច **គព្ភិត**) ។

ទិត្តិ ឥ. រស្មី, ពន្លឺ (ដូច **បភា**)

ទិទ្ធ បុ. កូនសរដែលលាបដោយថ្នាំពិស (**ទិសលិត្តសរ**), លាប (ដូច **លិត្ត**) ។

ទិនករ បុ. ព្រះអាទិត្យ (ដូច **ទេវរោចន**) ។

ទិនបតិ បុ. ព្រះអាទិត្យ (ដូច **អំសុមាលី**)

ទិន្ធិក បុ. សត្វត្រដេវិច (ដូច **ភីភី**)

ទិន្ន គុ. [ទា + ត, ត>ឥន្ន] គឺ...ឲ្យហើយ, ប្រគេនហើយ, -ថ្វាយហើយ, រ. **ទីយិត្ថាតិ>ទិន្នំ**។ -**កម្ពល** នបុ. សំពត់កម្ពលគឺ...ឲ្យហើយ។ -**កាល** បុ. កាលនៃទានគឺ....ឲ្យហើយ។ -**ត្ត** នបុ. ភាវ:នៃ....ជារបស់គឺ....ឲ្យហើយ។ - **ទាន** នបុ. ទានគឺ....ឲ្យហើយ។ -**ទ្វារ** នបុ. ទ្វារគឺ....ឲ្យហើយ។ -**ធន** នបុ. ទ្រព្យគឺ....ឲ្យហើយ។ -**នយ** បុ. ន័យ (សេចក្តីពន្យល់) ដែល....ឲ្យហើយ។ -**និយាម** បុ. ទំនងនៃទានគឺ....ឲ្យហើយ ។ -**បត្ត** បុ. បាត្រគឺ...ឲ្យហើយ ។ -**ហរ** បុ. វត្ថុជាគ្រឿងនាំទៅ ជុំវិញគឺ...ឲ្យហើយ, វត្ថុជាគ្រឿងរក្សាគឺ...ឲ្យហើយ, គ្រឿងយសគឺ....ឲ្យហើយ។ -**បាយាស** បុ. បាយាសគឺ....ឲ្យហើយ។ -**បិណ្ឌាបាត** បុ. បិណ្ឌាបាតគឺ....ឲ្យហើយ, គុ. មានបិណ្ឌាបាតគឺ....ឲ្យហើយ។ -**ភតិ** ឥ. ឈ្នួលដែលស្រីនេះឲ្យហើយ, ថ្លៃឈ្នួលគឺ....ឲ្យហើយ។ -**ភាវ** បុ. ភាវ:នៃ....ជារបស់គឺ....ឲ្យហើយ។ -**ភេសជ្ជ-ទាន** នបុ. ភេសជ្ជទានគឺ....ឲ្យហើយ, ទានគឺថ្នាំដែលបុគ្គលឲ្យហើយ។ -**លាជនិស្សន្ទ** បុ. វិបាកជាគ្រឿងហូរចេញនៃលាជគឺ...ឲ្យហើយ, អានិសង្សនៃលាជដែល....ឲ្យហើយ។ -**សញ្ញា** ឥ. សញ្ញាគឺ...ឲ្យហើយ។ -**សញ្ញាវស** បុ. អំណាចនៃសញ្ញាគឺ....ឲ្យហើយ។ -**សម្បត្តិ** ឥ. សម្បត្តិគឺ...ឲ្យហើយ។ -**សាដក** បុ. សាដកគឺ...ឲ្យហើយ។ -**សេនាសនទាន** នបុ. សេនាសនទានគឺ....ឲ្យហើយ។

ទិន្នក គុ. [ទា + ត + ក-ស.] (វត្ថុ) គឺ...ឲ្យហើយ។

ទិន្នាវសេស គុ. [ទិន្ន + អវសេស] ដ៏សេសចុះចាកទានដែល....ឲ្យហើយ, វត្ថុជាចំណែកសេស ចុះចាកទានគឺ...ឲ្យហើយ, ជារបស់សំណល់ដែល.....ឲ្យហើយ។

ទិន្នាវុធ បុ. [ទិន្ន + អាវុធ] អាវុធគឺ....ឲ្យហើយ, -គឺយើងឲ្យហើយ។

ទិន្នោវាទ បុ. [ទិន្ន + ឱវាទ] ឱវាទគឺ.....ឲ្យហើយ។

ទិន នបុ. ថ្ងៃ (ដូច **អហ**) ។

ទិបទ គុ. [ទ្វិ + បទ] (សត្ត) មានជើងពីរ, វិ. **ទ្វេ បទានិ ឯតេសន្តិ>ទិបទា**។

ទិប ធា. **ទិត្តិយំ ទិប្បតি** "ភ្លឺ, ឆ្លុះ, ចាំង" ទិ. ។ **ទីបោ** បុ. "ព្រះនិព្វាន, ប្រទីប, ចង្កៀង, ទៀន, ទ្វីប, ភោះ, ភ្លើង" ។ **បទីបោ** បុ. "ប្រទីប, ចង្កៀង, ទៀន, ភ្លើង" ។ **ទប្ប្យណោ** បុ. "កញ្ចក់" ។

ទិធ ធា. **ភថនយុទ្ធនិន្ទាហឹសាទានេសុ ទេធតি ទេធោ** "ពោល, ច្បាំង, និន្ទា, តិះដៀល, បៀតបៀន, កាន់យក" ភូ. ។

ទិព្វវិហារាទិ គុណ មានទិព្វវិហារជាដើម, សព្ទនេះជាអត្ថនៃ**ទិហារ**សព្ទ ។

ទិព្ព បុ., គុ. [ទិវ + វសិ + អឬទិវ + អ] អ្នកនៅក្នុងឋានសួគ៌ឬអ្នកលេងដោយកាមគុណប្រាំ (ទេវតា,ទិព្ព),វិ.**ទិវេ ភវសន្តីតি>ទិព្ពា, ទិព្ពន្តি បញ្ចហি កាមគុណេហি កីឬន្តីតি ទា> ទិព្ពា**។ -**ឆន្ទមាណទិ** គុ. (វត្ថុ) មានវត្ថុមានក្លិននិងកម្រងផ្កាដ៏ទិព្ពជាដើម, មានគ្រឿងក្រអូបនិងកម្រងផ្កាដ៏ទិព្ពជាដើម។ -**ភីតសទ្ទ** បុ. សូរនៃចម្រៀងដ៏ទិព្ព, សំឡេងនៃចម្រៀងគឺបុគ្គលគប្បីច្រៀងជាទិព្ព។ -**ចក្ខុក** គុ. អ្នកមានចក្ខុដូចជាទិព្ព។ -**ចក្ខុបរិកម្ម** នបុ. បរិកម្មដើម្បីទិព្ពចក្ខុ, -ដើម្បីចក្ខុជាទិព្ព។ -**ចក្ខុ** នបុ. ចក្ខុជាទិព្ព, ចក្ខុដូចជាទិព្ព។ -**អច្ឆរ** ឥ. ស្ត្រីអប្សរជាទិព្ព, នាងអប្សរមានក្នុងឋានសួគ៌។ -**អត្តភាព** បុ. អត្តភាពដ៏ជាទិព្ព។ -**ទុស្ស** នបុ. សំពត់ជាទិព្ព។ -**អន្ទបាន** នបុ. វត្ថុគឺបុគ្គលគប្បីស៊ីនិងទឹកគឺបុគ្គលគប្បីផឹកដ៏ជាទិព្ព, បាយនិងទឹកដ៏ជាទិព្ព។ -**បណ្ណាការ** បុ. គ្រឿងបណ្ណាការ (ជំនូន, តង្វាយ) ដ៏ជាទិព្ព។ -**ប្បដិភាគ** គុ. មានចំណែកប្រៀបដោយ...ជាទិព្ព។ -**បាន** នបុ. ទឹកគឺបុគ្គលគប្បីផឹកជាទិព្ព។ -**បារិច្ឆត្តក** បុ. ដើមបារិច្ឆត្តក:ជាទិព្ព, បារិច្ឆត្តកព្រឹក្សជាទិព្ព។ -**ឫាសាទ** បុ. ប្រាសាទជាទិព្ព។ -**បុប្ផវស្ស** នបុ. ភ្លៀងជាវិការ:នៃផ្កាដ៏ទិព្ព, ភ្លៀងគឺផ្កាដ៏ជាទិព្ព។ -**ឫូ** បុ. នំជាទិព្ព។ -**យោគ** បុ. ធម៌ជាគ្រឿងប្រកបដ៏ជាទិព្ព។ -**ភត្ត** នបុ. សំពត់ដ៏ជាទិព្ព។ -**អាភរណប្ប្ដិមណ្ឌិត** គុ. ប្រដាប់ចំពោះហើយដោយគ្រឿងអាភរណ:ជាទិព្ព, ដោយគ្រឿងអម្ពរជាទិព្ព។

ទិព្ពោជា ឥ. [ទិព្ព + ឱជា] ឱជាដ៏ជាទិព្ព។

ទិយឌ្ឍ គុ. [អឌ្ឍ + ទុតិយ>ទិយឌ្ឍ] គម្រប់ពីរដោយកន្លះ, ទីពីរដោយកន្លះ (មួយកន្លះ), វិ. **អឌ្ឍេន ទុតិយោ>ទិយឌ្ឍោ**។ -**ជាតិសហស្ស** នបុ. ពាន់នៃជាតិជាគម្រប់ពីរដោយកន្លះ (១.៥០០ជាតិ) -**យោ-ជនសតិក** គុ. ប្រកបដោយរយនៃយោជន៍ជាគម្រប់ពីរដោយកន្លះ,

		មានរយនៃ...., (១៥០យោជន៍) ។ -**សហស្សនាដកិត្តីបរិវារ** គុ. មានស្ត្រីរបាំមានពាន់ជាគម្រប់ពីរដោយកន្លះជាបរិវារ។ -**សហស្ស-បរិចារិកា** ឥ. ស្ត្រីអ្នកបម្រើមានពាន់ពីរដោយកន្លះជាប្រមាណ។
ទិវ	បុં.	ស្ថានសួគ៌ (ដូច **សគ្ត**), អាកាស (ដូច **គគន**) ។
ទិវឌ្ឍ	គុ.	ទីពីរដោយកន្លះគឺមួយកន្លះ ។
ទិវស	បុં., ន បុં.	[ទិវ+ស] ថ្ងៃ។ -**បរិយោសាន** នបុં. កាលជាទីបំផុតចុះជុំវិញនៃថ្ងៃ, កាលជាទីបំផុតនៃថ្ងៃ។ -**ភតិមត្ត** គុ. វត្ថុត្រឹមតែថ្លៃឈ្នួលក្នុងថ្ងៃ។ -**ភាគ** បុં. ចំណែកនៃថ្ងៃ, កាលជាចំណែកនៃថ្ងៃ។
ទិវា	និ.	ថ្ងៃ, ក្នុងវេលាថ្ងៃ, ក្នុងកណ្តាលថ្ងៃ។ -**ដ្ឋាន** នបុં. ទីជាទីនៅក្នុងវេលាថ្ងៃ។ **អហត្ថវាចក:** និបាតប្រាប់អត្ថគឺវេលាថ្ងៃ។
ទិវាករ	បុં.	ព្រះអាទិត្យ (ដូច **សតរំសិ**) ។
ទិវោក	បុំ.	ទេវតាសាមញ្ញ (ដូច **មរุ**) ។
ទិវី	ធា.	**ក៑ីឡាវិជិគីសាញ្ញវហារជុតិថុតិកន្តិគតិសត្តីសุ ទิฑ្ឍតิ** "លេង, នៅ, ចង់ឈ្នះ, ពោល, រុងរឿង, ភ្លឺ, សរសើរ, គួរស្រឡាញ់, ទៅ, អាច, មានសមត្ថភាព" ទิ. ។ **ទេវោ** បុំ. "ទេវតា" មានន័យ៣យ៉ាងៈ ១/ **សម្មតิទេវោ** "ទេវតាដោយសន្ទតิ" បានដល់ឥស្សរជនមានព្រះរាជាជាដើម។ ២/ **ឱิបបត្តิទេវោ** "ទេវតាដោយកំណើតដើម" សព្ទវេចនៈគឺ **ទេវោ សุរោ ទิฑุឡោ ទิฑ្ឍរោ អមរោ មรุ សุธาสี ติทสោ សคฺคาสี អนิมิสោ ទิโวกោ អมตปายี សคฺคฏฺโฐ ទេวตา** -ส. ។ ៣/ **ទิสุទ្ធิទេវោ** "ទេវតាដោយបរិសុទ្ធ" បានដល់ព្រះពុទ្ធនិងព្រះអរហន្ត -ส.។**ទេวสญฺ** អាចប្រែបាន២យ៉ាងទៀតគឺ ១/ **អជฺฌากาส**, ផ្ទៃអាកាស, អាកាស =**អជฺฌากาสោ** បាលីថា **ទิคตวณฺณาหาเร ទেវে** "កាលបើផ្ទៃអាកាសស្រឡះ" ២/ ភ្លៀង, មេឃ =**មেঘো** បាលីថា **ទেวো ช ถোกํ ถোกํ ฉุสายติ** "ទឹកភ្លៀងប៉ះពាល់បន្តិចៗ -ส. ។ **ទেวี** ឥ. មានន័យ២យ៉ាងគឺ "ព្រះជាយានៃព្រះរាជា, ព្រះរាជិនី, ព្រះរាជទេពី"=រាជ ภริยา" មួយ, "នាងទេវធីតា" =ទេវធីតាមួយ-ส. ។
ទิวี	ធา.	**បริภูชเน (คฺชฺเน) ទেวেติ ទেวยติ បริទেวেติ បริទেว-យติ ទেวো បริទেวো បริទেวิตฺวา** "គ្រហឹម, យំ, ខ្សឹកខ្សួល, ទួញរៀបរាប់" ចុ. ។ អา. **បริ-ទেวো នามญฺญาติญฺญสนาธีหิ ฉุฏฺฐสฺส ฯวชีปณาโถ** (វិសุទ្ធิមគ្គ៣/៨៩) ។
ទิวี	ធา.	**អฏฺฐเน (คนฺธปีสเน) ទেวেติ ទেวยติ** "បុក, កិនគ្រឿងក្រអូប" ចุ. ។

ទិស បុ. [ទិសិ + ស] អ្នកដែលបុគ្គលគប្បីសម្តែងឬគប្បីឃើញ (ចោរ) ។ ២-ជនជាសត្រូវ (ដូច **បច្ចនិក**) ។

ទិសម្បតិ បុ. ព្រះរាជាសាមញ្ញ (ដូច **ជនាធិប**) ។

ទិសា ឥ. [ទិស + អ + អា-ឥ] ទិស។ -**ចាមោក្ខាចរិយ** បុ. អាចារ្យជាប្រធានក្នុងទិស, អាចារ្យជាប្រមុខក្នុងទិស។ -**ភាគ** បុ. ទិសាភាគ, ចំណែកនៃទិស។ -**មុខ** បុ. អ.ន. ឈ្មោះទិសាមុខ។ -**ទាសិក** គុ. អ្នកនៅក្នុងទិសឬអ្នកមានកិ.នៅក្នុងទិសជាប្រក្រតី, វិ. **ទិសាយំ ភវតីតិ>ទិសាទាសី, ទិសាយំ ភវិតុំ សីលមស្សាតិ ទា> ទិសាទាសី, ទិសាទាសី ឯវ>ទិសាទាសិកោ**។ -**ទាសី** បុ.(មើល **ទិសាទាសិក**) ។ -**ទ្វិទិសា** ឥ. ទិសនិងទិសផ្សេងៗ, ទិសធំនិងទិសតូច។

ទិសិ ធា. **បេក្ខនេ ទក្ខតি បស្សតি ទិស្សតি ទិស្វា បស្សិត្វា ទិដ្ឋោ ទដ្ឋុំ បស្សិតុំ ទស្សនំ** " ឃើញ, មើល, ប្រាកដ,...″ ភូ. ។ ផ្លាស់ **ទិសិ** ជា **ទក្ខ** ជា **បស្ស** បាន។ កម្ម. **ទស្សីយតি**។ ការិត. **ទស្សេតি ទស្សយតি ទស្សេតុំ ទស្សិតោ** "ធ្វើឲ្យឃើញ, ចង្អុលប្រាប់, ពន្យល់ឲ្យឃើញ" ។ **ទិស្សតি** "ប្រាកដ" កត្តុវាចក:, ទិ.។ **ទិដ្ឋি** ឥ. "ទ្រឹស្តី, ទស្សន:, លទ្ធិ" ។ **ទិសា** ឥ. "ទិស" មានន័យ៤យ៉ាង៖១/ ទិសធំបាលីថា **ទិសា ចតស្សោ ទ្វិទិសា ចតស្សោ** ។២/ បុគ្គលទ. មានមាតាបិតាជាដើមឈ្មោះថា "ទិស" បាលីថា **មាតា បិតា ទិសា បុព្វា អាចរិយា ទក្ខិណា ទិសា បុត្តទារ ទិសា បច្ឆា មិត្តামচ্চা ច ឧត្តរ ទាសកម្មករ ហេដ្ឋា ឧទ្ធំ សមណព្រាហ្មណា** "មាតាបិតាទុកជាទិសខាងកើត គ្រូអាចារ្យទុកជាទិសខាងត្បូង កូនប្រពន្ធទុកជាទិសខាងលិច មិត្តអាមាត្យទុកជាទិសខាងជើង ខ្ញុំកំដរកម្មករទុកជាទិសខាងក្រោម ឯសមណព្រាហ្មណ៍ទុកជាទិសខាងលើ" ។ ៣/ អ្នកឲ្យបច្ច័យ៤ឈ្មោះថា "ទិស" បាលីថា **អគារិនោ អន្ធបាន-ភត្តទាទិសា ភវន្តি** "ទាយកទ.អ្នកប្រគេនបាយទឹកនិងសំពត់ដល់អ្នកបួសឈ្មោះថាទិស"។ ៤/ ព្រះនិព្វានក៏ឈ្មោះ ថា "ទិស" បាលីថា **ឯតា ទិសា ហិ សេតកេតុ យំ ហិ ត្វា និទ្ទុក្ខា សុខិនោ ភវន្តি** "បុគ្គលទ. ទៅដល់ទិសណាហើយជាអ្នកអស់ទុក្ខមានតែសុខទិសនុ៎ះឯងជាទិសឧត្តមក្រៃលែងមានតែទង់សគឺទង់សន្តិភាព" -ស. ។ **ញាណទស្សនំ** នបុ. "ការឃើញដោយញាណ, ការឃើញដោយវិបស្សនាញាណ" មានសេចក្តីសម្គាល់តាមផ្លូវធម៌ច្រើនយ៉ាង៖១/ ទិព្វចក្ខុញាណបាលីថា **អប្ប្ប្

៤/ ផល បាលីថា **ឧត្តរិមនុស្សធម្មោ អលមរិយញ្ញាណទស្សន-វិសេសោ**។ ៥/ បច្ច វេក្ខណញ្ញាណ បាលីថា **ញ្ញាណញ្ច បន មេ ទស្សនំ ឧទបាទិ អកុប្បា មេ ចេតោវិមុត្តិ** ។ ៦/ សព្វញ្ញុត ញ្ញាណ បាលីថា **ញ្ញាណញ្ច បន មេ ទស្សនំ ឧទបាទិ សត្តា-ហកាលកតោ អាលារោ កាលាមោ** -ស. ។ **ទក្ខិតាយ** "ដើម្បីយើញ, ដើម្បីមើល" អា. **អាគតម្ហ ឥមំ ធម្មសមយំ ទក្ខិតាយេវ អបរាជិតសង្ឆំ** "យើងទ. ជាអ្នកមកកាន់ធម្មសម័យនេះដើម្បីយើញពួកអ្នកមានជោគជ័យ" =**បស្សិតុំ**, -ស. ។ (ទិ+តាយ) **តាយេបច្ចយ** នេះនៅក្នុងពួក**តុំបច្ច័យ**គឺ **តុំ តវេ តុយេ តាយ** ជា អព្យយបច្ច័យ, អា. **បុច្ឆិតាយេម្ហ បញ្ហេ** "យើងទ. មកដើម្បីសួរប្រស្នាទ." (សរភង្គជាតក) ។ ២-**ហឺសាយ ទិសតិ** "បៀបបៀន" ភ្ជ. ។ ៣-**អាទានសំវរណេសុ ទិស្សតិ** "កាន់យក, សង្រ្ទម, ការពារ" ទិ. ភ្ជ. ។ ៤-**អតិសជ្ជនេ ទិសតិ** "ចាត់ចែង, រៀបចំ, ត្រៀមទុក" ភ្ជ. ។ **ឧបទិសតិ** "ណែនាំ, ប្រៀនប្រដៅ, បង្ហាញ" រូបដទៃ **ឧបទេសោ**។ **ឧទ្ទិសតិ** "ចាត់ចែងដោយសង្ខេប, សម្តែងដោយខ្ទីរូបដទៃ **ឧទ្ទេ-សោ**។ **និទ្ទិសតិ** "ចាត់ចែងដោយពិស្តារ, សម្តែងចេញ" រូបដទៃ **និទ្ទេសោ** "ការរៀបចំដោយពិស្តារ, ការចាត់ចេញ" ។ **បច្ចាទិសតិ** "ឃាត់បដិសេធ" រូបដទៃបច្ចាទេសោ (បដិ+អា+ទិ)។ **ទេសោ បទេសោ** បុ. "ប្រទេស, តំបន់ទីដែលគេរៀបចំ" -**ស**. ។ ៥-**អប្បីតិយំ ទេស្សតិ** "ស្ងប់, មិនពេញចិត្ត, គួរឲ្យខ្ពើម" ភ្ជ. ។ **ទិសោ** បុ. "ចោរ, សត្រូវ" ។ **ទិដ្ឋោ** បុ. "សត្រូវ, បច្ចាមិត្រ" (ទិ+ត) ។ សព្ទជាវេវចនៈ គឺ **បច្ចាមិត្តោ រិបុ ទិដ្ឋោ ទិសោ ភេរី សត្តុ អរិសបត្តោ** -ស. ។ **ទេស្សី** គុ. "អ្នកស្ងប់, មិនចូលចិត្ត, មិនពេញចិត្ត" អា. **ធម្មទេស្សី បរាភវោ**។ **ទេស្សោ ទេស្សិយោ** គុ. "ដែលស្ងប់, ខ្ពើម, មិនពេញចិត្ត" អា. **ន មេ ទេស្សា ឧភោ បុត្តា មជ្ឈិទេវី ន ទេស្សិយា** "ព្រះរាជបុត្រទាំង២យើងមិនស្ងប់មជ្ឈិទេវីក៏យើងមិនស្ងប់ដែរស. ។ ៦-**ឧជ្ជារណោ ទេសេតិ ទេសយតិ ទេសកោ ទេសេតា ទេសិតោ ទេសនា ទេសេត្វា ទេសេតុំ** "ទេសនា, ថ្លែង, សម្តែង, ពន្យល់ឲ្យយើញហេតុផល" ចុ.។ កម្ម. **ទេសីយតិ** ។ ការិត. **ទេសាបេតិ ទេសាបយតិ**។

ទិហ ធា. **ឧបចយេ ទេហតិ** "កសាង, សន្សំ" ភ្ជ. ។ **ទេហោ** បុ. "រាងកាយ, រូបរាង" ។ **សន្ទេហោ** បុ. "សេចក្តីសង្ស័យ" ។ **ទេហី** បុ. "សត្វ, បុគ្គល" ។

ទី ធា. **ខយេ ទីយតេ** "អស់, សូន្យ" ទិ.។ **ទីនោ** បុ. "អ្នកក្រ, អ្នកកម្សត់ទុគ្គិត" ។ **អទីនទោ** បុ. "ទោស,ទុក្ខ" ជាគ្រឿងដល់នូវទុក្ខ វិ. **អទីនំ ទុក្ខំ ទាតិ អធិគচ্ছতি ঠতেនាតি អទីនទោ** -ស. ។ **ទិវា** អព្យយសព្ទ វេលាថ្ងៃអស់ងងឹត។ **ទិវាករោ** បុ. "ព្រះអាទិត្យ" ធ្វើថ្ងៃ។

ទីឃ គុ. [ទិ + ឃ, ឥនៃទិ>ឦ] វែង, បណ្តោយ។ -**ការាយន** អ.ន. ឈ្មោះទីឃការាយន:។ -**ជាតិក** គុ. (សត្ត) មានជាតិដ៏វែង, ប្រកបដោយជាតិវែង, មានជាតិនៃសត្ត្វដ៏វែង (ពស់) (ពហុព្ជីហិ, និយុត្តតទ្ធិត, អត្ថិតទ្ធិត) ។ -**ទស្សី** បុ. អ្នកឃើញនូវកាលដ៏វែង, -អស់កាលដ៏វែង (ក.ក), អ្នកមានកិ.ឃើញនូវកាលដ៏វែងជាប្រក្រតី, - អស់កាលដ៏វែងជាប្រក្រតី (ស.ត) ។ -**ឆខបរិព្ជាជក** បុ. បរិព្ជាជកឈ្មោះទីឃនខ:។ -**និកាយាទិ** គុ. (និកាយ) មានទីឃនិកាយជាដើម (ពហុព្ជីហិ) ។ -**ភាវ** បុ. ភាវ:នៃ....ជា....ដ៏វែង។ -**មទ្ធាន** នបុ. កាលដ៏វែង, វេលាដ៏វែង។ -**មន្តរ** នបុ. ចន្លោះនៃកាលដ៏វែង, រវាងនៃកាលដ៏វែង។ -**រត្ត** នបុ. រាត្រីដ៏វែង, គុ. (កាល) មានរាត្រីដ៏វែង, វិ. **ទីឃា រត្តិ យស្ស សោ>ទីឃរត្តោ**។ -**លម្ពិកវាសី** បុ. អ្នកនៅក្នុងក្រុងឈ្មោះទីឃលម្ពិក:។ -**ទាឋី** អ.ន. ឈ្មោះទីឃវាបី (ចឹងដ៏វែង, ស្រះដ៏វែង) ។ -**សោត្តិយ** នបុ. ភាវ:នៃបុគ្គលអ្នកដេកលក់អស់កាលដ៏វែង, វិ. **សុត្តស្ស ភាវោ>សោត្តិយំ**។

ទីឃតា ឥ. វែង, កម្ពស់ (ដូច **អាវេហោ**) ។

ទីឃត្តំ នបុ. វែង, សព្ទនេះជាអត្ថនៃ **អាយតិ**សព្ទ ។

ទីឃបិដ្ឋិក បុ. សត្ត្វពស់សាមញ្ញ (ដូច **ឧរគោ**) ។

ទីឃលោមក បុ. ព្រំមានរោមវែង (ដូច **គោនក**) ។

ទីឃវណ្ណ បុ. ដើមពេកា (ដូច **សោនក**) ។

ទីឃសុត្ត គុ. អ្នកដែលធ្វើការងារយឺតយូរកន្លងទីបំផុតគ្មាន (ដូច **ចិរក្រិយ**)

ទីឃាទិយុត្ត-ដ្ឋាន នបុ. [ទីឃាទិយុត្ត + ឋាន] ទីដ៏គួរដល់ប្រមាណមានវែងជាដើម, មានអវយវ:វែងជាដើម។

ទីឃាយុក គុ. [ទីឃ + អាយុ + ក] មានអាយុវែង, វិ. **ទីឃំ អាយុ យេសំ តេ>ទីឃាយុកា**។ -**ពុទ្ធកាល** បុ. កាលនៃព្រះពុទ្ធមានអាយុវែង។

ទីឃាវុកុមារ បុ. [ទីឃាវុ + កុមារ] កុមារឈ្មោះទីឃាវុ។ -**ជាតក** នបុ. ជាតកគឺបណ្ឌិតកំណត់ហើយដោយកុមារឈ្មោះទីឃាវុ។

ទីឃីតិ អ.ន. ឈ្មោះ **ទីឃីតិ**។

ទីឆ ធា. **ទិត្តិទេវនេសុ ទីឆតិ** "រុងរឿង, ភ្លឺ,លេង" ភ្ល. ។ **ទីធិតិ** ឥ. "រស្មី, ពន្លឺ" ។សព្ទជាវេវចន:នៃពាក្យនេះ៖ **រស្មិ អាភា បភា រំសិ ទិត្តិ ភា រុចि ទីធិតិ ជុតि ភានុ អំសុ មយូខោ ភីរណោ ភណ្ដ-ធាមោ អាលោកោ** -**ស**. ។

ទីន បុ. អ្នកកម្សត់, អ្នកទ័លក្រ (ដូច **ឥ**ន) ។

ទីប បុ. [ទិប + ណ] (សភាវ:) រុងរឿងក្នុងកណ្ដាលនៃទឹក, (ទ្វីប, កោះ, ប្រទីប, ទីពឹងធម៌ជាទីពឹង), វិ. **ជលមជ្ឌេ ទិប្យតីតि>ទីបោ**។ ២-ព្រះនិព្វាន (ដូច **ឥ**ព្ភតि) ។

ទីបក បុ. ឆ្កែដែលព្រានបញ្ជូនទៅ, ឆ្កែដេញម្រឹគ (ដូច **ឧ**ត**ក** ឬ **ចេ**ត**ក**) ។

ទីបङ្ករ បុ. អ. [ទីបំ + ករ + អ] ព្រះពុទ្ធព្រះនាមទីបង្ករ (អ្នកធ្វើនូវធម៌ជាទីពឹង) ។ -ន. **ទ**ស**ពល** បុ. ព្រះទសពលព្រះនាមទីបង្ករ។ -**ចាទ**ម**ូ**ល នបុ. ប្រទេសជាទីតាំងនៃព្រះបាទនៃព្រះពុទ្ធព្រះនាមទីបង្ករ, ទីជិតនៃព្រះបាទនៃ...., បាទមូលនៃ....។

ទីបជាលា ឥ. [ទីប + ជាលា] អណ្ដាតនៃប្រទីប។

ទីបមូជា ឥ. [ទីប + បូជា] កិ.បូជាដោយប្រទីប។

ទីបភាសា ឥ. [ទីប + ភាសា] ភាសា (សម្ដី) នៃអ្នកកោះ, ភាសានៃជនអ្នកនៅក្នុងកោះ។

ទីបរុក្ខសហស្ស នបុ. [ទីបរុក្ខ + សហស្ស] ពាន់នៃដើមនៃប្រទីប។

ទីបសង្ខាត គុ. [ទីប + សង្ខាត] ពោលគឺកោះ, គឺបណ្ដិតពោលព្រមហើយថាកោះ, -ថាទីពឹង, -ថាទីពឹងដូចជាកោះ។

ទីបសាមិក គុ. [ទីប + សាមិក] អ្នកជាម្ចាស់នៃទ្វីប, -នៃកោះ។

ទីបសិខា ឥ. [ទីប + សិខា] អណ្ដាតនៃប្រទីប។

ទីបាលោក បុ. [ទីប + អាលោក] ពន្លឺនៃប្រទីប។

ទីបិនី ឥ. [ទីបិ + ឥនី] មេខ្លាដំបង។

ទីបេតព្ព គុ. [ទីបិ + អ, អ>ឯ + តព្ព] គឺ....គប្បីសម្ដែង។

ទីបេតិ កិ. [ទីបិ + អ, អ>ឯ + តិ-រ.] សម្ដែង។

ទីបេតុំ អ. [ទីបិ + អ + តុំ] ដើម្បីសម្ដែង។

ទីបេយ្យ កិ. [ទីបិ + អ + ឯយ្យ-ស.] គប្បីសម្ដែង។

ទីបោភាស បុ. [ទីប + ឱភាស] ពន្លឺនៃប្រទីប, រស្មីនៃប្រទីប។

ទីយិត្ត កិ. [ទា + យ + ត្ត-ហី., ចុះ-ឥ-អា.] គឺ.....ឲ្យហើយ។

ទុ ឧ. ជាឧបសគ្គប្រព្រឹត្តទៅក្នុងអត្ថគឺ **ករុច្ឆិត** គួរខ្ពើម, លំបាក ឧ. **ទុគ្គតំ**, **ទុក្ខំ**, -**ណ្ណ**ស តិចតួច ឧ. **អប្បកំ ភិក្ខុ យស្មឺ សោ>ទុណ្ណិក្ខো** បាយតិចក្នុងប្រទេសឯណា ប្រទេសនោះ ឈ្មោះថា ទុណ្ណិក្ខ ។ -**ទ្ធិ**ករ**ណ** ប្លែក, គួរខ្ពើម, អាក្រក់ ឧ. **ទ្ធិ**ករ**ណោ ទ**ណ្ណ**ោ យ**ស្ស **សោ>ទុ**ទ្ធ**ណ្ណ**ោ** សម្ប្ររនៃជនឯណាប្លែកឬគួរខ្ពើមឬអាក្រក់ជននោះឈ្មោះថា ទុទ្ធណ្ណ។ -**អ**សោ**ភ**ណ **ទ** មិនល្អ, អាក្រក់ឧ. **ទុ**ម្ម**ុ**ខោ ជនមានមុខអាក្រក់ ។ -**អ**ភ**ាវ** មិនមានស្ពួចស្ដើងឧ. **ទុ**ប្ប**ញ្ញ**ោ ជនគ្មានប្រាជ្ញា ។ -**អ**ស**មិ**ទ្ធ**ិ** មិនសម្រេចឧ. **ទុ**ស្ស**ស**្ស សន្ទូងខ្ជូចខាត, សន្ទូងអាក្រក់ ។ -**ភ**ិ**ច្ច** ក្រ, លំបាក ឧ. **ទ**ុ**ក្ករ**ំ អំពើដែលជនធ្វើបានដោយក្រ ។ -**អ**ន**ទ**ន **ទ** សេចក្ដីមិនត្រេកអរ ឧ. **ទ**ុ**ក្ខ**ី **ទ**ុ**ម្ម**ណោ ជនមានសេចក្ដីទុក្ខ មានចិត្តអាក់អន់, ត្ងួចចិត្ត។

ទុ ធ. ១-**ភ**ត**ិ**យ**ំ ទ**ាត**ិ** "ទៅ, ដល់, ប្រព្រឹត្តទៅ" ភូ. ។ **ទ**ុ**ហ**ោ បុ. "ដើមឈើ, ព្រឹក្សា"ឡើងទៅ"។ **ទ**ូ**ត**ោ បុ. "អ្នកដែលប្រើឲ្យទៅ, ទូត" ។ **ទ**ព្ធ**ំ** នបុ. "របស់, វត្ថុ, របស់ដ៏សមគួរ, ការមានឬជា, ទ្រព្យ, សម្បត្ដិ,ប្រាជ្ញា, ការចេះដឹង, ឈើ" ។ **ទ**ព្ធ**ี** ត. "ដែក" (**ស**ូ**ចិ**) ប៉ុន្ដែមោគ្គល្លាយន ព្រ៏ត្ដិ ពោលថា<**ទ**ារ**=ទ**ិ**ទ**ារ**ណ** "បំបែក, ញែក" ។ **ទ**ញ្ញ**ោ,ទ**ព្ធ**ំ** បុ. នបុ. "សេចក្ដីឆ្ងើងឆ្ម, ការក្រអឺតក្រទម" ។**ទ**ញ្ញ**ោ=អ**ហ**ङ्ङ**ារ**ោ។ ** ** **

អំពើគឺបុគ្គលធ្វើបានដោយលំបាក។

ទុក្ខ នបុં.,គុ. [ទុ + ខមិ + រ] (ធម្មជាត) ដែលជនអត់ទ្រាំបានដោយកម្រឬកិ.អត់ទ្រាំបានដោយកម្រ (ទុក្ខ, សេចក្តីព្រួយ, សេចក្តីលំបាក), រិ. **ទុដ្ឋ ខមិយតេតិ>ទុក្ខំ** , **ទុដ្ឋ ខមយតេតិ ឥ>ទុក្ខ**ំ។ -**ការណ** នបុં. ហេតុនៃទុក្ខ។ -**ក្ខន្ធសុត្តាទិឥស** បុં. អំណាចនៃសូត្រមានទុក្ខក្ខន្ធសូត្រជាដើម។ -**ជ្ជបន** នបុં. កិ.តាំងទុកនូវទុក្ខ, កិ.តម្កល់ទុកនូវទុក្ខ។ -**តា** ឥ. ភាវ:នៃ....នោះជា...នាំមកនូវទុក្ខ។ - **តោ** អ. ដោយសេចក្តីថាជាទុក្ខ, ដោយសេចក្តីថាអត្តភាពនាំមកនូវទុក្ខ។ -**និស្សរណ** នបុં. (ធម្មជាត) ជាគ្រឿងរលាស់ចេញចាកនូវទុក្ខ, ឬ (**ឥណជាត**) ជាគ្រឿងចេញចាកទុក្ខ (**និស្សរណ**<និ + សរ + យុ), រិ. **និស្សរន្តិ និគច្ឆន្តិ ឯតេនាតិ> និស្សរណំ**, **ទុក្ខស្ស និស្ស-រណំ>ទុក្ខនិស្សរណំ**។ -**បរិជានឥ្ឌាទិកិច្ច** នបុं. កិច្ចមានកិ.កំណត់ដឹងនូវទុក្ខជាដើម។ -**បរិញ្ញាទិ** គុ. (ធម្មជាត) មានកិ.កំណត់ដឹងនូវទុក្ខជាដើម។ -**បរិត្តាណ** នបុं. (ធម្មជាត) ជាគ្រឿងការពារនូវទុក្ខ (**បរិត្តាណ**<បរិ + តា + យុ = កិ.រក្សាជុំវិញ, កិ.ការពារ)។ -**ឧរេត** គុ. គឺទុក្ខប្រព្រឹត្តទៅក្នុងខាងមុខហើយ, គឺទុក្ខគ្របសង្កត់ហើយ (**ឧរេត**<ឧរ + ឥ + ត) ។ -**ឫត្ត** គុ. អ្នកដល់ហើយនូវទុក្ខ, អ្នកមានទុក្ខដល់ហើយ។ -**ឫឡិតសត្តឥត្ត** នបុं. រឿងនៃសត្វគឺទុក្ខបៀតបៀនហើយ។ -**ផល** នបុं. ផលជាទុក្ខ, គុ. មានផលនាំមកនូវសេចក្តីទុក្ខ។ -**លក្ខណ** នបុं. ទុក្ខលក្ខណ:, ធម្មជាតជាគ្រឿងកំណត់ថាសង្ខារជាធម៌នាំមកនូវទុក្ខ។ -**សមុឫាន** បុं. ធម៌ជាទីកើតឡើងព្រមនៃទុក្ខ, ធម៌ជាទីញ៉ាំងទុក្ខឲ្យកើតឡើងព្រម, សមុទ័យជាទីកើតព្រមនៃទុក្ខ។ -**សំឥត្តនិក** គុ. ប្រកបក្នុងកិ.ប្រព្រឹត្តទៅព្រមដើម្បីទុក្ខ, ប្រកបក្នុងកិ.ញ៉ាំងទុក្ខឲ្យប្រព្រឹត្តទៅព្រម, មានកិ.ប្រព្រឹត្តទៅព្រមដើម្បីទុក្ខ។

ទុក្ខក្ខយ បុं. ព្រះនិព្វាន។

ទុក្ខាទិ គុ. [ទុក្ខ + អាទិ] (សច្ច:) មានទុក្ខសច្ច:ជាដើម។

ទុក្ខានុបតិត គុ. [ទុក្ខ + អនុបតិត] អ្នកគឺទុក្ខធ្លាក់តាមហើយ។ -**ភាឥ**បុं. ភាវ:នៃ..... ជាអ្នកគឺទុក្ខធ្លាក់តាមហើយ។

ទុក្ខានុភវន នបុं. [ទុក្ខ + អនុភវន] កិ.រងនូវទុក្ខ, កិ.សោយនូវទុក្ខ។

ទុក្ខាភិភូត គុ. [ទុក្ខ + អភិភូត] អ្នកគឺទុក្ខគ្របសង្កត់ហើយ, -ជិះជាន់ហើយ, វិ. **ទុក្ខេន អភិភូតោ>ទុក្ខាភិភូតោ**។

ទុក្ខាវហ គុ. [ទុក្ខ + អាវហ] នាំមកនូវទុក្ខ, ជាទីនាំមកនូវសេចក្តីទុក្ខ។

ទុក្ខិត គុ. [ទុក្ខ + ឥ + ត] អ្នកលំបាក, វិ. **ទុក្ខតីតិ>ទុក្ខិតោ**, អ្នកប្រព្រឹត្តទៅដោយសេចក្តីទុក្ខ, -ដោយសេចក្តីលំបាក, វិ. **ទុក្ខេន ឥតោ បវត្តោតិ>ទុក្ខិតោ** , អ្នកដល់ហើយនូវសេចក្តីទុក្ខ, វិ. **ទុក្ខំ ឥតោ គតោតិ>ទុក្ខិតោ**។ -**កាល** បុ. កាលនៃ....ជាអ្នកដល់ហើយនូវសេចក្តីទុក្ខ។

ទុក្ខី គុ. [ទុក្ខ + ណ្ឍ] អ្នកមានទុក្ខ, វិ. **ទុក្ខំ យស្ស អត្ថីតិ>ទុក្ខី**។ ឥ. **ទុក្ខិនី**។

ទុក្ខីយតិ កិ. [ទុក្ខ + ណ្ឍយ + តិ-រ.] ប្រព្រឹត្តនូវសេចក្តីទុក្ខ, ប្រាជ្ញានូវសេចក្តីទុក្ខ។

ទុក្ខុទ្រិយ គុ. [ទុក្ខ + ឧទ្រិយ] (កម្ម) មានទុក្ខជាកម្រៃ, ជាគ្រឿងចម្រើនដោយទុក្ខ។

ទុក្ខុបទ្ទវ បុ. [ទុក្ខ + ឧបទ្ទវ] ឧបទ្រពគឺទុក្ខ, អន្តរាយចូលទៅបៀតបៀនគឺទុក្ខ ។

ទុក្ខុប្បត្តិ ឥ. [ទុក្ខ + ឧប្បត្តិ] កិ.កើតឡើងនៃទុក្ខ។

ទុក្ខូបសមគាមី គុ. [ទុក្ខូបសម+គមិ+ណី] មានកិ.ដល់នូវនិព្វានជាទីចូលទៅរម្ងាប់នូវទុក្ខជាប្រក្រតី, ដល់នូវធម៌ជាគ្រឿងចូលទៅរម្ងាប់នូវទុក្ខ (ស. ត. , ក.ក) ។

ទុក្ខ ធា. **ឥក្ខិរិយាយំ ទុក្ខតិ ទុក្ខំ ទុក្ខី** "ជាទុក្ខ, លំបាក" ភូ. ។ ការិត. **ទុក្ខេតិ ទុក្ខាបេតិ**។ **ទុក្ខិតោ** គុ. មានរូបវិគ្គហ:៣យ៉ាង៖
១/ **ទុក្ខតីតិ ទុក្ខិតោ** (ទុ+ក្ខ+ឥ+ត) កត្តុ. កត្តុសាធន:។
២/**ទុក្ខំ សញ្ញាតំ ឯតស្សាតិ ទុក្ខិតោ** (ទុ+ក្ខ+ឥតបច្ច័យ សញ្ញាតតទ្ធិត)។
៣/ **ទុក្ខេន ឥតោ បវត្តោតិ ទុក្ខិតោ** (ត្ថតិយាតប្បុរិស) -ស. ។

ទុគ្ត គុ. [ទុ+គមិ+រ] (ទី) ដែលមានសត្វទៅបានដោយលំបាកឬ(ទី) ដែលបុគ្គលគប្បីទៅបានដោយលំបាក (ផ្លូវលំបាក), វិ. **ទុដ្ឋុ គមយតេតិ> ទុគ្គំ, ទុដ្ឋុ គមិតព្ពន្តិ ឥ>ទុគ្គំ**។

ទុគ្គត គុ. [ទុ + គមិ + ត] អ្នកដល់ហើយនូវសេចក្តីលំបាក (អ្នកកម្សត់, អ្នកក្រីក្រ, អ្នកទាល់ក្រ, អ្នកទុគ្គិត), វិ. **ទុក្ខំ គតោតិ>ទុគ្គតោ**។ -**កាល** បុ. កាលនៃ....ដល់ហើយនូវសេចក្តីលំបាក, កាលនៃ....ជាអ្នកទុគ្គិត, -ជាអ្នកកម្សត់។ -**គហបតិកុល** នបុ. ត្រកូលនៃគហបតីអ្នកដល់ហើយនូវសេចក្តីលំបាក, ...។ -**ករ** គុ. អ្នកដល់ហើយនូវសេចក្តីលំបាកជាង, អ្នកទុគ្គិតជាង។ -**បណ្ណ្ណាការ**បុ. បណ្ណ្ណាការ (ជំនួន) នៃបុគ្គលអ្នកទុគ្គិត។ -**ព្រាហ្មណ** បុ. ព្រាហ្មណ៍អ្នកដល់ហើយនូវសេចក្តីលំបាក។ -**ភាវ** បុ. ភាវ:នៃ....ជាអ្នកទុគ្គិត។ -**មនុស្ស** បុ. មនុស្សអ្នកដល់ហើយនូវសេចក្តីលំបាក, មនុស្ស

ទុគ៌ត, មនុស្សកម្សត់។

ទុគ្គតិ ឥ. [ទុ + គតិ] គតិអាក្រក់, ដំណើរអាក្រក់, វិ. **ទុដ្ឋុ គតិ>ទុគ្គតិ**។ -**បរាយណ** គុ. អ្នកមានទុគ្គតិជាទីប្រព្រឹត្តទៅក្នុងខាងមុខ, វិ. **ទុគ្គតិ បរាយណា យេសំ តេ> ទុគ្គតិបរាយណា**។ ២-នរក (ដូច**និរយោ**) ។

ទុគ្គន្ធ បុં. [ទុ+គន្ធ] ក្លិនអាក្រក់, ក្លិនស្អុយ, គុ. មានក្លិនអាក្រក់, មានក្លិនស្អុយ។ -**ករ** គុ. មានក្លិនអាក្រក់ជាង, មានក្លិនស្អុយជាង។ -**មុខ** គុ. មានមាត់មានក្លិនអាក្រក់, មានក្លិនអាក្រក់ក្នុងមាត់។

ទុគ្គហិត គុ. [ទុ + គហ៊ + ឥ-អា. + ត] គឺបុគ្គលចាប់យកអាក្រក់ហើយ, -ចាប់យកដោយអាក្រក់, -ចាប់មិនល្អ, -កាន់មិនល្អ។

ទុគ្គុណតេជ បុં. [ទុគ្គុណ + តេជ] តេជៈនៃបុគ្គលអ្នកមានគុណដ៏អាក្រក់, -មានតេជៈគឺគុណគឺទោសប្រទូស្តហើយ។

ទុគ្ត នបុં. ផ្លូវលំបាក, ប៉ម, បន្ទាយជាអង្គរបស់រាជ្យម្យ៉ាង។

ទុច្ចរិត នបុં. [ទុ + ចរិត ឬ ចរ + ឥ-អា + ត] កិ.ប្រព្រឹត្តអាក្រក់, វិ. **ទុដ្ឋុ ចរិតំ> ទុច្ចរិតំ**, គុ. (កម្ម) ដែលបុគ្គលប្រព្រឹត្តអាក្រក់, **ទុដ្ឋុចរិយតេតិ> ទុច្ចរិតំ**។ -**កម្ម** នបុं. កម្មដែលបុគ្គលប្រព្រឹត្តអាក្រក់ហើយ។ -**ប្បវេសន** នបុं. កិ. ចូលទៅនៃទុច្ចរិត, កិ. ញ៉ាំងទុច្ចរិតឲ្យចូលទៅ។ -**ផលានុភាព** បុं. អានុភាពនៃផលនៃទុច្ចរិត។

ទុច្ចរិតានុភាព បុं. [ទុច្ចរិត + អានុភាវ] អានុភាពនៃទុច្ចរិត, -នៃកិ.ប្រព្រឹត្តអាក្រក់, -នៃកម្មដែលបុគ្គលប្រព្រឹត្តអាក្រក់ហើយ។

ទុច្ឆន្ន គុ. [ទុ + ឆទ + ត, ត>អន្ន, លុបទីបំផុតធាតុ] គឺបុគ្គលប្រក់អាក្រក់ហើយ, -ប្រក់មិនល្អហើយ។ - **គេហសទិស** គុ. ប្រាកដស្មើដោយផ្ទះដែលបុគ្គលប្រក់មិនល្អហើយ។

ទុច្ឆវិ ឥ. [ទុ + ឆវិ] សម្បុរថ្លៃដ៏អាក្រក់, មានសម្បុរថ្លៃដ៏អាក្រក់។ -**រោគ** បុं. រោគកើតក្នុងសម្បុរថ្លៃដ៏អាក្រក់, រោគដែលកើតត្រង់ស្បែកសម្បុរថ្លៃដ៏អាក្រក់រោគក្នុងសម្បុរថ្លៃដ៏អាក្រក់។

ទុច្ឆិន្ទិយ គុ. [ទុ+ឆិទ+ណ្យ+ឥ-អា.+និ-អា.] គឺ...គប្បីកាត់បានដោយលំបាក, -ដោយកម្រ។

ទុជ្ជរ គុ. រឹងប៉ឹង, សព្ទនេះជាអត្ថនៃ **ភរ** សព្ទ ។

ទុជ្ជាត គុ. [ទុ + ជនិ + ត] កើតអាក្រក់ហើយ, កើតមិនល្អ, មានជាតិអាក្រក់។

ទុជ្ញាន គុ. [ទុ + ញា + យុ] គឺបុគ្គលដឹងបានដោយកម្រ, -ដោយលំបាក។

ទុជ្ជិត គុ. [ទុ + ជិ + ត] គឺ....ឈ្នះបានដោយកម្រ, -បានដោយលំបាក។

ទុជ្ជីវ បុ., គុ. [ទុ+ជីវ+អ] កិ.រស់នៅដោយលំបាក, -ដោយកម្រ, -ដោយត្រដាបត្រដួស, គឺ....រស់នៅដោយលំបាក, វិ. **ទុក្ខេន ជីវោ>ទុជ្ជីវោ**។

ទុជ្ជីវិត នបុ., គុ. [ទុ + ជីវិត] រស់នៅដោយលំបាក, -ដោយកម្រ, -ដោយត្រដាបត្រដួស, គឺ....រស់នៅបានដោយលំបាក, វិ. **ទុក្ខេន ជីវិតំ>ទុជ្ជីវិតំ**។

ទុដ្ឋ គុ. [ទុសិ + ត] គឺទោសប្រទូស្តហើយ, បុគ្គលគឺទោសប្រទូស្តហើយ, អាក្រក់, កាច, កំណាច។ -**ក្ខុដ្ឋិ** អា.បុ. នៃបុរសមានរោគឃ្លង់កំណាច, ម្នាលបុរសមានរោគឃ្លង់គឺទោសប្រទូស្តហើយ (នៃអាគម្លង់កំណាច) ។ -**គាមណិរាជ** បុ. ព្រះរាជាព្រះនាមទុដ្ឋគាមណិ។ -**ចោរ** បុ. ចោរកំណាច, ចោរគឺទោសប្រទូស្តហើយ។ -**តិត្ថិយ** បុ. តិត្ថិយកំណាច, តិត្ថិយអាក្រក់, តិត្ថិយគឺទោសប្រទូស្តហើយ។ -**ទាសិ** អា.ឥ ម្នាលទាសីកំណាច, ម្នាលទាសីអាក្រក់។ -**ឆហាបិត** បុ. ជាងកំណែរកំណាច, -អាក្រក់។ -**បុត្ត** បុ. កូនកំណាច, កូនអាក្រក់។ -**ឍោតក** បុ. កូនកំណាច, កូនកាច, កូនអាក្រក់។ -**ហត្ថី** បុ. ដំរីកំណាច, ដំរីកាច។ -**ហត្ថិឍោតក** បុ. កូននៃដំរីកាច, -កាច, -ដំរីកាច។

ទុដ្ឍ និ. **និន្ទាត្ថវាចក:** និបាតប្រាប់អត្ថគឺតិះដៀល ប្រែថា អាក្រក់, កុច្ឆាត្ថវាចក:និបាតប្រាប់អត្ថគឺកាច, គួរខ្ពើម, **ក្ខ** ក៏ជាកុច្ឆាត្ថវាចក:ដែរ។

ទុដ្ឍបេន្ត គុ. [ទុ+ឋ+អ, អ>ឯ+អន្ត] កាលតាំងទុកមិនល្អ, កាលទុកដាក់មិនល្អ។

ទុណ ធា. **ហឹសាគតីសុ ទុណតិ** "បៀតបៀន, ទៅ, ដល់, ប្រព្រឹត្តទៅ" ភ្ជ. ។

ទុតិយ បូ.សំ. [ទ្វि>ទុ+តិយ] ទីពីរ, គម្រប់ពីរ។ -**គាថា** ឥ. គាថាទីពីរ, -គម្រប់ពីរ។

គុ. -**ជ្ឈាន** នបុ. ឈានទីពីរ, -គម្រប់ពីរ។ -**ឥតិយអត្តភាព** បុ. អត្តភាពទីពីរនិងអត្តភាពទីបី។ -**ទិវស** បុ. នបុ. ថ្ងៃទីពីរ, -គម្រប់ពីរ។ -**ឋានទ្វិក្ខេប** បុ. កិ.ឈានទៅនៃជើង (ជំហាន) ទីពីរ, -គម្រប់ពីរ។ -**ផល** នបុ. ផលទីពីរ, គម្រប់ពីរ។ -**ទាស** បុ. ខែទីពីរ, -គម្រប់ពីរ។ -**ទារ** បុ. ទារ: (លើក, ផេន) ទីពីរ, -គម្រប់ពីរ។ -**សទ្ទ** បុ. សំឡេង (ស្ងរ) ទីពីរ, -គម្រប់ពីរ។ -**សាវកជ្ឈាន** នបុ. ទីនៃសាវ័កទីពីរ, -គម្រប់ពីរ។

ទុតិយា ឥ. ប្រពន្ធ (ដូច **ឥរិយា, ឧជាបតិ**) ។

ទុតិយាសន នបុ. [ទុតិយ + អាសន] អាសន:ទីពីរ, -គម្រប់ពីរ។

ទុទ្ធន គុ. [ទុ + ទា-ទា + អ] គឺ....ឲ្យបានដោយលំបាក, -ដោយកម្រ, វិ. **ទុក្ខេន ទធីយតីតិ >ទុទ្ធនោ**។

ទុទ្ធម គុ. [ទុ + ទមិ + ខ] (ជន) គឺបុគ្គលទូន្មានបានដោយលំបាក, -ដោយកម្រ, វិ. **ទុដ្ឋ ទមិយតេតិ>ទុទ្ធមោ**។

ទុទ្ធស គុ. [ទុ + ទិសិ + ខ] (ទោស) គឺបុគ្គលឃើញបានដោយលំបាក, -ដោយកម្រ, វិ. **ទុដ្ឋ ទស្សិយតេតិ>ទុទ្ធសំ**។

ទុទ្ធិដ្ឋិ គុ. [ទុ + ទិដ្ឋិ] មានទិដ្ឋិអាក្រក់, មានកិ.ឃើញអាក្រក់។

ទុទ្ធិន នបុં. ថ្ងៃដែលត្រូវភ្លៀងបិទបាំង, ថ្ងៃដែលអាប់ងងិតដោយមេឃភ្លៀង។

ទុទ្ធ នបុં. ទឹកដោះស្រស់ (ដូច **ខីរ**) ។

ទុទ្ទុភិ បុં. ឥ. ស្គរ (ដូច **ភេរិ**) ។

ទុន្ទាមក នបុં. ឫសដូងដុះ (ដូច **អរិស**) ។

ទុន្ទិក្ខត្ត គុ. [ទុ + និក្ខិត្ត] គឺ...ទុកមិនល្អហើយ, គឺ...ទុកដាក់មិនល្អហើយ។

ទុន្ទិគ្គហ គុ. [ទុ + និគ្គហ] គឺបុគ្គលសង្កត់សង្កិនបានដោយលំបាក, គឺ...ផ្ទុញផ្ទាល់បានដោយលំបាក, -ដោយកម្រ , វិ. **ទុក្ខេន និគ្គហោ> ទុន្ទិគ្គហោ**។

ទុន្ទិវត្ថ គុ. [ទុ + និវត្ថ] គឺ....ស្លៀកមិនល្អហើយ, គឺ....ស្លៀកអាក្រក់ហើយ, គឺ...ស្លៀកមិនស្រួលហើយ។ -**ទុប្ប្យារុតទស្សន** នបុં. កិ.ឫការសម្តែង (បង្ហាញ) នូវសំពត់ដែលខ្លួនស្លៀកមិនល្អហើយនិងសំពត់ដែលខ្លួនដណ្តប់មិនល្អហើយ។

ទុន្ទិវារយ គុ. [ទុ+និ+រ+ណ្យ] គឺ...គប្បីហាមបានដោយលំបាក, -ដោយកម្រ, គឺ...ឃាត់បានដោយលំបាក, -ដោយកម្រ។

ទិបទុត្តម បុំ. ព្រះនាមព្រះពុទ្ធជាម្ចាស់។

ទុប្ប ញ្ញ គុ. [ទុ+បញ្ញា] អ្នកមានបញ្ញាអាក្រក់, អ្នកឥតបញ្ញា។ -**ការ** នបុं. កម្មនៃបុគ្គលអ្នកមានបញ្ញាអាក្រក់, -អ្នកឥតបញ្ញា។ -**ភេជ** នបុं. ភេជ:នៃ... ។

ទុប្ប ដិបន្ន គុ. [ទុ + បដិ + បទ + ត] គឺបុគ្គលដើរទៅបានដោយលំបាក, -ដោយកម្រ, ដែលបុគ្គលប្រតិបត្តិមិនល្អហើយ។

ទុប្ប ដិហត-ញ្ញាណ គុ. [ទុ+ប្ប ដិហត + ញ្ញាណ] អ្នកមានញ្ញាណ (បញ្ញា) គឺអ្វីនីមួយខ្ទាំងខ្ទប់មិនបានហើយ, -ជៀតជៀនតបមិនបានហើយ។

ទុប្ប ដ្ដ ចីវរ នបុं. [ទុ+ប ដ្ដ+ចីវរ] ចីវរមានពីរជាន់, មានផ្ទាំងពីរ (**ទុ+ប ដ្ដ<ទ្វិ>ទ្ធ**) ។

ទុប្ប ព្ជ ជ ឥ. [ទុ + ប ព្ជ ជ] កិ.ចូលបានដោយលំបាក, -ដោយកម្រ (ក្នុងខ្លះ ប្រើជានបុं. ក៏មាន) ។

ទុប្ប ម ញ្ញ គុ. [ទុ+ប ម ញ្ញ] គឺ....ស្រាយ (ដោះ) បានដោយលំបាក, -ដោយកម្រ។

ទុប្ប រាម ដ្ឋ គុ. [ទុ+ប រាម ដ្ឋ] គឺបុគ្គលពាល់ត្រូវ (ស្ទាបអង្អែល, ចាប់, កាន់) មិនល្អហើយ។

ទុប្ប ូ ណ គុ. [ទុ + ប ូ + ណ] គឺយរ៉ាវ៉ាសឲ្យពេញបានដោយលំបាក, គឺ...បំពេញបានដោយកម្រ, -ដោយលំបាក។

ទុប្ប្ឫរណត្ថ បុ. [ទុប្ប្ឫរណ + អត្ថ] អត្ថគឺកិ.បំពេញបានដោយលំបាក, -ដោយកម្រ, សេចក្ដីគឺ....ឲ្យពេញបានដោយកម្រ។

ទុម្ផស្ស គុ. របស់ដែលមានផស្ស:អាក្រក់, សព្ទនេះជាអត្ថនៃ **ខរ** សព្ទ ។

ទុផស្ស បុ. ខ្ទេរ (ដូច **ឧបិកច្ឆ**) ។

ទុឆ ធា. **ឧបក្ខិលេសេ ឆោជតិ** "សៅហ្មង, ប្រឡាក់ប្រឡ្ងស" ភូ. ។

ទុញ្ហ ឥ. ស្មៅចិញ្ចៀន (ដូច **សន្ធ្ឫ**) ។

ទុញ្ហមិ កិ. [ទុ ព្ភ + អ + មិ-រ.] ប្រទូស្ត, បៀតបៀន។

ទុក្ខ គុ. [ទុ + ភិក្ខា] មានភិក្ខា (បាយ) គឺបុគ្គលបានដោយលំបាក, -ដោយកម្រ (ទុរភិក្ស),រ. **ទុល្ភភ ភិក្ខា យស្មឺ សោ>ទុព្ភិក្ខោ**។ -**ភាណ** បុ. កាលមានបាយគឺបុគ្គលបានដោយក្រ, កាលនៃ...មានបាយគឺ.....។ -**ភយ** នបុ. ភ័យគឺទុរភិក្ស, ភ័យកើតអំពីទុរភិក្ស, ភ័យគឺភិក្ខាដែលបុគ្គលបានដោយលំបាក, -ដោយកម្រ, ភ័យកើតអំពីភិក្ខាដែល..... ។

២-**គតিយं បលេតি បលយតি** "ទៅ, ដល់, ប្រព្រឹត្តទៅ" ចុ. ។ អា. **បលេតি រសមាទាយ** "ត្រឹបយកទឹកដមហើរទៅ" -ស. ។

បវដ្ដមាន គុ. [ប+រដ្ដ+អ+មាន] កាលវិលទូទៅ, កាលបម្រះននៀល, កាលប្រមៀល។

បវដ្ដិត្វា អ. [ប+រដ្ដ+ឥ-អា.+ត្វា] វិលទូទៅហើយ, បម្រះননៀលហើយ។

បវដ្ដេន្ត គុ. [ប+រដ្ដ+ណ+អន្ត] កាលវិលទៅ, កាលបម្រះননៀល។

បវដ្ដេសិ កិ. [ប+រដ្ដ+ណ+ណ្ឌ-អជ្ជ., ចុះស-អា.] ញ៉ាំង...ឱ្យវិលទៅហើយ, ឱ្យបម្រះননៀលហើយ។

បវឌ្ឍតি កិ. [ប+រ+ឍ+អ+តি-រ.] ចម្រើនទូទៅ, ចម្រើន, រុងរឿង។

បវឌ្ឍន្តি កិ. [ប+រ+ឍ+អ+អន្តি-រ.] ចម្រើនទូទៅ, ចម្រើន។

បវត្ត គុ. [ប+រ+ត+អ] ប្រព្រឹត្តទៅហើយ, ដែលប្រព្រឹត្តទៅហើយ។ -**ចេតនា** ឥ. ចេតនាដែលប្រព្រឹត្តទៅហើយ។ -**ដ្ឋាន** នបុं. ទីនៃ...ប្រព្រឹត្តទៅហើយ។ -**សិនេហាទស** បុं. អំណាចនៃសេចក្ដីស្នេហាប្រព្រឹត្តទៅហើយ, អំណាចនៃសេចក្ដីស្រឡាញ់...។

បវត្តតি កិ. [ប+រ+ត+អ+តি-រ.] រមែងប្រព្រឹត្តទៅ។

បវត្តន្ត គុ. [ប+រ+ត+អន្ត] កាលប្រព្រឹត្តទៅ, កំពុងប្រព្រឹត្តទៅ។

បវត្តមាន គុ. [ប+រ+ត+អ+មាន] កាលប្រព្រឹត្តទៅ, កំពុងប្រព្រឹត្តទៅ។

បវត្តយមាន គុ. [ប+រ+ត+ណយ+មាន] កាលញ៉ាំង...ឱ្យប្រព្រឹត្តទៅ។

បវត្តយីសុ កិ. [ប+រ+ត+ណយ+ឧं-អជ្ជ.] ញ៉ាំង...ឱ្យប្រព្រឹត្តទៅហើយ។

បវត្តារं គុ. [ប+រ+ទ+តុ, ទ>ត, ត+តុ>ត្តុ+អं-រ, ឧនៃត្តុ>អារ] អ្នកពោល, អ្នកប្រាប់, អ្នកបង្ហាញ។ ក្នុងអដ្ឋកថាយើញចេញទៅជាឆដ្ឋីវិភត្ដិ ពហុវចន:ជា **អាចិក្ខន្តានं** គួរតែជា **អាចិក្ខន្តារं** ឬ **អាចិក្ខនं** ឬក៏យ៉ាងណា? សូមផ្ញើមតិនេះលើវេយ្យាករណបណ្ឌិតទូទៅ។

បវត្តិ ឥ. [ប+វត+ ឬវតុ+តិ] កិ.ប្រព្រឹត្តិទៅ, ដំណើរប្រព្រឹត្តិទៅ (ដំណឹង, រឿង, ប្រវត្តិ, បវត្តិកាល, វេលាជាទីប្រព្រឹត្តិទៅ, ហេតុជាទីប្រព្រឹត្តិទៅ); វិ. **បវត្តនំ>បវត្តិ**។ -**ជ្ញានត្ថំ** ដើម្បីកិដឹងនូវដំណឹង, នូវហេតុជាទីប្រព្រឹត្ត។ -**ស្សវនដ្ឋាន** នបុં. ទីជាទីឮនូវដំណឹង។

បវត្តិត គុ. [ប+វត្តិ+ឥ-អា.+ត] ដែល...ឱ្យប្រព្រឹត្តទៅហើយ, គឺ...ឱ្យប្រព្រឹត្តទៅហើយ។ -**បវរធម្មចក្ក** គុ. មានចក្រគឺធម៌ដ៏ប្រសើរដែល...ឱ្យប្រព្រឹត្តទៅហើយ; វិ. **ធម្មោ ឯវ ចក្កំ>ធម្មចក្កំ, បវរំ ធម្មចក្កំ> បវរធម្មចក្កំ, បវត្តិតំ បវរធម្មចក្កំ យេន សោ>បវត្តិត-ប្បវរធម្មចក្កោ**។ មានធម៌ដូចជាចក្រដ៏ប្រសើរដែល...ឱ្យប្រព្រឹត្តទៅហើយ; វិ. **ធម្មោ ចក្កំ ឥវ>ធម្មចក្កំ**,...(ក្រៅពីនេះដូចខាងដើម) ។

បវត្តិត្ត កិ. [ប+វត្តិ+អ+ត្ត-ហី, ចុះឥ-អា.] ប្រព្រឹត្តទៅហើយ។

បវត្តិស្សតិ កិ. [ប+វត្តិ+អ+ស្ស្ត-ភ., ចុះឥ-អា.] នឹងប្រព្រឹត្តទៅ។

បវត្តេត្វា អ. [ប+វត្តិ+ណេ+ត្វា] ញ៉ាំង...ឱ្យប្រព្រឹត្តទៅហើយ។

បវត្តេថ កិ. [ប+វត្តិ+ណេ+ថ-ប.] ចូរញ៉ាំង...ឱ្យប្រព្រឹត្តទៅ។

បវត្តេន្ត គុ. [ប+វត្តិ+ណេ+អន្ត] កាលប្រព្រឹត្តទៅ, កាលញ៉ាំង...ឱ្យប្រព្រឹត្តទៅ។

បវត្តេសិ កិ. [ប+វត្តិ+ណេ+ល្ស-អជ្ជ. ចុះស-អា.] ញ៉ាំង...ឱ្យប្រព្រឹត្តទៅហើយ។

បវន នបុំ. [ប+វន] ព្រៃជាប្រធាន (ព្រៃធំ, ព្រៃស្បាត); វិ. **បធានំ ឯនំ>បវនំ**។ បុំ. ខ្យល់ (ដូច **មារុត**) ។

បវរ គុ. [ប+វរ] ប្រសើរទូទៅ, ប្រសើរបំផុត, (ថាត្រឹមតែ «ប្រសើរ» ក៏បាន) ។

បវស្សិ កិ. [ប+វស្សិ+អ+ល្ស-អជ្ជ.] ធ្លាក់ចុះទូទៅហើយ, បង្អុរចុះហើយ។

បវហណ នបុំ. ទូកតូច, សំប៉ាន (ដូច **ចោត**) ។

បវាយតি កិ. [ប+វេ+អ+តি-រ.] ផ្សាយទៅ, បក់ទៅ, ជាត់ទៅ។

បវារណ ឥ. [ប+រ+យុ+អា-ឥ.] តិចីជាទីញ៉ាំងសង្ឆឱ្យប្រាថ្នាទូទៅ, ឱ្យត្រេកអរទូទៅ (បវារណា, បវារណាកម្ម); វិ. **បវារេតি ឯតិស្សាតি> បវារណ** (តិចី) ។

បវារិត គុ. [ប+រ+ណេ+ត, ចុះឥ-អា.] គឺ...បវារណាហើយ, គឺ...ឱ្យបវារណាហើយ។

បវារេតព្ព កិ. [ប+រ+ណេ+តព្ព] គឺ...គប្បីញ៉ាំង...ឱ្យប្រាថ្នាទូទៅហើយ, គឺ...គប្បីបវារណា។

បវារេត្វា អ. [ប+រ+ណេ+ត្វា] បវារណាហើយ, ញ៉ាំង...ឱ្យប្រាថ្នាទូទៅហើយ។

បវារេសិ កិ. [ប+រ+ណ+ណ-អជ., ចុះ-អា.] បវារណាហើយ, ញ៉ាំង...ឱ្យ ប្រាថ្នាទូទៅហើយ។

បវារ ឬ. សំពត់ដណ្តប់ (ដូច **ឧត្តរាសង្ខ**) ។

បវាស ឬ. [ប+វ+ណ] ទីជាទីនៅប្រាស, ទីជាទីនៅព្រាត់ប្រាស; វ. **បវសនំ**> **បវាសោ**។

បវាសី ឬ. [ប+វ+ណី] អ្នកនៅប្រាស, អ្នកនៅព្រាត់ប្រាស; វ. **បវសតីតি**> **បវាសី**។

បវាហ ឬ. កម្លាំងនៃទឹក, ការហូរទៅនៃទឹក (**អម្ពុវេគ**), ការប្រព្រឹត្តទៅ (ដូច **បវត្តិ**)

បវាហេត្វា អ. [ប+ហ+ណ+ត្វា] បណ្តែតហើយ, បន្សាត់បង់ហើយ។

បវាឡ នឬ. [ប+ល+ណ, ល>ឡ] កែវប្រាឡ:ឬកែវប្រពាឡ។ -**ឆជ** ត. ទង់ជាវិការ:នៃកែវប្រពាឡ។ -**មយ** គុ. ជាវិការ:នៃកែវប្រពាឡ, សម្រេចហើយដោយកែវប្រពាឡ, គឺ...ធ្វើហើយដោយកែវប្រពាឡ (វិការតទ្ធិត និបន្ធតទ្ធិត, បកតតទ្ធិត)។ -**យដ្ឋិ** ត. ដងជាវិការ:នៃកែវប្រពាឡ។

បវិជ្ឈិត្វា អ. [ប+វិធ+យ+ត្វា, ចុះ-ត-អា.] ប្រមៀលហើយ។

បវិដ្ឋ គុ. [ប+វិ+ត] ចូលទៅហើយ, ចូលមកហើយ។ -**កាល** ឬ. កាលនៃ... ចូលទៅហើយ។ -**ក្ខណ** ឬ. ខណ:នៃ...ចូលទៅហើយ។ -**ឆិទ្ទ** នឬ. ប្រហោង...ចូលទៅហើយ។ -**បវិដ្ឋ** គុ. ចូលទៅហើយៗ។ -**ឫ** គុ. ធ្លាប់ចូលទៅហើយ។ -**ភាវ** ឬ. ភាវ:នៃ...ជាអ្នកចូលទៅហើយ។ **មត្ត** គុ. គ្រាន់តែចូលទៅហើយ; គ្រាន់តែគឺ...ចូលទៅហើយ។

បវិត្ត គុ. លាង, ស្អាត (ដូច **បយត**), ម៉ត់ចត់, មង្គល, ល្អ (ដូច **មេជ្ឈ**) ។

បវិទ្ធ គុ. [ប+វិធ+ត] គឺ...ប្រមៀលហើយ, ចោះទៅហើយ។ -**ត្ត** ត. ព្រោះភាវ:នៃ...ជារបស់គឺ...ប្រមៀលហើយ។

បវិវិត្ត គុ. [ប+វិ+វិច+ត] ស្ងាត់ទូទៅហើយ, ស្ងប់ស្ងាត់ហើយ។

បវិវេក គុ. [ប+វិ+វិច+ណ, ច>ក] ទីស្ងាត់, ទីជាទីស្ងាត់, ទីស្ងប់ស្ងាត់។ -**រស** ឬ. រសដែលកើតអំពីទីស្ងាត់, ទីស្ងប់ស្ងាត់; វ. **បវិវេកតោ ឧប្បន្នោ រសោ**> **បវិវេករសោ**។

បវិស កិ. [ប+វិ+អ+ហិ-ប., លុបហិ] ចូរចូលទៅ, ចូរចូលមក។

បវិសតិ កិ. [ប+វិ+អ+តិ-វ.] ចូលទៅ, ចូលមក។

បវិសថ កិ. [ប+វិ+អ+ថ-ប.] ចូរចូលទៅ, ចូរចូលមក។

បវិសន នបុ. [ប+វិសិ+យុ] កិ.ចូលទៅ; វិ. **បវិសិយតេតិ>បវិសនំ**។ (ទី) ជាទីចូលទៅ; វិ. **បវិសតិ ឯត្ថាតិ>បវិសនំ**។ -**អត្ថាយ** ដើម្បីប្រយោជន៍ដល់កិ.ចូលទៅ។ -**សមយ** បុ. សម័យនៃកិ.ចូលទៅ។ -**អាការ** បុ. អាការ:នៃកិ.ចូលទៅ, អាការ:ជាទីចូលទៅ។

បវិសន្តិ កិ. [ប+វិសិ+អ+អន្តិ-វ.] ចូលទៅ, ចូលមក។

បវិសិត្វា អ. [ប+វិសិ+ត្វា, ចុះ-ឥ-អា.] ចូលទៅហើយ, ចូលមកហើយ។

បវិស្ស អ. [ប+វិសិ+ត្វា] ចូលទៅហើយ។

បវិស្សសេ កិ. [ប+វិ+សសិ+អ+ឯយ្ស-ស.] គប្បីស្ងិទ្ធស្ងាល, រាប់អាន។

បវិស្សវិលេស ញែកចេញពីគ្នា, កន្ទែកគ្នា, ខុសគ្នា (ដូច **ឱ**ធ**ុ** រ) ។

បវីន អ្នកឆ្លាស, ជំនាញ, មានថ្វីដៃ (ដូច **កុ**ស**ល**) ។

បវុត្តិ ឥ. [ប+វត+តិ, អនៃវ>ឧ] ពាក្យប្រៃដូច **ប**ទ**ត្តិ**។

បវុទ្ធទ**ី** ជ្រោះធំ ។

បវេក្ខាមិ កិ. [ប+វិសិ+ខ+ស្សามិ-ភ., ស>ក, ស្ស>ខ, ិ>ាវ] នឹងចូលទៅ។

បវេច្ឆន្ត គុ. [ប+វិសិ+ឆ+អន្ត, ស>ច, ិ>ាវ] កាលញ៉ាំង...ឱ្យហូរទៅ, កាលបង្ហូរទៅ។

បវេណិ ឬ **បវេណ**ី ឥ. [ប+វ+ណឬណី] បវេណី, ប្រពៃណី, កម្រាលខ្នងដំរី (ដូច **ក**ុ**ថ**), ផ្ទ្ធងសក់ (នៃស្រី) (បែបផែន, សណ្ឋាប់ធ្នាប់) ។ -**ជ្ជ** នបុ. ភាវ:នៃ...ជាព្រះរាជាដោយប្រពៃណី។ -**ចាលក** គុ. អ្នករក្សានូវប្រពៃណី។ (**ចាលក**<ចាលិ+ណ្ឍ); វិ. **បវេណី ចាលេតីតិ>បវេណិចាលកោ**។

បវេទយន្តិ កិ. [ប+វិទ+ណយ+អន្តិ-វ.] ញ៉ាំង...ឱ្យដឹងទូទៅ, ប្រាប់, សម្តែង, ប្រកាស។

បវេទយមាន គុ. [ប+វិទ+ណយ+មាន] កាលញ៉ាំង...ឱ្យដឹងជាទូទៅ, កាលប្រាប់, កាលសម្តែង, កាលប្រកាស។

បវេទិត គុ. [ប+វិទ+ត, ចុះ-ឥ-អា.] គឺ...ឱ្យដឹងទូទៅហើយ, គឺ...ប្រាប់ហើយ, គឺ...សម្តែងហើយ។

បវេទេត្វា អ. [ប+វិទ+ណេ+ត្វា] ញ៉ាំង...ឱ្យដឹងទូទៅហើយ, សម្តែងហើយ, ប្រាប់ហើយ។

បវេទេសិ កិ. [ប+វិទ+ណេ+ណ្ស-អជ្ជ., ចុះ-ស-អា.] ញ៉ាំង...ឱ្យដឹងទូទៅហើយ, សម្តែងហើយ, ប្រាប់ហើយ។

បវេធន្ត គុ. [ប+វិធ+អន្ត] កាលញាប់ញ័រ, កាលញាក់ញ័រ, កាលទ្រាក់ទ្រើក។

បវេធិ កិ. [ប+វិធ+អ+ណ្ស-អជ្ជ.] ញាប់ញ័រហើយ,...។

បវេសន នបុ. [ប+វិសិ+យុ] កិ.ចូលទៅ, ការចូលទៅ; វិ. **បវិសិយតេតិ>បវេសនំ**។

(ទី) ជាទីចូលទៅ; វិ. **បវិសតិ ឯត្ថាតិ>បវេសនំ**។

បវេសយីសុ កិ. [ប+វិសិ+ណយ+ឧំ-អជ្ជ.] ញ្ចុំង...ឱ្យចូលទៅហើយ។

បវេសេតព្ព កិ. [ប+វិសិ+ណេ+តព្ព] គឺ...គប្បីញ្ចុំង...ឱ្យចូលទៅ, គឺ...គប្បីឱ្យចូលទៅ។

បវេសេតុកាម គុ. [បវេសេតុំ+កមិ+ណ] ចង់ដើម្បីចូលទៅ, ប្រាថ្នាដើម្បីចូលទៅ; វិ. **បវេសេតុំ កាមេតីតি>បវេសេតុកាមោ**។ មានសេចក្តីប្រាថ្នាដើម្បីចូលទៅ;វិ. **បវេសេតុំ កាមោ អស្សាតি>បវេសេតុកាមោ**។

បវេសេត្វា អ. [ប+វិសិ+ណេ+ត្វា] ញ្ចុំង...ឱ្យចូលទៅហើយ, បញ្ចូលទៅហើយ, ឱ្យចូលទៅហើយ។

បវេសេន្តិ កិ. [ប+វិសិ+ណេ+អន្តិ-វ.] ញ្ចុំង...ឱ្យចូលទៅ, ឱ្យចូលទៅ។

បវេសេសិ កិ. [ប+វិសិ+ណេ+ណ្ស-អជ្ជ., ចុះស-អា.] ញ្ចុំង...ឱ្យចូលទៅហើយ, ឱ្យចូលមកហើយ។

បវ បុំ. ការអុមឬរោយ (នូវអង្ការជាដើម) (ដូច **ឋាវន**) ។

បសត បុំ. ទ្ធកដៃ (ដូច **ករុឧ**) ។

បសត្ថ ឬ **បសដ្ឋ** គុ. [ប+សំសិ+ត] គឺ...សរសើរហើយ; វិ. **បសំសិយិត្ថាតি>បសត្ថោ, បសដ្ឋោ**។

បសទ បុំ. ម្រឹគមានរោមដ៏វិចិត្រ, ម្រឹគដ៏វិចិត្រ (ក្ដាន់) ។

បសន្ន គុ. [ប+សទ+ត, ត>អន្ន, លុបទ] ថ្លា, ជ្រះថ្លា, ជ្រះថ្លាហើយ; វិ. **បសីទ-តីតি>បសន្នំ, បសីទីតি ឥ>បសន្នំ**។ **-ឧទករហទសទិស** គុ. ប្រាកដស្មើដោយអន្លង់នៃទ្ធកដ៏ថ្លា។ **-ឧទករហទ** នបុំ. អន្លង់នៃទ្ធកដ៏ថ្លា។ **-ឧទក** នបុំ. ទ្ធកថ្លា, ទ្ធកដ៏ថ្លា។ **-កាល** បុំ. កាលនៃ...ជ្រះថ្លាហើយ។ **-ចិត្ត** គុ. មានចិត្តជ្រះថ្លាហើយ; វិ. **បសន្នំ ចិត្តំ យស្ស សោ>បសន្នចិត្តោ**។ **-មានស** គុ. មានចិត្តជ្រះថ្លាហើយ, មានឆន្ទ:មានក្នុងចិត្តជ្រះថ្លាហើយ។

បសន្នតា ឥ. សេចក្តីជ្រះថ្លា (ដូច **បសាទ**) ។

បសន្នោទក គុ. [បសន្ន+ឧទក] មានទ្ធកដ៏ថ្លា; វិ. **បសន្នំ ឧទកំ យស្ស តំ>បសន្នោទកំ**។

បសយ្ហ និ. ពលក្ការត្ថវាចក: និបាតប្រាប់អត្ថគឺការកំហែង។

បសយ្ហរូប នបុំ. [បសយ្ហ+រូប] (ក្នុងទីនេះប្រើជាបទគុណ) មានរូបគឺ...គប្បីកំហែងបាន, មានសភាពគឺ...គប្បីសង្កត់សង្កិនបាន, គប្បីញ្ចាំញ្ចីបាន, គ្របសង្កត់បាន (**បសយ្ហ**<ប+សហ+ណ្យ) ។

បសរ បុ. សេចក្តីរាយមាយទៅឬរង្គិលទៅ, លូនទៅក្នុងអារម្មណ៍ផ្សេងៗ (ដូច **វិបស្សន**) ។

បសវ បុ. ផ្តា (ដូច **បុប្ផ**), ផ្លែ (ដូច **ផល**), សេចក្តីកើត (ដូច **ឧប្បាទ**), ការសម្រាលកូន (ដូច **គព្ភហោចន**) ។

បសវតិ កិ. [ប+សុ+អ+តិ-រ.] សោយ, បាន, ប្រសព្ធ, ទទួល, ហូរទៅ។

បសវិស្សាមិ កិ. [ប+សុ+អ+ស្សាមិ-ភ., ចុះឥ-អា.] នឹងសោយ, នឹងបាន,...។

បសាទកាយ បុ. [បសាទ+កាយ] កាយដ៏ថ្លាស្អាត។ (**បសាទ**<ប+សទ+ណ)= សេចក្តីជ្រះថ្លា; វិ. **បសាទនំ>បសាទោ**។ អាការ:ដែលបុគ្គលជ្រះថ្លាដោយវិសេស; វិ. **វិសេសេន បសាទិយតីតি>បសាទោ**។

បសាទពហុល គុ. [បសាទ+ពហុល] ច្រើនដោយសេចក្តីជ្រះថ្លា, ក្រាស់ដោយសេចក្តីជ្រះថ្លា។

បសាទភញ្ញ នបុ. [បសាទ+ភញ្ញ] ពាក្យគឺបុគ្គលគប្បីពោលដោយសេចក្តីជ្រះថ្លា; គប្បីពោលដោយអំណាចនៃសេចក្តីជ្រះថ្លា។

បសាទានុរូប គុ. [បសាទ+អនុរូប] ដ៏សមគួរដល់សេចក្តីជ្រះថ្លា។

បសាទេតុកាម គុ. [បសាទេតុំ+កមិ+ណ] អ្នកប្រាថ្នាដើម្បីញ៉ាំង...ឱ្យជ្រះថ្លា; វិ. **បសាទេតុំ កាមេតីតি>បសាទេតុកាមោ**។

បសាទេតុំ អ. [ប+សទ+ណេ+តុំ] ដើម្បីញ៉ាំង...ឱ្យជ្រះថ្លា, កិ.ញ៉ាំង...ឱ្យជ្រះថ្លា។

បសាទេត្វា អ. [ប+សទ+ណេ+ត្វា] ញ៉ាំង...ឱ្យជ្រះថ្លាហើយ។

បសាទេន្ត គុ. [ប+សទ+ណេ+អន្ត] កាលញ៉ាំង...ឱ្យជ្រះថ្លា។

បសាទេសិ កិ. [ប+សទ+ណេ+ណ្ឌ-អជ្ជ., ចុះស-អា.] ញ៉ាំង...ឱ្យជ្រះថ្លាហើយ។

បសាទ បុ. សេចក្តីជ្រះថ្លា (ដូច **បសន្ទតា**) ។

បសាធន នបុ. [ប+សាធ+យុ] វត្ថុជាគ្រឿងញ៉ាំងកិច្ចឱ្យសម្រេចឬវត្ថុជាគ្រឿងប្រដាប់ (គ្រឿងប្រដាប់, គ្រឿងបសាធន:); វិ. **បសាធេតិ ឯតេនាតি> បសាធនំ**។ -**បេឡិកា** ឥ. ហិបសម្រាប់ដាក់នូវវត្ថុជាគ្រឿងប្រដាប់, ហិបសម្រាប់ដាក់នូវភណ្ឌ:ជាគ្រឿងប្រដាប់, ហិបសម្រាប់ដាក់នូវគ្រឿងប្រដាប់ (**បេឡិក**សព្ទនេះប្រែបានន័យផ្សេងទៀតថា ស្ទុគ្រ, កំប្រោង) ។ -**ភណ្ឌ** នបុ. ភណ្ឌ:គឺគ្រឿងប្រដាប់, ភណ្ឌ:គឺវត្ថុជាគ្រឿងប្រដាប់។ -**យោគ្គ** គុ. គួរដល់កិ.ប្រដាប់។

បសាធិតុំ អ. [ប+សាធ+តុំ, ចុះឥ-អា.] ដើម្បីប្រដាប់។

បសាធេត្វា អ. [ប+សាធ+ណេ+ត្វា] ប្រដាប់ហើយ, ស្ពិតស្អាងហើយ។

បសាធេស្សាមិ កិ. [ប+សាធ+ណេ+ស្សាមិ-ភ.] នឹងប្រដាប់, នឹងញ៉ាំង...ឱ្យប្រដាប់។

បសារេតិ កិ. [ប+សរ+ណេ+តិ-រ.] សណ្ដូក, លាត, លា, លាចេញ, សន្ធឹង។

បសារេត្វា អ. [ប+សរ+ណេ+ត្វា] សណ្ដូកហើយ, លាតហើយ, លាហើយ, លាចេញហើយ, សន្ធឹងហើយ។

បសារេន្ត គុ. [ប+សរ+ណេ+អន្ត] កាលសណ្ដូក,...។

បសារេសិ កិ. [ប+សរ+ណេ+ណ្ឌ-អជ្ជ., ចុះ-អា.] លាហើយ, លាចេញហើយ,...។

បសិតិ គ្រឿងចង (ដូច **ពន្ធន**) ។

បសិទ្ធ គុ. ប្រាកដ, ល្បីល្បាញ (ដូច **ឥសិសុត**) ។

បសីទន្តិ កិ. [ប+សទ+អ+អន្តិ-រ., សទ>សីទ] ថ្លា, ជ្រះថ្លា។

បសីទិត្វា អ. [ប+សទ+ត្វា, សទ>សីទ, ចុះ-អា.] ជ្រះថ្លាហើយ។

បសុ បុ. [បស+ឧ] សត្វគឺគេគប្បីចងទុក (សត្វចិញ្ចឹម); វិ. **បសវិតព្ពោ ពន្ធិតព្ពោតិ >បសុ**។ សត្វដែលគេគប្បីចិញ្ចឹម; វិ. **បសេតព្ពោ ចោសេតព្ពោតិ>បសុ**។ បើជាពហុវចនៈតាំងជាបសុ+យោ-វិ., ផ្លាស់ឧ>អ, យោ>ឱ =**បសវោ**។

បសុត គុ. [ប+សុ+ត] ខ្ទល់ខ្ចាយ, អ្នកខ្ទល់ខ្ចាយ; វិ. **បសវតីតិ>បសុតោ**។

បសុបតិ បុ. ព្រះឥសូរ (ដូច **សិវ**) ។

បសុបាលន នបុ. ការចិញ្ចឹមសត្ត (ដូច **គោរក្ខ**) ។

បសូ ធា. **និប្ផសវេ បសូយតិ** "សម្រាប់កូន" ហូរចេញ ទិ. ។ **បសូតា** ឥ. "ស្រីសម្រាលបុត្រ" ។ (ប+សូ) ? ។

បសូតិ ឥ. [ប+សូ+តិ] (ផ្ទះ) ជាទីប្រសូតិ; វិ. **បសវតិ ឯត្ថាតិ>បសូតិ**។ កិ. ប្រសូតិ; វិ. **បសវនំ>បសូតិ**។ **-ឃរ** នបុ. ផ្ទះជាទីប្រសូតិ។

បសូតិកា ឥ. ស្រីដែលសម្រាលកូនហើយ (ដូច **ជាតាបច្ចា**) ។

បសេនទិ ន. ព្រះនាមនៃព្រះរាជាជាធំក្នុងដែនកោសល។

បស្ស កិ. [ទិសិ+អ+ហិ-ប., ទិសិ>បស្ស, លុបហិ-ប.] ចូរឃើញ, ចូរមើល។

បស្ស ន. ខាង, ម្ខាង (**ទក្ខិណបស្ស** ខាងស្ដាំ, **វាមបស្ស**ខាងឆ្វេង) ។

បស្សតា គុ. [បស្សន្ត+នា-វិ, ន្ត+នា>តា] កាលឃើញ, កាលមើល។

បស្សតិ កិ. [ទិសិ+អ+តិ-រ.] ឃើញ, មើល។

បស្សតុ កិ. [ទិសិ+អ+តុ-ប.] ចូរឃើញ, ចូរមើល។

បស្សតោ គុ. [បស្សន្ត+ស-វិ, ន្ត+ស>តោ] កាលឃើញ, កាលមើល។

បស្សថ កិ. [ទិសិ+អ+ថ-ប.] ចូរមើល, ចូរឃើញ។

បស្សទ្ធ គុ. [ប+សំភ+ត, ត>ទ្ធ, ស>ស្ស, លុបនិគ្គហិត] ស្ងប់ហើយ, រម្ងាប់ហើយ, ស្ងប់រម្ងាប់, សះស្បើយ; វិ. **បស្សម្ភីតិ>បស្សទ្ធោ**។ **-ទរថ**

គុ. អ្នកមានសេចក្តីក្រវល់ក្រវាយរម្ងាប់ហើយ។

បស្សនសីល គុ. [បស្សន+សីល] អ្នកមានកិ.ឃើញជាប្រក្រតី; វិ. **បស្សនំ សីលម-ស្សាតិ** >**បស្សនសីលោ**។ **បស្សន**<ទិស+យុ=វិ. **បស្សិយតេតិ**> **បស្សនំ**។

បស្សន្ត គុ. [ទិសិ+អន្ត, ទិសិ>បស្សិ] កាលឃើញ, កាលមើល។

បស្សសិ កិ. [ទិសិ+អ+សិ-រ.] ឃើញ, មើល។

បស្សាវ បុ. ទឹកនោម (ដូច **មុត្ត**) ។

បស្សាស បុ. ខ្យល់ដកដង្ហើមចូល (ដូច **អបាន**) ។

បស្សិ កិ. [ទិសិ+អ+ណ្យ-អជ្ជ.,] ឃើញហើយ, មើលហើយ។

បស្សិតុកាម គុ. [បស្សិតុំ+កមិ+ណ] អ្នកចង់ដើម្បីឃើញ។

បស្សិតុំ អ. [ទិសិ+តុំ, ចុះឥ-អា.] ដើម្បីឃើញ, កិ.ឃើញ។

បស្សិត្វា អ. [ទិសិ+ត្វា, ចុះឥ-អា.] ឃើញហើយ។

បស្សិស្សតិ កិ. [ទិសិ+អ+ស្សតិ-ភ. ចុះឥ-អា.] នឹងឃើញ។

បស្សេ កិ. [ទិសិ+អ+ឯយ្យ-ស.] គប្បីឃើញ។ ន. ទីខាង, ក្បែរខាង។

បស្សេសុ ន. [បស្ស+សុ, ផ្លាស់អនៃស្ស>ឯ] ក្នុងខាងទាំងឡាយ, ទៀបខាងទាំងឡាយ។

បសំសការណា នបុ. [បសំស+ការណ] ហេតុនៃសេចក្តីសរសើរ។

បសំសន នបុ. [ប+សំសិ+យុ] សេចក្តីសរសើរ, កិ.សរសើរ; វិ. **បសំសិយតេតិ**> **បសំសនំ**។ -**មត្ត** គុ. ពាក្យគ្រាន់តែសេចក្តីសរសើរ, សព្វបើសេចក្តីសរសើរ។

បសំសន្តិ កិ. [ប+សំសិ+អ+អន្តិ-រ.] រមែងសរសើរ។

បសំសសិ កិ. [ប+សំសិ+អ+សិ-រ.] សរសើរ, រមែងសរសើរ។

បសំសា ឥ. [ប+សំសិ+អ+អា-ឥ.] ការសរសើរ, សេចក្តីសរសើរ; វិ. **បសំសនំ**> **បសំសា** ។ -**មត្ត** គ្រាន់តែសេចក្តីសរសើរ។

បសំសិត គុ. [ប+សំសិ+ត, ចុះឥ-អា.] គឺ...សរសើរហើយ។

បសំសិតព្ព កិ. [ប+សំសិ+តព្ព, ចុះឥ-អា.] គឺ...គប្បីសរសើរ។

បសំសិត្វា អ. [ប+សំសិ+ត្វា, ចុះឥ-អា.] សរសើរហើយ។

បសំសិយភាវ បុ. [បសំសិយ+ភាវ] ភាវៈនៃ...ជាអ្នកគឺ...គប្បីសរសើរ។ **បសំសិយ** <ប+សំសិ+ណ្យ, ចុះឥ-អា.=វិ. **បសំសិតព្វោតិ**>**បសំសិយោ**។

បសំសុឃ្ជាទន នបុ. [បសំស+ឧឃ្ជាទន] កិ.ញ៉ាំង...សេចក្តីសរសើរឱ្យកើតឡើង។

បសិ ធា. **ឥត្ថារពន្ធនបស្សនេសុ បសតិ, បសេតិ បសយតិ** "ពង្រីក, ពិស្តារ, ចង, ទាក់, យើញ" ភ្ជ. ចុ. ។ **បាសោ** បុ. "អន្ទាក់, គ្រឿងចង" **ហត្ថបាសោ** "ហត្ថបាសគឺមួយអន្ទាក់ដៃប្រមាណពីរហត្ថ" ។ **បសុ** បុ. "សត្វដែលគេចិញ្ចឹម" ដែលគេទាក់ឬចង -ស. ។

បហដ្ឋ គុ. [ប+ហស+ត] រីករាយទូទៅហើយ, រីករាយហើយ។ -**មានស** គុ. អ្នកមានចិត្តរីករាយទូទៅហើយ, អ្នកមានឆន្ទៈមានក្នុងចិត្តរីករាយហើយ។

បហត គុ. [ប+ហរ+តឬហន+ត] គឺ...ប្រហារហើយ, គោះហើយ, វាយហើយ, ខ្ជប់ហើយ។ -**ភាវ** នបុ. ភាវៈនៃ...ជា...គឺ...ប្រហារហើយ។ -**បហត-ដ្ឋាន** នបុ. ទីនៃ...គឺ...ប្រហារហើយ។ ។

បហន្ត្វា អ. [ប+ហនិ+ត្វា] កម្ចាត់បង់ហើយ,សម្លាប់ហើយ។

បហរ កិ. [ប+ហរ+អ+ហិ-ប.] ចូរប្រហារ, ចូរវាយ,...។

បហរណាទិ គុ. [បហរណ+អាទិ] (កម្ម) មានកិ.ប្រហារជាដើម; វិ. **បហរណំ អាទិ យេសំ តានិ >បហរណាទីនិ** (**ភណ្ឌានិ**) ។ **បហរណ**<ប+ហរ+យុ=វិ. **បហរិយតេតិ> បហរណំ**។

បហរណ នបុ. សស្ត្រាវុធ (ដូច **សត្ថ**) ។

បហរន្តុ កិ. [ប+ហរ+អ+អន្តុ-ប.] ចូរប្រហារ, ចូរវាយ,...។

បហរិតព្ព កិ. [ប+ហរ+តព្ព, ចុះឥ-អា.] គឺ...គប្បីប្រហារ។

បហរិតុកាមតា នបុ. [បហរិតុកាម+តា] ភាវៈនៃ...ជាអ្នកចង់ដើម្បីប្រហារ; វិ. **បហរិតុំ កាមេតីតি> បហរិតុកាមោ, តស្ស ភាវោ>បហរិតុកាមតា**។

បហរិត្វា អ. [ប+ហរ+ត្វា, ចុះឥ-អា.] ប្រហារហើយ។

បហរិស្សតិ កិ. [ប+ហរ+អ+ស្សតិ-ភ., ចុះឥ-អា.] នឹងប្រហារ។

បហរីសុ កិ. [ប+ហរ+អ+ឧំ-អជ្ជ.] ប្រហារហើយ។

បហរេយ្យ កិ. [ប+ហរ+អ+ឯយ្យ-ស.] គប្បីប្រហារ។

បហស្សថ កិ. [ប+ហា+អ+ស្សថ-ភ.] នឹងលះ, នឹងលះបង់។

បហាតព្ព កិ. [ប+ហា+តព្ព] គឺ...គប្បីលះ, គប្បីលះបង់។ -**អត្ថ** បុ. សេចក្ដីថាគឺ...គប្បីលះបង់។

បហាតវេ អ. [ប+ហា+តវេ] ដើម្បីលះបង់។

បហាតុំ អ. [ប+ហា+តុំ] ដើម្បីលះបង់។

បហាន នបុ. [ប+ហា+យុ] កិ.លះ, កិ.លះបង់ (ជាទីលះបង់); វិ. **បហីយតេ> បហានំ**។ -**ករ** បុ. អ្នកធ្វើនូវកិ.លះបង់។ -**អត្ថាយ** ដើម្បីប្រយោជន៍

ដល់កិ.លះបង់។ -**បរិញ្ញា** ឥ. ធម្មជាតិគឺបុគ្គលគប្បីកំណត់ដឹងដោយអំណាចនៃកិ.លះបង់, ឈ្មោះ បហានបរិញ្ញា។

បហាយ អ. [ប+ហា+ត្វា] លះហើយ, លះបង់ហើយ, លះចោលហើយ, ទុកហើយ។

បហារ បុં. [ប+ហរ+ណ] កិ.ប្រហារ, យាម (នាឡិកា); វិ. **បហារណំ>បហារោ**។ -**ទាន** នបុં. កិ.ឱ្យនូវកិ.ប្រហារ។

បហារាទ បុં. ព្រះនាមស្តេចអសុរ១ព្រះអង្គ (បហារាទអសុរិន្ទ) ។

បហារាបេសិ កិ. [ប+ហរ+ណាបេ+ណ្យ-អជ្ជ., ចុះស-អា.] ញ៉ាំង...ឱ្យប្រហារហើយ,...។

បហិណាតុ កិ. [ប+ហិ+ណា+តុ-ប.] ចូរបញ្ជូនទៅ, ចូរបញ្ជូនមក, ចូរផ្ញើទៅ។

បហិណាមិ កិ. [ប+ហិ+ណា+មិ-វ.] បញ្ជូនទៅ, បញ្ជូនមក, ផ្ញើទៅ។

បហិណិ កិ. [ប+ហិ+ណា+ណ្យ-អជ្ជ.] បញ្ជូនទៅហើយ, បញ្ជូនមកហើយ, ផ្ញើទៅហើយ។

បហិណិត្ថ កិ. [ប+ហិ+ណា+ត្ថ-អជ្ជ.] បញ្ជូនទៅហើយ,...។

បហិណិត្វា អ. [ប+ហិ+ណា+ត្វា, អានៃណា>ឥ] បញ្ជូនទៅហើយ, បញ្ជូនមកហើយ, ផ្ញើទៅហើយ។

បហិណិស្សតិ កិ. [ប+ហិ+ណា+ស្សតិ-ភ.] នឹងបញ្ជូនទៅ,...។

បហិណឹសុ កិ. [ប+ហិ+ណា+ឧំ-អជ្ជ.] បញ្ជូនទៅហើយ,...។

បហិត គុ. [ប+ហិ+ត] គឺ...បញ្ជូនទៅហើយ។ -**ត្ត** គុ. មានខ្លួនបញ្ជូនទៅហើយ។ -**បហិត** គុ. គឺ ...បញ្ជូនទៅហើយៗ។ -**ភាព**បុં. ភាវៈនៃ...ជា...គឺ...បញ្ជូនទៅហើយ។ -**សញ្ញាណ** នបុં. សញ្ញាឬសញ្ញាណនៃ...គឺ...បញ្ជូនទៅហើយ, សេចក្តីសម្គាល់នៃ...គឺ...បញ្ជូនទៅហើយ។ -**សាសន** នបុં. ដំណឹង, សំបុត្រ, ពាក្យបណ្តាំគឺ...បញ្ជូនទៅហើយ, ផ្ញើទៅហើយ។

បហិយ កិ. [ប+ហា+យ+ណ្យ-អជ្ជ., អានៃហា>ឥ] សាបសូន្យហើយ, លះបង់ហើយ។ ប្រើជា **បហីយ** ក៏បាន។

បហីន គុ. [ប+ហា+ត, ត>ណ្ឌ] គឺ...លះបង់ហើយ, បន្សាត់បង់ហើយ។ -**កសាព** គុ. អ្នកមានទឹកចត់គឺរាគាទិក្តិលេសបន្សាត់បង់ហើយ, លះបង់ហើយ, អ្នកមានកិលេសដូចជាទឹកចត់លះបង់ហើយ, អ្នកមានទឹកចត់លះបង់ហើយ។ -**ត្តា** ព្រោះភាវៈនៃ...ជា...គឺ...លះបង់ចោលហើយ។ -**ចាប** គុ. អ្នកមានបាបលះបង់ចោលហើយ, បន្សាត់បង់ហើយ។ -**បុញ្ញ** គុ. អ្នកមានបុណ្យលះបង់ហើយ។ -**មាន** គុ. អ្នកមានមានៈលះបង់ហើយ។

បហីនសោកសល្លតា ឥ. [បហីនសោកសល្ល+តា] ភាវៈនៃ...ជាអ្នកមានសរគឺសេចក្តីសោកលះបង់ហើយ; វិ. **សោកោ ៦ឥ សល្លំ>សោកសល្លំ, បហីនំ សោកសល្លំ យេន សោ> បហីន សោកសល្លោ, បហីនសោក-សល្លស្ស ភាវោ>បហីនសោកសល្លតា**។

បហីយតិ កិ. [ប+ហា+យ+តិ-វ., អានៃហា>ល្ម] គឺ...លះ, លះបង់, បន្សាត់បង់។

បហុត គុ. [ប+ហ+ត] ច្រើន, ល្ម, ល្មមគ្រាន់, គ្រប់គ្រាន់។ **-អន្ធបាន** គុ. មានបាយគឺបុគ្គលគប្បីស៊ីនិងទឹកគឺបុគ្គលគប្បីផឹកដ៏ច្រើន, មានបាយនិងទឹកច្រើន។

បហុន ប៉ុ. ភ្ញៀវ (ដូច **អតិថិ**) ។

បហេណក នប៉ុ. បញ្ញើដែលបញ្ជូនទៅឲ្យ (ដូច **បណ្ណាការ**) ។

បហោតិ កិ. [ប+ហ+អ+តិ-វ.] ល្ម, ល្មមគ្រាន់, ត្រឹមល្ម, គ្រប់គ្រាន់។

បហោនក គុ. [ប+ហ+យុ+ក-ស.] ល្ម, ល្មមគ្រាន់, ត្រឹមល្ម, គ្រប់គ្រាន់។ **-និយាម** ប៉ុ. ទំនងនៃ...ល្មមគ្រាន់, លំអាននៃ...។

បហោសិ កិ. [ប+ហ+អ+ល្ម-អជ្ជ., ចុះស-អា.] ល្មមហើយ, គ្រប់គ្រាន់ហើយ។

បហោស្សតិ កិ. [ប+ហ+អ+ស្សតិ-ភ.] នឹងល្ម, នឹងល្មមគ្រាន់, នឹងគ្រប់គ្រាន់។

បហំសិ កិ. [ប+ហំស+អ+ល្ម-អជ្ជ.,] រីករាយហើយ, ស្រស់ស្រាយហើយ, ស្រស់បោះហើយ, ញញឹមញញែមហើយ។

បហំសិតមុខ គុ. [បហំសិត+មុខ] មានមុខស្រស់បំព្រង, មានមុខរីករាយហើយ។

បហំសិត្វា អ. [ប+ហំស+ត្វា, ចុះឥ-អា.] រីករាយហើយ, ញញឹមញញែមហើយ។

បា ធា. ១.**បានេ បាតិ បានីយំ បាតព្ពំ បាតុំ** "ផឹក, ហៅ, ហុត, បឹត" ភ្ល. ។ **បានំ** នប៉ុ. "ទឹក, គ្រឿងផឹក" ។ **បាសតិ** "នឹងផឹក" ភវិ. ។ **អបស្សា** "នឹងផឹកហើយ, នឹងបានផឹកហើយ" កាលា.។ **បចា** ឥ. "រោងទឹក, រោងទុកទឹកផឹក" -ស. ។

២-**បានេ បិវតិ បិវន្តោ បិវិត្វា** "ផឹក, ហុត, ហៅ, ឬ ភ្ល. **បិវាសតិ** "ចង់ផឹក, ស្រេក" **បិបាសតិ** "ចង់ផឹក, ស្រេក" ។ ន. **បិបាសា** "ការស្រេក, សម្រេក" ។ កម្ម. **ពីយតិ**ពីតោ។ ការិត. **បាយេតិ** អា. **កុមារំ ខីរំ បាយេតិ** "ញ៉ាំងកុមារឲ្យហៅដោះ" -ស. ។ ចំពោះ **បិវាសតិ បិបាសតិ** (ហ-ហ+ស+តិផ្លាស់ ហអ្ហ:ជា ប ផ្លាស់ហ ធាតុ ជា ហ) ។

៣-**ឆ្ងេ បាតិ និបាតិ** "រក្សា, ចិញ្ចឹម, ឃុំគ្រង" ភ្ល. ។ **ពិតា** ប៉ុ. "ឪពុក" (ហ+ឥតុ) ។ **គោបោ** "គង្វាលគោ" (គោ+ហ+ក្ត) ។ **និបកោ** ប៉ុ. "អ្នក

ឈ្លាស, អ្នកមានប្រាជ្ញា" (និ+បា+ណ្យ ឬនិ+បចិ+ណ) ។ **អធិបតិ** បុ. ឬគុ. "អ្នកជាធំ, ជានាយ, ជាចៅហ្វាយ" (អធិ+បា+តិ ឬ អធិ+បតិ+ឥ) ។ **បតិ** បុ. "អ្នកធំ, ចៅហ្វាយ, ប្តី (បា+តិឬបតិ+ឥ) ។ **ជនា-ធិបោ** បុ. "ព្រះរាជា" (ជន+អធិ+បា+ក្ងិ) ។ **បាបំ** នបុ "បាប, សេ. អាក្រក់, ថោកទាប, លាមក, អន់" (បា+ប-បច្ច័យឬប+អបិ+អឬប+ឧ+ណ) (ស្ងួចិ) ។

៤-ម្ហរណោ បាតិ ទ្វិប្ជាតិ "បំពេញ" ភ. ។ **ទ្វិជ្ជោ** បុ. "ព្រាហ្មណ៍" អ្នកញ៉ាំងវេទមន្តឲ្យពេញអា. **ជាតោ ទ្វិជ្ជកុលេ អហំ** "ខ្ញុំកើតក្នុងត្រកូលព្រាហ្មណ៍" -ស. ។

បាក បុ. ញើស (ដូច **សេទ**), វិបាក (ផល) ។

បាកដ គុ. [ប+កដ+អ, ប>បា] (សភាវ:)ដល់នូវកិ.ឃើញ (ប្រាកដ, ជាក់ស្តែង, ល្បីល្បាញ); វិ. **ទស្សនំ កដតិ គច្ឆតីតិ>បាកដោ**។ -**ទ្ធ** បុ. អន្តរាយប្រាកដ, អន្តរាយជាក់ស្តែង។

បាកដីភូត គុ. [បាកដ+ភូត, ចុ:ណ្ឌ] ជាធម្មជាតមានសេចក្តីប្រាកដកើតហើយ។

បាកដ្ឋាន នបុ. រោងគ្រូ, រោងបាយ (ដូច **មហានស**) ។

បាកតិក គុ. [បកតិ+ណិក] (សភាវ:) តាំងនៅដោយប្រក្រតីឬតាំងនៅដោយសភាវ:ជាប្រក្រតី; វិ. **បកតិយា តិដ្ឋតីតិ>បាកតិកោ**។ **អគ្គិ-ន្ធាម** បុ. កម្តៅនៃភ្លើងដែលតាំងនៅដោយភាវ:ជាប្រក្រតី។ -**សរីរ** គុ. មានសរីរ:តាំងនៅដោយប្រក្រតី។

បាកវត្ត នបុ. [បាក+វត្ត] វត្ថុគឺបុគ្គលគប្បីឱ្យឆ្អិនប្រព្រឹត្តទៅ (ស្បៀង, គ្រឿងសម្ល, ម្ហូប) ។ -**មូល** នបុ. ទ្រព្យជាមូល (តម្លៃ) នៃវត្ថុគឺបុគ្គលគប្បីឱ្យឆ្អិនប្រព្រឹត្តទៅ។

បាកសាសន បុ. ព្រះឥន្ទ (ដូច **កោសិយ**) ។

បាការ បុ. [ប+ការ+ណ] (ប្រទេស) ដែលគេធ្វើដោយជុំវិញ (កំពែង); វិ. **បរិស-មន្តតោ ករិយតីតិ>បាការោ**។ -**អន្តរ** នបុ. ចន្លោះឬរវាងនៃកំពែង, ខាងក្នុងនៃកំពែង។ -**បរិក្ខិត្ត** គុ. ដែលបុគ្គលបិទបាំងហើយដោយកំពែង, ដែល... ព័ន្ធព័ទ្ធហើយដោយកំពែង, ដែល... ហ៊ុមព័ទ្ធហើយដោយកំពែង។ -**បរិក្ខេប** បុ. កិ.បិទបាំងដោយកំពែង, វត្ថុជាគ្រឿងបិទបាំងដោយកំពែង។

បាយណ បុ. ផ្ទៀង, រមៀង (ដូច **ឧមុ១**) ។

បាចន នបុ. ចន្លូញ, រំពាត់ (ដូច **ឧតោ១**) ។

បាចានល បុ. ភ្លើងធាតុកើតអំពីកម្មតាំងនៅក្នុងផ្ទៃដុតកម្តៅអាហារឲ្យរលួយ

រលាយ, សព្វនេះជាអត្ថនៃ **គហណីសញ្ញ**។

បាចី ឥ. ទិសខាងកើត។

បាចីន គុ. [ប+អចិ+ណ្យ, ចុះន-ស.] ទិសដែលព្រះអាទិត្យលេចចេញជាដំបូង (ទិសខាងកើត); វិ. **បឋមំ ជាតោ អញ្ញតិ រវិ យស្សំ សា>បាចី, បាចី ឯវ>បាចីនំ**។ -**ចក្ខវាឡមុខវដ្ដិ** ឥ. កណ្តាប់នៃមាត់នៃចក្កវាឡក្នុងទិសខាងកើត។ -**ទិសា** ឥ. ទិសខាងកើត។ -**ទ្វារ** នបុં. ទ្វារមានក្នុងទិសខាងកើត។ -**ឆិន្ន** គុ. ដែលឱនទៅហើយក្នុងទិសខាងកើត, ទេរទៅហើយកាន់ទិសខាងកើត។ -**បច្ឆិមទ្វារ** នបុં. ទ្វារមានក្នុងទិសខាងកើតនិងទ្វារមានក្នុងទិសខាងលិច។ -**ឋំសមិគទាយ** នបុំ. ព្រៃជាទីឱ្យនូវអភ័យដល់ម្រឹគជិតស្រុកឈ្មោះបាចីនវំសៈ, ព្រៃឈ្មោះ បាចីនវំសមិគទាយៈ។

បាជិតា នាយសារថី, អ្នកបររថ (ដូច **រថាចារី**) ។

បាជិយមាន គុ. [បជ+យ+មាន, ចុះឥ-អា.] គឺ...កាលបរទៅ, កាលកៀងទៅ។

បាជេហិ កិ. [បជ+ណេ+ហិ-ប.] ចូរបរទៅ, ចូរកៀងទៅ។

បាជេតិ កិ. [បជ+ណេ+តិ-វ.] រមែងបរទៅ, កៀងទៅ, ដើរទៅ។

បាជេត្វា អ. [បជ+ណេ+ត្វា] បរទៅហើយ, កៀងទៅហើយ។

បាជេថ កិ. [បជ+ណេ+ថ-ប.] ចូរបរទៅ, ចូរដើរទៅ។

បាជេន្ត គុ. [បជ+ណេ+អន្ត] កាលបរទៅ, កាលកៀងទៅ។

បាជេសិ កិ. [បជ+ណេ+ណ្យ-អជ្ជ., ចុះស-អា.] បរទៅហើយ។

បាដលិបុត្តក នបុំ. ឈ្មោះទីក្រុងមួយក្នុងប្រទេសឥណ្ឌា។

បាដលី ដើមច្រនៀង (ដូច **កណ្ណិកណ្ណ**) ។

បាដល ពណ៌ក្រហមលាយស, ក្រហមភ្លាវ (**សេតណោហិត**) ។

បាដិកង្ខ គុ. [បដិ+កង្ខ+អ] គឺ...គប្បីប្រាថ្នាចំពោះ, ប្រាកដ។

បាដិកា ឥ. ថ្មមានសណ្ឋានដូចអឌ្ឍចន្ទ, អឌ្ឍសិលា

បាដិគ្គ គុ. [បាដិ+អគ្ត] ទានដ៏លើសដែលបុគ្គលគប្បីឱ្យក្នុងកាលជាទីដួសដាក់ក្នុងភាជន៍, ទានដ៏ប្រសើរ...។ ប្រើជា **ឋានិ**ក៏មាន។

បាដិភោគ គុ. [បតិ+ភុជ+ណ, ត>ដ] អ្នករក្សា (អ្នកធានា, អ្នកវ៉ាប់រង) វិ. **បតិភុញ្ជតិ ចាលយតីតិ>បាដិភោគោ**។

បាដិមោក្ខ នបុំ. [បដិ+មោក្ខ+អ ឬ មុចិ+អ] (ធម្មជាតឬសីល) ញ្ជាំងបព្វជិតឱ្យផុតចាកទុក្ខមានអបាយិកទុក្ខជាដើមឬចាកភ័យមានអត្តានុវាទភ័យជាដើម; វិ. **សីលំ យោ នំ ចាតិ រក្ខតិ តំ មោក្ខេតិ មោចយតិ អបាយិ-**

ភាវីហិ ទុក្ខេហិ អត្តានុវាទាទីហិ វា ភយេហីតិ>បាដិ-មោក្ខំ។ **សីល** នបុ. សីលគឺបាដិមោក្ខ។ ឥឡូវប្រើ **បាតិមោក្ខ** វិញ។

បាដិយេក្ក កិ.វិ. ឬនិ ផ្សេងគ្នា, ផ្ទៃកផ្សេងៗ, ដោយឡែកពីគ្នា។

បាដិហារិយ នបុ. [បដិ+ហរ+ណ្យ, អនៃរ>ឥ.] (ធម្មជាត) នាំទៅនូវធម៌ជាប្រតិបក្ស ឬនាំបង់នូវធម៌ជាសត្រូវ (**បាដិហារ្យ**); វិ. **បដិបក្ខេ ហរតីតិ>បាដិ-ហារិយំ**។ **-ករណវេលា** ឥ. វេលាជាទីធ្វើនូវបាដិហារ្យ។

បាដិហីរ នបុ. បាដិហារិយ៍ (ដូច **បាដិហារិយ**) ។

បាដិហេរ នបុ. [បដិ+ហិ+ណ, ហិ>ហេរ ឬ ហរ, អនៃហ>ឥ>ឯ] (ពាក្យប្រែនិងវិគ្គហៈ ដូច **បាដិហារិយ**) ។

បាឋ បុ. [បឋ+ណ] អត្ថគឺបណ្ឌិតពោល (បាឋៈ, បាលី); វិ. **បឋិយតេតិ>បាឋោ**។

បាឋសេស បុ. [បាឋ+សេស] សេសនៃបាលី, បាឋៈដ៏សេស, បាលីដ៏សេស។

បាឋា ឥ. ឈ្មោះដើមឈើម្យ៉ាង (ដូច **អម្ពដ្ឋា**) ។

បាឍីន បុ. ត្រីស្លាត, ត្រីក្អែក (ដូច **បាសាណមច្ឆ**) ។

បាដេយ្យកភិក្ខុ បុ. [បាដេយ្យក+ភិក្ខុ] ភិក្ខុអ្នកនៅក្នុងដែនបាឋា; ភិក្ខុអ្នកនៅក្នុងក្រុងបាឋា; វិ. (**បាដេយ្យក**<បាឋា+ឯយ្យក= វិ. **បាឋាយំ ភវន្តីតិ> បាដេយ្យកា**) ។

បាណ បុ. [ប+អនិ+ណ] (សភាវៈ) ជាហេតុរស់នៅនៃសត្ត (សត្ត, ជីវិត), ពល, ខ្យល់ដកដង្ហើម (ដូច **ហទយគានិល**); វិ. **បានន្តិ ជីវន្តិ សត្តា ឯតេនាតិ> បាណោ**។ **-ភោជិ** ឥ. ភោជិនៃសត្ត។ **-ឃាតី** គុ. បុគ្គលអ្នកសម្លាប់នូវសត្ត; វិ. **បាណំ ហនតីតិ>បាណឃាតី**។ **-សម** គុ. ស្មើដោយជីវិត។ **សហស្ស** ប.សំ. ពាន់នៃសត្តឬពាន់នៃសត្តមានជីវិត។

បាណក បុ. [បាណ+ក] សត្តតូច, សត្តល្អិត, ដង្កូវ។ **-ទ្ធ** គុ. គឺសត្តល្អិតចោះហើយ, គឺដង្កូវចោះហើយ។

បាណាតិបាត បុ. [បាណ+អតិ+បត+ណ] (ចេតនាធម៌) ជាហេតុញ្ចាំងសត្តមានជីវិតឱ្យធ្លាក់ចុះកន្លងឬចេតនាធម៌ជាហេតុសម្លាប់នូវសត្តមានជីវិត; វិ. **បាណំ អតិបាតេតិ ឯតេនាតិ>បាណាតិបាតោ**។

បាណាតិបាតី គុ. [បាណ+អតិ+បត+ណី] អ្នកញ្ចាំងសត្តមានជីវិតឱ្យធ្លាក់ចុះកន្លងឬអ្នកសម្លាប់នូវសត្តមានជីវិត; វិ. **បាណំ អតិបាតេតីតិ>បាណាតិបាតី**។

បាណិ បុ. [បណ+ឥ ឬ ណ+ណិ] ដៃ, បាតដៃ, ឈើខ្ទៀសគឺឈើសម្រាប់ចូកបាយអនៃជាងចូកបាយអ (ដូច **ភូសណ្ហករណិយ**) ។ **-អាទិ** គុ.

(**ឧហារណាវត្ថុ**) មានបាតដៃជាដើម។ -**ឆល** នបុં. ផ្ទៃនៃដៃ, ផ្ទៃនៃបាតដៃ។ -**ឃ្ឃាតាទិ** គុ. (គ្រឿងប្រហារ) មានកិ.ប្រហារដោយបាតដៃជាដើម។ -**សន្ធ** បុં. សូរនៃបាតដៃ។

បាណិគ្គហ បុં. ពិធីរៀបការ (ដូច **ឱវាហ**) ។

បាណិយ បុં. អ្នកទះដៃ (ដូច **បាណិទាន**) ។

បាណិមុត្ត នបុં. គ្រឿងសស្ត្រាដែលផុតអំពីដៃមានលំពែងជាដើម។

បាណិទាន បុំ. អ្នកទះដៃ (ដូច **បាណិយ**) ។

បាណី បុំ. សត្ត (ដូច **ទេហី**) ។

បាណ្យង្ក នបុំ. អវយវ:នៃសត្ត។

បាតន នបុំ. [បត+យុ] កិ.ធ្លាក់ទៅ, កិ.ធ្លាក់ចុះ, កិ.ញ៉ាំង...ឱ្យធ្លាក់ចុះ, កិ.ទម្លាក់ចុះ; វិ. **បាតិយតេតិ>បាតនំ**។

បាតព្ព កិ. [បា+តព្ព] គឺ...គប្បីផឹក; វិ. **ឬ ឬ ឬ>**។ **យុត្តក** គុ. គួរគឺ...គប្បីផឹក, ជារបស់គួរគឺ...។

បាតយិស្សាមិ កិ. [បត+ណយ+ស្សាមិ-ភ., ចុះ-ឥ-អា.] នឹងញ៉ាំង...ឱ្យធ្លាក់ចុះ, នឹងទម្លាក់ចុះ។

បាតរាស នបុំ. [បាតោ+អសិ+ណ, ចុះ-អ-អា.] (ភោជន) គឺបុគ្គលគប្បីស៊ីក្នុងវេលាព្រឹក; វិ. **ឬ ឬ ឬ>**។ -**អត្ថាយ** ដើម្បីប្រយោជន៍ដល់ភោជនគឺបុគ្គលគប្បីស៊ីក្នុងវេលាព្រឹក។ -**វេលា** ឥ. វេលានៃភោជនគឺបុគ្គលគប្បីស៊ីក្នុងវេលាព្រឹក។

បាតាល នបុំ. ពិភពនាគ (ដូច **នាគលោក**), អន្លង់ជ្រៅ, បាតទន្លេដែលជ្រៅជាងគេ (ដូច **ឥឡ្យាមុខ**) ។

បាតិត គុ. [បត+ណេ+ឥ+ត] គឺ...ឱ្យធ្លាក់ចុះហើយ, គឺ...ទម្លាក់ចុះហើយ (ជុះដាក់, ស្ពោះដាក់) ។

បាតី បាត្រ, ភាជន៍ (ដូច **ឆត្ត**) ។

បាតីចិ ទិសខាងលិច។

បាតុ កិ.វិ. ឱ្យជាក់, ប្រាកដ។ -**ភាយ** ដើម្បីបាតុកម្ម, ដើម្បីកិ.ធ្វើឱ្យប្រាកដ។ -**ភូតមត្ត** គុ. គ្រាន់តែកើតប្រាកដហើយ។ **បាតុឥត្ថាចក:** និបាតប្រាប់អត្ថគឺប្រាកដ, **អាវិ** ក៏ជាបាតុឥត្ថាចក:ដែរ, មួយទៀតសម្មុខាត្ថាចក: និបាតប្រាប់អត្ថគឺទីចំពោះមុខ, ជាក់ច្បាស់, **សម្មុខ**, **អាវិ**ក៏ជា **សម្មុខាត្ថាចក:** ដែរ, ម្យ៉ាងទៀត **បាតុ** ប្រព្រឹត្តទៅក្នុងអត្ថគឺ **បកាស** ប្រកាស, **សម្ភវ** កើត។

បាតុករិត្វា អ. [បាតុ+ករ+ត្វា, ចុះឥ-អា.] ធ្វើឱ្យប្រាកដហើយ, ធ្វើឱ្យជាក់ច្បាស់ហើយ។

បាតុកាម គុ. [បាតុं+កម+ណ] អ្នកចង់ដើម្បីផឹក;វិ. **បាតុं កាមេតីតি>បាតុកាមោ**។

បាតុភវិ កិ. [បាតុ+ភូ+អ+ណ្ឌ-អជ្ជ.] មានប្រាកដហើយ, កើតប្រាកដហើយ។

បាតុភវិស្សតি កិ. [បាតុ+ភូ+អ+ស្សតি-ភ. ចុះឥ-អា.] នឹងមានប្រាកដ, នឹងកើតប្រាកដ។

បាតុរហោសি កិ. [បាតុ+អ+ហុ+អ+ណ្ឌ-អជ្ជ., ចុះរ+ស-អា.] បានមានប្រាកដហើយ, បានកើតប្រាកដហើយ។

បាតុं អ. [បា+តុं] ដើម្បីផឹក, កិ.ផឹក។

បាតেតি កិ. [បតি+ណ+តি-រ.] ញ្ចុំង...ឱ្យធ្លាក់ចុះ, ទម្លាក់ចុះ (ជុះដាក់, ស្ពោះដាក់) ។

បាតেត្វា អ. [បតি+ណ+ត្វា] ញ្ចុំង...ឱ្យធ្លាក់ចុះហើយ,...។

បាតেយ្យាថ កិ. [បតি+ណ+ឯយ្យាថ-ស.] គប្បីញ្ចុំង...ឱ្យធ្លាក់ចុះ...។

បាតেសি កិ. [បតি+ណ+ណ្ឌ-អជ្ជ., ចុះស-អា.] ញ្ចុំង...ឱ្យធ្លាក់ចុះហើយ, ទម្លាក់ចុះហើយ។

បាតেស្សាមি កិ. [បតি+ណ+ស្សាមি-ភ.] នឹងញ្ចុំង...ឱ្យធ្លាក់ចុះ, នឹងឱ្យដួល, នឹងឱ្យរលំ។

បាតো និ. ក្នុងពេលព្រឹក, អំពីព្រឹក, អំពីព្រលឹម។ **បុព្វណ្ហត្ថាចកः** និបាតប្រាប់អត្ថគឺខាងដើមនៃថ្ងៃ, ពេលព្រឹកប្រែថា អំពីព្រឹក, **បគេ**ក៏ជា**បុព្វណ្ហត្ថាចកः**ដែរ។

បាថেយ្យ នបុં. [បថ+ណេយ្យ] (វត្ថុ) ជាប្រយោជន៍ក្នុងផ្លូវ, ឬជាប្រយោជន៍ដល់ផ្លូវ (ស្បៀង); វិ. **បថে បថស្ស ឥ ហិតं>បាថেយ្យं**។ -**ភិច្ច** នបុं. កិច្ចដោយវត្ថុជាប្រយោជន៍ក្នុងផ្លូវ, កិច្ចដោយស្បៀង។

បាទ បុं. [បទ+ណ] (អវយវ:) តែងដើរទៅ (ជើង); វិ. **បជ្ជតি គচ্ছតীតি>បាទោ**។ -**ឥមត្ថិក** ន. ក្បឿងជាទីរងនូវជើង, អំបែងសម្រាប់រងនូវជើង។ -**ករុក្ករុច្ច** នបុं. កិ.រពឹសដោយជើង, កិ.រពឹសនៃជើង។ -**អគ្ឆរក** គុ. ដល់នូវតម្លៃបាទមួយ, គួរនូវតម្លៃបាទមួយ។ -**ករុដ្ឋក** បុं. មេម្រាមនៃជើង, មេជើង។ -**ចលន** នបុं. កិ.កម្រើកនៃជើង, កិ.ញាប់ញ័រនៃជើង។ -**ច្ឆិទ្ធ** នបុं. ប្រហោងនៃជើង, ចង្វៃកនៃជើង។ -**ដ្ឋាន** នបុं. ទីជាទីតាំងនៃជើង, ទីនៃជើង។ -**តល** នបុं. ផ្ទៃនៃជើង។ **ឆោវនន-ហានាទិកាល** បុं. កាលមានកាលជាទីលាងនូវជើងនិងកាលជាទីងូតជាដើម។ -**ឆោវនមត្ត** គុ. វត្ថុគ្រាន់តែទឹកសម្រាប់លាងនូវជើង, សព្វបើទឹកសម្រាប់លាងនូវជើង។ -**ឆោវនុទក** នបុं. ទឹកសម្រាប់លាងនូវជើង។ -**អន្ត** នបុं. ទី

		បំផុតនៃជើង, ចុងនៃជើង។ -**បរិកម្មានិការក** គុ. អ្នកធ្វើនូវកិច្ចមានបរិកម្មនូវជើងជាដើម។ -**បរិចារិកា** ឥ. ស្ត្រីអ្នកបម្រើនូវជើង, ស្ត្រីអ្នកបម្រើទៀបជើង (ប្រពន្ធ) ។ -**បស្ស** នបុં. ខាងនៃជើង។ -**ប៉ំសុ** នបុં. អាចម៍ដែលជាប់ព្ធដ៏ជើង, លម្អិតដីនៃជើង។ -**ឋិដ្ឋិ** ឥ. ខ្នងនៃជើង, ខ្នងនៃព្រះបាទ។ -**ឋីឋកា** ឥ. តាំងជាទីរងនៃជើង។ -**ឋីឋ** នបុં. តាំងជាទីរងនូវព្រះបាទ, សម្រាប់ទ្រនូវព្រះបាទ។ -**បុញ្ជនក** គុ. ឱ្យជាសំពត់ជូតនូវជើង។ -**មត្ត** គុ. ទ្រព្យត្រឹមតែបាទមួយ, ត្រឹមតែមួយបាទ។ -**មូល** នបុં. ប្រទេសជាទីតាំងនៃជើង, ជាទីតាំងនៃជើង, ទីជិតនៃជើង។ -**មូលិក** គុ. បុរសអ្នកប្រកបក្នុងប្រទេសជាទីតាំងនៃជើង, អ្នកប្រកបក្នុងទីជិតនៃជើង។ -**សញ្ញត** គុ. អ្នកមានជើងសង្ក្រមហើយ, អ្នកសង្ក្រមហើយដោយជើង។ -**សម្ហាហន** នបុં. កិ.ច្របាច់នូវជើង, កិ.នូតនូវជើង។
បាទកដក	បុំ.	គ្រឿងប្រដាប់ជើង (ដូច **បាទន្ទុ**) ។
បាទគណ្ឋី		កជើង (ដូច **គោឋ្ឋ**) ។
បាទគ្ត	នបុំ.	ចុងជើង (ដូច **ឋបទ**) ។
បាទន្ទុ	នបុំ.	គ្រឿងប្រដាប់ជើង (ដូច **ទ្ទុរ**) ។
បាទបរិចារិកា	ឥ.	ប្រពន្ធ (ដូច **ជាយា**) ។
បាទប	បុំ.	ឈើ (ដូច **ឋិដ្ឋី**) ។
បាទផោដ	បុំ.	ជើងបែក, បែកនៃជើង (ដូច **ឋិបាទិកា**) ។
បាទហិត	នបុំ.	វត្ថុជាប្រយោជន៍ដល់ជើងមានទឹកសម្រាប់លាងជាដើម ។
បាទាសិ	កិ.	[ប+អ+ទា+អ+ណ្ឍ-អជ្ជ., ចុះ-ស-អា.] បានឱ្យទូទៅហើយ, បានប្រគល់ឱ្យហើយ, បានថ្វាយហើយ។
បាទិក	គុ.	ឧបសគ្គ២០មាន **ឋ** ជាដើម, សព្ទនេះជាអត្ថនៃ **ឧបសគ្ត**សព្ទ។
បាទុ		ស្បែកជើង (ដូច **ឧបាហន**) ។
បាទុកបត្តថាល-កធមករកកាយ-ពន្ធនអំសពន្ធន-មណ្ហាន	នបុំ.	[បាទុក+បត្ត+ថាលក+ធមករក+កាយពន្ធន+អំសពន្ធន+មណ្ហាន] កិ. ប្រដាប់ដោយទ្រនាប់ជើងនិងបាត្រនិងសៀននិងធមក្រកនិងវត្ថពន្ធ និងអង្ស៊ីក (**កាយពន្ធន**សំពត់សម្រាប់ចងនូវកាយ, **អំសពន្ធន** សំពត់សម្រាប់ពាក់ព្ធដ៏ស្មា) ។
បាទុកមណ្ហាន	នបុំ.	[បាទុក+មណ្ហាន] កិ.ប្រដាប់នូវទ្រនាប់ជើង, កិ.ប្រដាប់ដោយទ្រនាប់ជើង។
បាទុកមណ្ហា-ឧបាទុ-យោគ	បុំ.	[បាទុក+មណ្ហាន+អនុយោគ] ការប្រកបតាមនូវកិ.ប្រដាប់ដោយទ្រនាប់ជើង។

បាទុកា ទ្រនាប់ជើង, ជ្រញ់ទ្រជើង។

បាទូនរ បុ. សត្វពស់ (ដូច **ទ្ធិជិន្ទ**) ។

បាទោទក នបុ. [បាទ+ឧទក] ទឹកសម្រាប់លាងនូវជើង។

បាន នបុ. [បា+យុ] កិ.ផឹក; វិ. **បិវិយតេតិ>បានំ**។ទីជាទីផឹក; វិ. **បិវតិ ឯត្ថាតិ> បានំ**។ ជាគ្រឿងផឹក; វិ. **បិវតិ ឯតេនាតិ>បានំ**។ ទឹកគឺបុគ្គលគប្បីផឹក; វិ. **បាតព្ពន្តិ> បានំ**។ -**ភោជន** នបុ. ទឹកនិងភោជន, ទឹកគឺបុគ្គលគប្បីផឹកនិងបាយគឺបុគ្គលគប្បីស៊ី។ -**អាគារ** នបុ. ផ្ទះជាទីផឹក (រោងសុរា) ។

បានកូប បុ. អណ្តូងទឹក (ដូច **ឧទបាន**) ។

បានមណ្ឌល នបុ. បន្ទប់ទឹក, កន្លែងជាទីផឹក (ដូច **អាបាន**) ។

បានីយ គុ.ន [បា+អនីយ] (ទឹក) គឺបុគ្គលគប្បីផឹក; វិ. **បាតព្ពន្តិ>បានីយំ**។ -**ឃដ** បុ. ក្អមសម្រាប់ដាក់នូវទឹកគឺបុគ្គលគប្បីផឹក, ក្អមដ៏ពេញដោយទឹកគឺបុគ្គលគប្បីផឹក។ -**ឃដបរិភោជនីយឃដ** បុ. ក្អមសម្រាប់ដាក់នូវទឹកគឺបុគ្គលគប្បីផឹកនិងក្អមសម្រាប់ដាក់នូវទឹកគឺបុគ្គលគប្បីប្រើប្រាស់, ក្អមសម្រាប់ដាក់នូវទឹកឆាន់និងក្អមសម្រាប់ដាក់នូវទឹកប្រើប្រាស់។ -**ទារក** បុ. បំពង់សម្រាប់ដាក់នូវទឹកគឺបុគ្គលគប្បីផឹក, ដបសម្រាប់ដាក់នូវ...។

បាប នបុ. [ប+អបិ+អ] (អកុសល) ញ្ជាំងសត្វឱ្យដល់នូវទុក្ខមានអបាយទុក្ខជា
ឬគុ. ដើម (បាប, លាមក, អាក្រក់); វិ. **សត្តេ អបាយាទិទុក្ខំ បាបេតីតិ> បាបំ**។

បាបក គុ. [បាប+ក] ជាបាប, ដ៏លាមក, អាក្រក់។

បាបកម្ម នបុ. [បាប+កម្ម] កម្មជាបាប, កម្មដ៏លាមក, កម្មដ៏អាក្រក់។

បាបកម្មី គុ. [បាបកម្ម+ណ្ឍ] អ្នកមានបាបកម្ម, អ្នកមានកម្មដ៏លាមក; វិ. **បាបំ កម្មំ>បាបកម្មំ, បាបកម្មំ យស្ស អត្ថីតិ>បាបកម្មី**។

បាបការី គុ. [បាប+ករ+ណី] អ្នកធ្វើនូវបាប; វិ. **បាបំ ករោតីតិ>បាបការី**។ អ្នកធ្វើនូវបាបដោយប្រក្រតី; វិ. **បាបំ ករោតិ សីលេនាតិ>បាបការី**។ អ្នកមានកិ.ធ្វើនូវបាបជាប្រក្រតី; វិ. **បាបំ ការ សីលមស្សាតិ> បាបការី**។

បាបគរហី គុ. [បាប+គរហ+ណី] អ្នកតិះដៀលនូវបុគ្គលបាប, នូវបុគ្គលលាមក, នូវបុគ្គលអាក្រក់; វិ. **បាបំ គរហតីតិ>បាបគរហី**។ ចងវិគ្គហៈជា ៣សាធនៈដូច «**បាបការី**» ក៏បាន។

បាបជីវិត នបុ. [បាប+ជីវិត] ជីវិតដ៏លាមក, ការរស់នៅដ៏លាមក, ការរស់នៅដោយលាមក។

បាបតរ គុ. [បាប+តរ] បាបជាង, លាមកជាង, អាក្រក់ជាង (បាបវិសេស, លាមកវិសេស)។

បាបធម្ម បុ.ឬ គុ. [បាប+ធម្ម] ធម៌ជាបាប, ធម៌លាមក, អ្នកមានធម៌ជាបាប, អ្នកមានធម៌លាមក។

បាបនិន្ន គុ. [បាប+និន្ន] ឱនទៅក្នុងបាប, បង្ហោនទៅក្នុងបាប។ **និន្ន**<និ+នម៊+ណ, ម៊>និ, លុបណ។

បាបន នបុ. ការដល់, សេចក្ដីដល់។

បាបភាវ បុ. [បាប+ភាវ] ភាវ:នៃ...ជាអ្នកបាប, ជាអ្នកលាមក។

បាបតិរុតា សេចក្ដីខ្លាចអំពីបាប (ដូច **ឱត្តប្ប**) ។

បាបមិត្ត បុ.ឬ គុ. [បាប+មិត្ត] មិត្រជាបាប, មិត្រលាមក, អ្នកមានមិត្រលាមក។ -**សំសគ្ត** បុ. កិ.ច្រឡ្ងកច្រឡ្ងដោយបាបមិត្រ, កិ.ជាប់ជំពាក់ដោយ...។ **សំសគ្ត**<សំ+ សជ+ណ។

បាបយិម្ហ កិ. [ប+អប+ណយ+ម្ហ-អជ្ជ., ចុះ-ឥ-អា.] ញ្ចាំង...ឱ្យដល់ហើយ,ឱ្យលុះហើយ។

បាបរាសិ បុ. [បាប+រាសិ] គំនរនៃបាប, កងនៃបាប។

បាបវគ្គវណ្ណនា ឥ. [បាបវគ្គ+វណ្ណ+យុ+អា-ឥ.] កថាជាគ្រឿងពណ៌នានូវបាបវគ្គ, កថាជាគ្រឿងពណ៌នានូវសេចក្ដីនៃបាបវគ្គ; វិ. **បាបវគ្គំ បាបវគ្គស្ស ឆ អត្ថំ ឆណ្ណេតិ ឯតាយាតិ>បាបវគ្គវណ្ណនា**។

បាបវូបសមន នបុ. [បាប+វិ+ឧប+សម៊+យុ] កិ.ចូលទៅរម្ងាប់វិសេសនូវបាប, កិ.ចូលទៅរម្ងាប់នូវបាប; វិ. **វូបសមិយតេតិ>វូបសមនំ, បាបស្ស វូបសមនំ> បាបវូបសមនំ**។

បាបសុបិន បុ. [បាប+សុបិន] សុបិនដ៏លាមក, កិ.យល់សប្ដិដ៏លាមក, កិ.យល់សប្ដិអាក្រក់។

បាបិក គុ. [បាប+ណិកឬឥក] លាមក, អាក្រក់, មានបាប, នាំមកនូវបាប។

បាបិច្ឆ គុ. [បាប+ឥច្ឆា] អ្នកមានសេចក្ដីប្រាថ្នាដ៏លាមក, អ្នកមានសេចក្ដីប្រាថ្នាជាបាប; វិ. **បាបា ឥច្ឆា យេសំ តេ>បាបិច្ឆា**។

បាបិត គុ. [ប+អប+ត, ចុះ-ឥ-អា.] គឺ...ឱ្យដល់ហើយ; វិ. **បាបិយិត្ថាតិ>បាបិតោ**។

បាបិម គុ. [បាប+ឥមន្តុ] អ្នកមានបាប, អ្នកប្រាថ្នានូវបាប; វិ. **បាបំ យស្ស អត្ថីតិ>បាបិមា, បាបំ ឥច្ឆតីតិ>បាបិមា**។ បុ. មារ (ដូច

ឥសវត្ថ) ។

បាបិយ គុ. [បាប+ឥយ] បាបជាង, លាមកជាង, បាបដោយវិសេស, លាមកដោយវិសេស (អាក្រក់ជាង); វិ. **ឥមេ បាបា អយមិមេសំ ឥតិ សេសេន បាបោតិ>បាបិយោ**។

បាបុណន្ត គុ. [ប+អបិ+ឧណា+អន្ត] កាលដល់, កាលលុះ។

បាបុណន្តិ កិ. [ប+អបិ+ឧណា+អន្តិ-រ.] រមែងដល់, រមែងលុះ។

បាបុណាតុ កិ. [ប+អបិ+ឧណា+តុ-ប.] ចូរដល់, ចូរលុះ។

បាបុណិ កិ. [ប+អបិ+ឧណា+ណ្យ-អជ្ជ.] ដល់ហើយ, លុះហើយ, ទាន់ហើយ។

បាបុណោ កិ. [ប+អបិ+ឧណា+ឯយ្យ-ស.] គប្បីដល់, គប្បីលុះ, គប្បីទាន់។

បាបុណោយ្យុំ កិ. [ប+អបិ+ឧណា+ឯយ្យុំ-ស.] គប្បីដល់,...។

បាបេ អា.ឥ. [បាបា+សិ-វិ., យកស្រះអានៃបា+សិ>ឯ] ម្នាលស្រីបាប, ម្នាលស្រីលាមក។

បាបេតិ កិ. [ប+អបិ+ណេ+តិ-រ.] ញ្ជាំង...ឱ្យដល់,...។

បាបេតុំ អ. [ប+អបិ+ណេ+តុំ] ដើម្បីញ្ជាំង...ឱ្យដល់, កិ.ញ្ជាំង...ឱ្យដល់។

បាបេត្វា [ប+អបិ+ណេ+ត្វា] ញ្ជាំង...ឱ្យដល់ហើយ។

បាបេយ្យ កិ. [ប+អបិ+ណេ+ឯយ្យ-ស.] គប្បីញ្ជាំង...ឱ្យដល់។

បាបេសិ កិ. [ប+អបិ+ណេ+ណ្ឌ-អជ្ជ., ចុះ-ស-អា.] ញ្ជាំង...ឱ្យដល់ហើយ។

បាបេស្សតិ កិ. [ប+អបិ+ណេ+ស្សតិ-ភ.] នឹងញ្ជាំង...ឱ្យដល់។

បាភដ នបុં. [បឋម+អាភដ] ទ្រព្យដែលគេនាំមកហើយជាដំបូង (ទ្រព្យជាដើមទុន); វិ. **បឋមំ អាភតំ>បាភដំ**។ ទ្រព្យដែលបុគ្គលអ្នកប្រាថ្នានាំមក; វិ. **បត្ថេន្តេហិ អា- ភរីយតេតិ>បាភដំ**។ អាភដ<អា+ភរ+ត, ត>ដ, លុបរ។

បាភត នបុં. ទ្រព្យជាដើមទុន, ថ្លៃ (ដូច **មូល**), បណ្ណាការ, ចំនួនដែលគេបញ្ជូនទៅ (ដូច **ឧបាទ**) ។

បាមោក្ខ គុ. [បមុខ+ណ] អ្នកបិតនៅក្នុងភាវៈនៃខ្លួនជាប្រមុខ (ជាប្រធាន), ប្រសើរ, ខ្ពង់ខ្ពស់ (ដូច **សេដ្ឋោ**); វិ. **បមុខភាវេ ឋិតោ>បាមោក្ខោ**។

បាមោជ្ជ នបុં. [បមុទិត+ណ្យ] ភាវៈនៃបុគ្គលអ្នករីករាយទូទៅ, ភាវៈនៃចិត្តរីករាយទូទៅ (សេចក្ដីរីករាយទន់); វិ. **បមុទិតស្ស បុគ្គលស្ស ចិត្តស្ស ភាវោ>បាមោជ្ជំ**។ -**ពហុល** គុ. ច្រើនដោយសេចក្ដីរីករាយទន់, ច្រើនដោយប្រាមោទ្យ។

បាម នបុ. កម, រមាស់ (ដូច **ភន្ធ**) ។

បាយមាន គុ. [បា+ណយ+មាន] កាលឱ្យផឹក, កាលញ៉ាំង...ឱ្យផឹក។

បាយាសបាដិ ឥ. [បាយាស+បាដិ] ភាជន:នៃបាយបាយាស, ភាជន:ដាក់នូវបាយបាយាស, ភាជន:ដ៏ពេញដោយបាយបាយាស។

បាយាសបិណ្ឌ បុ. [បាយាស+បិណ្ឌ] ដុំនៃបាយបាយាស។ **បាយាស**<បា+អស= បាយទាំងគឺបុគ្គលគប្បីផឹកទាំងគឺបុគ្គលគប្បីស៊ី (យកអានៃបា> អាយ+អស>បាយាស) ។

បាយាសិ កិ. [ប+អឬអា+យា+អ+ណ្យ-អជ្ជ. ចុះ-អា.] ទៅហើយ, ដើរទៅហើយ, បរទៅហើយ។

បាយាស បុ. បាយបាយាស, បាយលាយដោយទឹកដោះ, បាយដ៏ឧត្តម (ដូច **បរមន្ន**) ។

បាយីសុ កិ. [ប+អា+យា+អ+ឧំ-អជ្ជ.] ទៅហើយ, ដើរទៅហើយ (<បា+ណយ+ ឧំ-អជ្ជ.) ផឹកហើយ។

បាយុ វ្ចមគ្គ (ដូច **ភុជ**) ។

បាយេតិ កិ. [បា+ណេ+តិ-វ., អានៃបា>អាយ] ផឹក, ចៅ, ញ៉ាំង...ឱ្យផឹក, ឱ្យ ចៅ។

បាយេត្វា អ. [បា+ណេ+ត្វា, អានៃបា>អាយ] ញ៉ាំង...ឱ្យផឹកហើយ, ឱ្យចៅហើយ។

បាយេន្ត គុ. [បា+ណេ+អន្ត] កាលញ៉ាំង...ឱ្យផឹក, ឱ្យចៅ...។

បាយេហិ កិ. [បា+ណេ+ហិ-ប., អានៃបា>អាយ] ចូរញ៉ាំង...ឱ្យផឹក, ឱ្យចៅ។

បាយោ ពហុល្យត្ថវាចក:និបាតប្រាប់អត្ថគឺច្រើន។

បាយ ធា. **ឆុឌ្ឍិយំ បាយតិ** "ចម្រើន, ថ្កើងថ្កាន" ភ្ជ. ។ **បាយោ** បុ. "សេចក្តីចម្រើន" ។ **អបាយោ** បុ. "អបាយ, ឥតមានសេចក្តីចម្រើន" វិ. **ឆត្ថិ បាយោ ឆុឌ្ឍិ ឯត្ថាតិ អបាយោ, អយតោ សុខតោ អបេតោតិ ឥ អបាយោ** -ស. ។ **ឋីតោ ឋីតឥ** កិ.គុ. ផ្លាស់ អា ជា ណ្យ លុប យ ចេញ។

បារគត គុ. [បារ+គត] អ្នកដល់ហើយនូវត្រើយ, អ្នកមានត្រើយដល់ហើយ; វិ. **បារំ គតោ >បារគតោ**។ **បារ**<បារ+អ=ត្រើយ, និព្វាន, ខាងនាយ។

បារគវេសី គុ. [បារ+គវេសិ+ណី] អ្នកស្វែងរកនូវត្រើយ, អ្នកមានកិ.ស្វែងរកនូវត្រើយជាប្រក្រតី; វិ. **បារំ គវេសតីតិ>បារគវេសី**, **បារំ គវេសិតុំ សីលមស្សាតិ> បារគវេសី**។

បារគាមី គុ. [បារ+គមិ+ណី] អ្នកដល់នូវត្រើយ, អ្នកមានកិ.ដល់នូវត្រើយជា

ប្រក្រតី។

បារគូ គុ. [បារ+គមិ+រ] អ្នកដល់នូវត្រើយ; វិ. **បារំ គច្ឆតីតិ>បារគូ**។

បារទ បុ. បារទ (បារ៉ទ) (ដូច **រស**) ។

បារមី ឥ. [បរម+ណ្យ] ភាវៈនៃពោធិសត្វដ៏ឧត្តមឬអំពើនៃពោធិសត្វដ៏ឧត្តម; វិ. **បរមស្ស ឧត្តមស្ស ពោធិសត្តស្ស ភាវោ កម្មំ វា>បារមី**។

បារម្ប្យរិយ នបុ. ពាក្យប្រដៅដែលមកហើយអំពីអាចារ្យក្នុងកាលមុន (ដូច **ឧបទេស**) ។

បារលោកិក គុ. ធម្មជាតប្រព្រឹត្តទៅក្នុងលោកខាងមុខ (ដូច **សម្ប្យាយិក**) ។

បារជិកាប-ត្តិអាបជ្ជន នបុ. [បារជិក+អាបត្តិ+អាបជ្ជន] កិ.ត្រូវនូវអាបត្តិឈ្មោះបារជិក។

បារបារ គុ. [បារ+អបារ] ត្រើយនិងមិនមែនត្រើយ, ត្រើយតូចនិងត្រើយធំ។

បារាវតបាទ-សទិសបាទ គុ. [បារាវត+បាទ+សទិស+ បាទ] មានជើងប្រាកដស្មើដោយជើងនៃព្រាប; វិ. **បារាវតស្ស បាទា>បារាវតបាទា, បារាវតបាទេហិ សទិសា បាទា យេសំ តានិ>បារាវតបាទសទិសបាទានិ**។ ប្រើជា **បារាឍត**ក៏មាន។

បារាវត បុ. សត្វព្រាប (ដូច **កបោត**) ។

បារិចរិយា ឥ. ការបម្រើ (ដូច **ឧបាសនា**) ។

បារិច្ឆត្តក បុ. [បរិច្ឆត្ត+ណក] ដើមបារិច្ឆត្តកៈ, បារិច្ឆត្តកព្រឹក្ស, ដើមឈើតាំងនៅដូចជាឆត្រដោយជុំវិញ, ដើមរលួសផ្ទុង, ដើមឈើទេវតា (ដូច **កោវិឡារ**); វិ. **បរិសមន្តតោ ឆត្តំ វិយ តិដ្ឋតីតិ>បារិច្ឆត្តកោ**។ -**រុក្ខ** បុ. ដើមនៃបារិច្ឆត្តកៈ, បារិច្ឆត្តកព្រឹក្ស។ -**កុសុម** បុ. ផ្កានៃឈើឈ្មោះបារិច្ឆត្តកៈ។

បារិជាតក បុ. ដើមឈើទេវតាក្នុងស្ថានសួគ៌ (ដូច **កោវិឡារ**) ។

បារិបូរិការិតា ឥ. [បារិបូរិការី+តា] ភាវៈនៃបុគ្គលអ្នកធ្វើនូវកិ.ពេញជុំវិញ, នូវកិ.ពេញលេញ, ភាវៈនៃបុគ្គលអ្នកធ្វើឱ្យបរិបូណ៌, ឱ្យគ្រប់គ្រាន់; វិ. **បរិបូរ-យតេ>បារិបូរិ**។ **បារិបូរឺ ក�តីតិ>បារិបូរិការី**។ **បារិបូរិការិ-នោ ភាវោ>បារិបូរិការិតា** ។

បារិមតីរ នបុ. [បារិម+តីរ] ត្រើយឬឆ្នេរមានក្នុងទីខាងនាយ, ត្រើយខាងនាយ។ -**បារិម**<បារ+ ឥម=មានក្នុងទីខាងនាយ; វិ. **បារេ ភវំ>បារិមំ** (**តីរំ**) ។ **បារិមំ តីរំ>បារិមតីរំ**។ -**ទាសិក** គុ. អ្នកនៅទៀបឆ្នេរខាងនាយ, អ្នកនៅនាត្រើយខាងនាយ (**ទាសិក** <រសិ+ណោ+ក-សកត្ថ) ។

បារិលេយ្យក អ.ន. ស្រុកឈ្មោះបារិលេយ្យក:។ -**ឞនសណ្ឌ** បុ. ដងនៃព្រៃឈ្មោះបារិ-លេយ្យក:។ -**ហត្ថី** បុ. ដំរីឈ្មោះបារិលេយ្យក:។

បារិសុទ្ធិសីល នបុ. [បារិសុទ្ធិ+សីល] សីលគឺសេចក្តីបរិសុទ្ធិ; រ. **បរិសុជ្ឈនំ>បារិសុទ្ធិ, បារិសុទ្ធិ ឯវ សីលំ>បារិសុទ្ធិសីលំ**។ (បរិ+សុធ+យ+យុ>បរិ-សុជ្ឈន) ។

បារិហារិយបក្ខ បុ. [បារិហារិយ+បក្ខ] ប័ក្ខនៃបារិហារិយឧបោសថ, ប័ក្ខនៃឧបោសថដែលបុគ្គលគប្បីរក្សា, ប័ក្ខដែលបុគ្គលគប្បីនាំបង់នូវធម៌ជាសត្រូវ (បារិហារិយប័ក្ខ) **បារិហារិយ**<បរិ+ហរ+ណ្យ+ឥ-អា. ។

បារុតចីវរ នបុ. [បារុត+ចីវរ] ចីវរដែល...ដណ្តប់ហើយ, ឃ្លុំហើយ (**បារុត**<ប+អា+រុ+ត, លុបប) = រ. **បារុបិយិត្ថាតិ>បារុតំ**។

បារុបតិ កិ. [ប+អា+រុ+អ+តិ-វ.] ដណ្តប់, ឃ្លុំ, ទទួរ។

បារុបន នបុ. [ប+អា+រុ+យុ] សម្រាប់ដណ្តប់, សម្រាប់ទទួរ, សម្រាប់ឃ្លុំ; រ. **បារុបតិ ឯតេនាតិ>បារុបនំ**។ -**កម្ពល** បុ. សំពត់កម្ពលសម្រាប់ដណ្តប់។ -**ឞ** នបុ. សំពត់ផ្ទាំងសម្រាប់ដណ្តប់។ -**ឞត្ថ** នបុ. សំពត់សម្រាប់ដណ្តប់។

បារុបន្ត គុ. [ប+អា+រុ+អន្ត] កាលដណ្តប់, កាលឃ្លុំ, កាលទទួរ។

បារុបមាន គុ. [ប+អា+រុ+មាន] កាលដណ្តប់, កាលឃ្លុំ។

បារុបិតព្ព កិ. [ប+អា+រុ+តព្ព, ចុ:ឥ-អា.] គឺ...គប្បីដណ្តប់។

បារុបិត្វា អ. [ប+អា+រុ+ត្វា+ឥ-អា.] ដណ្តប់ហើយ, ឃ្លុំហើយ, ទទួរហើយ។

បារុបិស្សាមិ កិ. [ប+អា+រុ+អ+ស្សាមិ-ភ., ចុ:ឥ-អា.] នឹងដណ្តប់,...។

បារេម កិ. [បរ+ណ+ម-វ.] រក្សា, បំពេញ, បាច។

បារេវក អ.ន. (ដំរី) ឈ្មោះបារេវក:។

បារេវជ បុ. សត្វព្រាប (ដូច **ឞ**ក្ខ**ជ**) ។

បារេហន្តរ នបុ. [បារេហ+អន្តរ] ចន្លោះនៃពួរជ្រៃ, រវាងនៃពួរជ្រៃ។

បារ នបុ. ព្រះនិព្វាន, ត្រើយនាយ, ច្រាំងខាងនាយ។

បារ ធ. **ឞ**ម្ម**សម្ប**ត្តិ**យ**ំ **ចារេតិ ចារយតិ** "ដល់ព្រមនៃការងារ, សម្រេច" ចុ. ។ អា. **ឞ**ិ**ក្ខ**ាមិ **ន ចារេ**មិ **ន ចារ**េមិ =**ឞ**ិ**ន្ធ**ិ**ត**ុ**ំ ន ស**ក្ខោ**មិ** - ស. ។ **ចារ**ំ នបុ. "ត្រើយនាយ, ទីបញ្ចប់, ព្រះនិព្វាន" ។

បាល អ.ន. ឈ្មោះបាល:។

បាលយំ គុ. [បាលយន្ត+សិ-រ., ន្ត+សិ>អំ] កាលរក្សា, កាលចិញ្ចឹម។

បាលិត គុ. [បាល+ត, ចុ:ឥ-អា.] គឺ...រក្សាហើយ។ អ.ន. ឈ្មោះបាលិត។

បាលិតច្ឆកតិរីក-ណ្ណិកជយកុសុ-ហាទិតេឧ គុ. ផ្សេងដោយផ្កាមានផ្ការលួសបាយ (ឬផ្កាចា) និងផ្កាអញ្ជ័នខៀវ (ឬផ្កាកណ្ណិកាភ្នំ) និងផ្កាច្បា (ឬផ្កាជយព្រឹក្ស) ជាដើម។បទសមាស។

បាលិតច្ឆ បុ. ដើមរលួសបាយ (ដូច **ភីសុក**) ។

បាលិ ធា. **ក្ខនេ បាលេតិ បាលយតិ បាលនំ បាលិតោ** "ចិញ្ចឹម, រក្សា" ចុ. ។ **បាលិ** ឥ. "បាលី" មានន័យ៣យ៉ាង៖

១/ ព្រះបាលីរក្សាទុកនូវអត្ថដូចជាភ្លឺស្រះរក្សានូវទឹកគឺអត្ថ។ ម្យ៉ាងទៀតញែក ប+អាលិ រៀបពាក្យដែលអ្នកប្រាជ្ញប្រកាសទុក។

២/ ភ្លឺ, មាត់ (ស្រះបឹង) បាលីថា **មហតោ តឡាកស្ស បាលិ** "ភ្លឺនៃស្រះធំ" ។

៣/ ជួរ, លំដាប់, បាលីថា **បាលិយា ឋិសិទ្ធីសុ**។

បាវក បុ. [បុ+ណ្ឌ] (សភាវ:) តែងជម្រះបំផ្លាញ (ភ្លើង);វិ. **បុណ្ណាតីតិ>បាវកោ**។

បាវចន នបុ. [បធាន+វចន] ពាក្យជាប្រធាន (ពុទ្ធវចន);វិ. **បធានំ ឞ្ចនំ>បាវចនំ។**

បាវចនំ ពុទ្ធវចន:, ពាក្យជាប្រធាន

បាវទិ កិ. [ប+អ+វទ+អ+ល្យ-អជ្ជ.] បានពោលទូទៅហើយ, ពោលផ្ទួនហើយ, ពោលបន្ថែមហើយ។

បាវន នបុ. ការអុមឬរោយ (នូវអង្ការជាដើម) (ដូច **ឞ**) ។

បាវស្សិ កិ. [ប+រស្សិ+អ+ល្យ-អជ្ជ., អនៃប>អា] ស្រោចចុះហើយ, បង្អុរចុះហើយ, ធ្លាក់ចុះហើយ។

បាវារិការាម បុ. [បាវារិក+អារាម] អារាមឈ្មោះបាវារិក:។

បាវិសិ កិ. [ប>បា+រិសិ+អ+ល្យ-អជ្ជ.] ចូលទៅហើយ, ចូលមកហើយ។

បាវុស បុ. រដូវភ្លៀង (ដូច **ឞ**), ត្រីសណ្ដាយ ។

បាវេយ្យក គុ. [បាវា+ឯយ្យក] អ្នកនៅក្នុងក្រុងឈ្មោះបាវា។

បាស បុ. [បា+ស] អន្ទាក់ (វិ. **ចាតិ ក្ខតិ អឞយវេតិ>ចាសោ**) ម្យ៉ាងទៀត (ឞ+ណ= ប្រែថាចង, ទាក់), វិ. **ឞ្ដ ឞសេតិ ឯតេនាតិ>ចាសោ**។ ចាច់សក់ឬផ្ទ្ធងសក់ (**ភេសចយ**) ។ -**ដ្ឋាន** នបុ. ទីជាទីតាំងនៃអន្ទាក់, ទីជិតនៃអន្ទាក់។ -**ឞ** ប.សំ. រយនៃអន្ទាក់។

បាសក បុ. [ឞ+ណ្ឌ](ប្រែថា ជៀតជៀន, ពាល់ត្រូវ) បាសកា, ក្ងនបាសកា (ដូច **អក្ខ**) ។

បាសណ្ឌ បុ. លទ្ធិ៣៤និងទិដ្ឋិ៦២រួមជា ៩៦ហៅថា **ចាសណ្ឌ**។ ប្រែថា ចោះទៅនូវអន្ទាក់គឺទិដ្ឋិក្នុងចិត្តនៃសត្ត។

បាសនី ឥ. កែងជើង (ដូច **បណ្ហិ**) ។

បាសាណទារណ បុ. ដែកសម្រាប់ចោះថ្ម (ដូច **ដ**ំ**ក**) ។

បាសាណមច្ច បុ. ត្រីស្លាត, ត្រីក្អែក (ដូច **បាមីន**) ។

បាសាណមណិ បុ. [បាសាណ+មណិ] កែវមណីដែលកើតអំពីថ្ម, កែវមណីជាវិការ:នៃថ្ម។

បាសាណមយ គុ. [បាសាណ+មយ] ជាវិការ:នៃថ្ម, សម្រេចហើយដោយថ្ម, កើតហើយអំពីថ្ម (**ឥ**ិ**ការ**ត**ទ្ធិ**ត, **និ**ម្ច**ន**ត**ទ្ធិ**ត, **ជ**ាត**ត**ទ្ធិ**ត**) ។

បាសាណសម្ភវ គុ. [បាសាណ+សម្ភវ] មានថ្មជាដែនកើតព្រម; វិ. **បាសាណោ សម្ភោ យស្ស តំ** >**បាសាណសម្ភ**ំ។ **បាសាណ**<បស្ស+ស និ+អ, បស្ស>បា, ស>សា, និ>ណ =ប្រែថាដល់នូវខាង; វិ. **បស្សំ ស ន តិ បាបេ តីតិ** >**បាសាណោ**។

បាសាទ បុ. [ប+ស ទ+ណ] ប្រទេសជាទីជ្រះថ្លានៃភ្នែកនិងចិត្ត (ប្រាសាទ); វិ. **ប ស ី ទ ន្ត ិ ន យ ន ម ន ា ន ិ អ ត្រ េ ត ិ**>**ប ា ส า ท ោ**។ -**ក ូ ដ** នបុ. កំពូលនៃប្រាសាទ។ -**ត ល** នបុ. ផ្ទៃនៃប្រាសាទ។ -**ប ริ ว ณ ะ** នបុ. បរិវេណនៃប្រាសាទ។ -**ម ห า** នបុ. កិ.ឆ្លងនូវប្រាសាទ, កិ.ឆ្លងនូវប្រាសាទ។

បាសាទិក គុ. [ប ส า ท+ณ ิ ก] នាំមកនូវសេចក្តីជ្រះថ្លា; វិ. **ប ส า ท ํ อ า ว ห า ต ี ต ิ**> **ป า ส า ท ิ โ ก**។ ប្រកបដោយសេចក្តីជ្រះថ្លា; វិ. **ป ส า ท ช น ิ ย ุ ต ฺ โ ต**> **ป า ส า ท ิ โ ก**។ គួរដល់សេចក្តីជ្រះថ្លា; វិ. **ป ส า ท ส ฺ ส อ า ร ห า ต ี ต ิ**> **ป า ส า ท ิ โ ก**។ -**ត ร** គុ. នាំមកនូវសេចក្តីជ្រះថ្លាជាង។

បាហសិ កិ. [ป>ปา+ห า ร ิ+អ+ญ ฺ-អ ช ฺ ช ., ช ุ ะ ส-อา.] ប្រហារហើយ។

បាហុនក បុ. [ปาหุน+ณิก, លុបណ, ឥ-អา.] អ្នកគួរដើម្បីទទួលនូវគ្រឿងបូជាដោយប្រការទាំងពួង (ភ្ញៀវ); វិ. **ส ว ฺ ห ุ ย ก า ร เ ร น อ า ห ว ห ํ อ ร ห า ต ี ต ิ**> **ป า ห ุ น โ ก**។ (**ป า ห ุ น**<ป+អา+ ห ุ+ยุ ឬ ป+ห ุ+ยุ, ป>ปา) ។

បាហុនទាន នបុ. [ปาหุน+ทาน] ទានដែលបុគ្គលតាក់តែងដោយសក្ការ:ដើម្បីប្រយោជន៍ដល់ញាតិនិងមិត្រដែលមកអំពីទិសតូចនិងទិសធំ, ទានដែលបុគ្គលគប្បីឱ្យដល់ភ្ញៀវ។

បាហេសិ កិ. [ป>ปา+ห ิ+អ+ญ ฺ-អ ช ฺ ช ., ช ุ ะ ส-อา.] បញ្ជូនទៅហើយ, ផ្ញើទៅហើយ, បណ្តែតទៅហើយ។

បាឡ្ឍ ឥ. ដងព្រៃ, ១ របៀបព្រៃ (ដូច **ป ต ฺ ถ ิ**), **ส ส ฺ ส ุ** (ទំនប់, ខ្ទ ឿ ន, ថ្ម ល់, ស្ពាន) ត ន ្ ត ិ (**ต ุ ฐ ฺ ฐ ว จ น**) ។

ปิ ឬ ปี ធ. **ป ี ต ิ ย ํ ป ิ ณ า ต ิ ป ิ ณ า ต ิ ป ม โ ห ป ิ ย ो ป ี ต ิ** "ផ្ទ ែ ត ចិ ត ្ ត,

រីករាយ, ស្រឡាញ់" សុ. ។

បិក បុ. សត្វតាវ៉ៅ (ដូច **ក្ករណ្ឌាល**) ។

បិङ្គល អ.ន. ឈ្មោះបិङ្គល:; គុ. លឿង, មានភ្នែកលឿង។

បិङ្គលកិបិល្លក បុ. [បិङ្គល+កិបិល្លក] ស្រមោចលឿងនិងស្រមោចក្រហម (អង្ក្រង) ។

បិङ្គលមក្ខិកា ឥ. សត្វរបោម (ដូច **ឌំស**) ។

បិङ្ក សម្ព្ករដំដែងខ្ចៅក្រហមលឿងទន់ (ដូច **ឬលङ្ក**) ។

បិចុ សំឡី (ដូច **ភូល**) ។

បិចុល បុ. ឈ្មោះឈើម្យ៉ាង (ដូច **ឈាលុក**) ។

បិច្ឆិល គុ. [បិច្ឆ+ឥល] រអិល, ឱ្យជាទីរអិល។ ន. ដើមរកា។

បិញ្ជ បុ. [បតិ+ឆអនៃប>ឥ, ចុះនិគ្គហិតអា., លុបត] កន្ទុយ, កំបោ៉ាយ, ស្លាប; វិ. **បតិតុមិច្ឆតិ យេន តំ>បិញ្ជំ**។ (ប្រើជា **ឬញ្ជ**ក៏មាន) ។

បិញ្ជ នបុ. ស្លាបសត្ត (ដូច**ឬក្ខ**), កន្ទុយក្ងោក (ដូច **ក**ណ**ាប**) ។

បិញ្ជ ធា. **ភាសាហ៊ីសាពលទានានិកេតនេសុ ឬញ្ជេតិ ឬញ្ជយតិ** "ពោល, បៀតបៀន, អាច, មានកម្លាំង, នៅ, អាស្រ័យ" ចុ. ។

បិដក នបុ. [បិដ+ណ្ឍ] ប្រែថាបញ្ចេញសំឡេង, ពោល, សម្តែង (ល្ម, ក ញ្ជ, ច្រែង), ភាជន៍, ព្រះបរិយត្តិ; វិ. **បិដិយតិ សङ្ខិយតិ ឥតិ ឯតេនាតិ>បិដកំ**។

បិដ្ឋ គុ. [ប៊ីសិ+ឬ] (វត្ថុ) គឺ...ក៏ន ហើយ, របស់ដែលល្ងីត, ម្សៅ (ដូច **ចុណ្ណ**ិ**ត**); វិ. **ឬ ីសិយ ិ ាតិ>ឬ ិ ដ្ឋ**ំ។ **ឬ ិ ដ្ឋ** គុ. គឺ ខ ន្ត ិ យ ធ ិ ាតទាំ ង ឡ ាយ ក ិ ន ហ ើ យ ។ ។ **ឬ ិ ដ្ឋ** ន. ខ្ន ង, ខ ាង, ខ ាងក្ រ ោយ ។

បិដ្ឋ បុ. ម្សៅ (ដូច **ចូ**ណ**ៀ**) ។

បិដ្ឋ ១ ១ ១

ដោយខ្នងនៃថ្ម។

បិដ្ឋិមជ្ឈ គុ. [បិដ្ឋি+មជ្ឈ] កណ្តាលនៃខ្នង, ពាក់កណ្តាលនៃខ្នង។

បិដ្ឋិរំស បុ. រោងក្តឿង, រោងតាល់ក្តឿង។

បិដ ធា. **សङ្ឆសङ្ឆាតេសុ បេដតិ បេដកោ** "ចេញសំឡេង, ពោល, ប្រហារ, រួបរួម, ជាប់តគ្នា" ភូ. ។ **បិដកំ** នបុ. "បិដក, ព្រះត្រៃបិដក, កញ្ជើ, ល្ហ, ភាជន៍" ។

បិឍ ធា. **ហឺសាសङ្ខិលេសេសុ ឍិបតិ** "បៀតបៀន, សៅហ្មង" ភូ. ។ **ឍិបកោ** បុ. "ឆ្នាំង, ខ្ទះ " ។

បិឌ ធា. **សङ្ឆាតេ បិណ្ឌតិ** "រួបរួមគ្នា, ជាប់តគ្នា" រុ. ។ **បិណ្ឌោ** បុ. "ដុំបាយ, ដុំ, រាងកាយ, គ្រឿងចិញ្ចឹមជីវិត" ។

បិណ្ឌ បុ. [បិណ្ឌ+អ] ប្រែថាប្រមូល, ដុំ, ដុំនៃបាយ, ដុំនៃអាមិសៈ។ -**មត្ត** គុ. វត្ថុគ្រាន់តែបិណ្ឌៈ, ដុំបាយ។ ការចិញ្ចឹមជីវិត, វត្ថុសម្រាប់ចិញ្ចឹមជីវិត (ដូច **អាជីវន**), **ទេហ** (រាងកាយ), ប្រមូល, ផ្ទុំ, ធ្វើឲ្យជាគំនរ (ដូច **បិណ្ឌន**) ។

បិណ្ឌក បុ. [បិណ្ឌ+ណ្ឍ] ដុំនៃសាច់ស្មុង, កម្លាំងស្មុង, កម្លាំងជើង។ ប្រែថាកំញ្ជានក៏បាន។

បិណ្ឌចារិក គុ. [បិណ្ឌ+ចរ+ណី+ក-ស.] អ្នកមានកិ.ត្រាច់ទៅដើម្បីបិណ្ឌៈ (ឬបិណ្ឌបាត) ជាប្រក្រតី; វិ. **បិណ្ឌាយ ចរិតុំ សីលមស្សាតិ>បិណ្ឌចារី, បិណ្ឌចារី ឯវ> បិណ្ឌចារិកោ**។ បើដាក់ **វត្ត**ត្រង់ **សីល**ត្រូវប្រែថា ...ជាវត្ត។ អ្នកត្រាច់ទៅដើម្បីបិណ្ឌៈ (ឬបិណ្ឌបាត); វិ. **បិណ្ឌាយ ចរតីតិ>បិណ្ឌចារី, សោ ឯវ> បិណ្ឌចារិកោ**។ -**វត្ត** នបុ. វត្តនៃភិក្ខុអ្នក...។

បិណ្ឌន នបុ. ប្រមូល, ផ្ទុំ, ធ្វើឲ្យជាដុំ, ធ្វើឲ្យជាគំនរ, សព្ទនេះជាអត្ថន័យ **បិណ្ឌ** សព្ទ។

បិណ្ឌបាត បុ. [បិណ្ឌ+បត+ណ] កិ.ធ្លាក់ចុះនៃដុំអាមិសៈ (បិណ្ឌបាត); វិ. **អាមិសបិណ្ឌានំ បាតោតិ>បិណ្ឌបាតោ**។ កិ.ត្រាច់ទៅដើម្បីបិណ្ឌៈ; វិ. **បិណ្ឌាយ បាតោ> បិណ្ឌបាតោ**។ -**កាល** បុ. កាលនៃបិណ្ឌបាត, កាលជាទីត្រាច់ទៅដើម្បីបិណ្ឌបាត។ -**ឬដិក្ខ្ត** គុ. មានបិណ្ឌបាតត្រឡប់វិញហើយ, ត្រឡប់មកអំពីបិណ្ឌបាត, ត្រឡប់មកអំពីកិ.ស្វែងរកនូវបិណ្ឌបាត។ -**បដិលាភ** បុ. កិ.បានចំពោះនូវបិណ្ឌបាត។ -**បរិយេសន** នបុ. កិ.ស្វែងរកនូវ...។ -**វេលា** ឥ.

វេលានៃ..., វេលាជាទីត្រាច់ទៅដើម្បីបិណ្ឌបាត។

បិណ្ឌបាតិក គុ. [បិណ្ឌ+បតិ+ណី+ក-ស.] អ្នកមានកិ.ត្រាច់ទៅដើម្បីបិណ្ឌ:ជាវត្ត; វិ. **បិណ្ឌាយ បតិតុं ១ត្តមស្សាតិ>បិណ្ឌបាតី, បិណ្ឌបាតី ៦១>បិណ្ឌបាតិកោ**។ ន័យមួយទៀត: (**បិណ្ឌបាត+ណិក**) អ្នកស្វែងរកនូវបិណ្ឌបាតឬអ្នកប្រព្រឹត្តនូវបិណ្ឌបាត; វិ. **បិណ្ឌបាតं គវេសតីតិ>បិណ្ឌបាតិកោ, បិណ្ឌបាតं ចរតីតិ ១ា>បិណ្ឌបាតិកោ**។

បិណ្ឌិកា ឥ. ប្រែដូច **បិណ្ឌក**។

បិណ្ឌិត គុ. រាប់ (ដូច **គណិត**), គាន់ (ដូច **ឃន**) ។

បិតា បុ. [បា+រិតុ] (បុរស) អ្នករក្សានូវកូន (បិតា, ឪពុក); វិ. **បុត្តं ១ាតិ រក្ខតីតិ>បិតា**។ -**បុត្ត** បុ. បិតានិងបុត្រ។

បិតាមហ បុ. [បិតុ+អាមហ] បិតានៃបិតា, (តាឬជីតា); វិ. **បិតុនោ បិតា>បិតាមហោ**។

បិតិបក្ខ បុ. [បិតុ+បក្ខ, ឧនៃតុ>ឥ] ចំណែកនៃបិតា, ពួកនៃបិតា។

បិតុច្ឆា ឥ. [បិតុ+ច្ឆ+អា-ឥ.] ប្អូនស្រីនៃបិតា; វិ. **បិតុនោ ភគិនី>បិតុច្ឆា**។ -**ធីតា** ឥ. ធីតានៃប្អូនស្រីនៃបិតា។ -**បុត្ត** កូននៃប្អូនស្រីនៃបិតា។

បិតុបដ្ឋាន នបុ. [បិតុ+ឧបដ្ឋាន] កិ.បម្រើនូវបិតា, ទីជាទីបម្រើនូវបិតា។

បិតុវធ នបុ. [បិតុ+វធ] កិ.សម្លាប់នូវបិតា, កិ.បៀតបៀននូវបិតា (**១ធ**<ហនិ+ណ, ហន>វធ= វិ. **ហនតំ>១ធោ**) ។

បិតុសេនេហ បុ. [បិតុ+សេនេហ] សេចក្តីស្នេហាក្នុងបិតា, សេចក្តីស្រឡាញ់ក្នុងបិតា, សេចក្តីស្រឡាញ់ចំពោះបិតា។

បិត្ត នបុ. [អបិ+ធា+ត, លុបអ] ប្រមាត់, (វិ. **អបិ១ធាតីតិ>បិត្តं**) ។

បិត្វា អ. [បា+ត្វា, អានៃបា>ឥ] ផឹកហើយ, ហុតហើយ។

បិត្វាន អ. [បា+ត្វាន, អានៃបា>ឥ] ផឹកហើយ, ហុតហើយ។

បិ១ហតិ កិ. [អបិឬបិ+ធា+អ+តិ-វ., លុបអនៃអបិ] បិទ, រាំង, ខ្ទប់។

បិ១ហន នបុ. [អបិ+ធា+យុ, លុបអនៃអបិ] កិ.បិទ, កិ.រាំង; វិ. **បិ១ហិយតេតិ>បិ១ហនំ**។ **វេលា** ឥ. វេលាជាទីបិទ (វិ. **បិ១ហតិ ១ត្ថាតិ>បិ១ហនំ**) ។

បិ១ហន្ត គុ. [អបិ+ធា+អន្ត, លុបអ] កាលបិទ, កំពុងបិទ។

បិ១ហាបេត្វា អ. [អបិ+ធា+ណាបេ+ត្វា] ញ៉ាំង...ឱ្យបិទហើយ។

បិ១ហាបេសិ កិ. [អបិ+ធា+ណាបេ+ណ្ឍ-អជ្ជ., ចុ:ស-អា., លុបអ] ញ៉ាំង...ឱ្យបិទហើយ។

បិទហិត គុ. [អបិ+ធា+ត, ចុះ ត-អា., លុបអ] គឺ...បិទហើយ។ -**ទ្វារវាតបាន** គុ. មានទ្វារនិងបង្ហួចបិទហើយ។

បិទហិត្វា អ. [អបិ+ធា+ត្វា, លុបអ] បិទហើយ, រាំងហើយ។

បិទហី កិ. [អបិ+ធា+អ+តំ-អជ្ជ.] បិទហើយ។

បិធាន នបុំ. [អបិ+ធ៎ាឬធា+យុ, លុបអ] គ្រប, គម្រប (វិ. **អបិធ៎ាតិ អាតុណោតីតិ>បិធានំ**)។

បិធាយ អ. [អបិ+ធា+ត្វា, លុបអ] បិទហើយ។

បិនាស បុំ. រោគច្រមុះ, តឹងច្រមុះ (ដូច **ឆាសិការោគ**) ។

បិបាសា ឥ. [បា-បា+ស, អានៃបាអញ្ជាស>ឥ] សេចក្តីប្រាថ្នាដើម្បីផឹក (ការស្រេក, សេចក្តីស្រេក), វិ. **បាតុំ ឥច្ឆា>បិបាសា**។

បិបាសិត គុ. [បិបាស+ឥ+ត] អ្នកប្រព្រឹត្តទៅដោយសេចក្តីស្រេក។ **បិបាសិត** <បា-បា+ស+ត, ចុះ ឥ-អា. = ស្រេកហើយ។

បិឍ្ឌ នបុំ. ដើមអស្សត្ថព្រឹក្ស, កាំបិតតូចសម្រាប់កាត់សំពត់ (ក្ដ្រៃ) (ដូច **ឥត្ថ្ពេ្ជទនសត្ថក**) ។

បិឍ្ឌ, ឍី ឥ. [វិ+ផ+ណ្ឌ, វិ>បិ] ដីប្លី, ដើមលៀប, (ចាញ) ។ -**គុហា** ឥ. គុហាគឺបិណ្ឌិតកំណត់ហើយដោយដើមលៀប, ឬដីប្លី, គុហាជិតដើមលៀប។

បុច្ឆ ធា. **ឥ៎ិកសនេ បុច្ឆតិ បុច្ឆនំ បុច្ឆិតុំ បុច្ឆិត្វា** "រីក, ផ្ការ, បញ្ចេញផ្ការ" ភ្ជ. ។ **បុច្ឆ** នបុំ. "ផ្ការ, រដូវនៃស្ត្រី" អា. **បុច្ឆសា ឧប្ប៎ជ្ជតិ** (បុច្ឆ+អស្សា) ។ **បុច្ឆវតី** ឥ. "ស្ត្រីគ្រប់ការឬមានរដូវ" (ស្ងួចិ) ។

បិយ គុ. [បិ+យ] ជាទីស្រឡាញ់; វិ. **បិយេតិ តន្តិ>បិយោ**។ សេចក្តីស្រឡាញ់; វិ. **បិយនំ សិនេហនំ>បិយោ**។ -**កថា** ឥ. វាចាជាហេតុពោលជាទីស្រឡាញ់, វាចាជាហេតុពោលនាំមកនូវសេចក្តីស្រឡាញ់។ វាចាជាគ្រឿងពោលគឺបុគ្គលគប្បីស្រឡាញ់; វិ. **បិយិតព្ពាតិ>បិយា** (កថា)។ -**ភ្ជាហី** គុ. អ្នកកាន់យកនូវសត្វនិងសង្ខារជាទីស្រឡាញ់, គឺបុគ្គលគប្បីស្រឡាញ់។ -**ញ្ញាតិ** បុំ. ញាតិជាទីស្រឡាញ់។ -**ឥ** គុ. ជាទីស្រឡាញ់ជាង, ជាទីស្រឡាញ់វិសេស។ -**ទស្សី** អ.ន. ព្រះពុទ្ធទ្រង់ព្រះនាមបិយទស្សី។ -**បុត្ត** បុំ. កូនជាទីស្រឡាញ់។ -**ភរិយា** ឥ. ភរិយាជាទីស្រឡាញ់។ -**វគ្គវណ្ណនា** ឥ. កថាជាគ្រឿងពណ៌នានូវសេចក្តីនៃបិយវគ្គ។ -**វចន** នបុំ. ពាក្យជាទីស្រឡាញ់, ពាក្យគឺបុគ្គលគប្បីស្រឡាញ់។ -**សហាយក** បុំ. ឬគុ. សម្លាញ់ជាទីស្រឡាញ់។ -**សហាយ-ភវណ្ណ** បុំ. វណ្ណៈឬភេទនៃបុគ្គលជាសម្លាញ់ជាទីស្រឡាញ់។

-**សហាយិកាវណ្ណ** បុ. ភេទនៃស្ត្រីជាសម្លាញ់ជាទីស្រឡាញ់។

បិយក បុ. ដើមកទម្ព (ក្ទម្ព) (ដូច **កទម្ព**), ដើមធ្នង់ (ដូច **អសនោ**), ស្បែកប្រើស, ស្បែកឈ្មស់ ។

បិយङ្គុ ស្រូវផ្ការ (ដូច **ឥङ្គុ**), ដើមប្រយង់ (ដូច **សាមា**) ។

បិយាបាយ បុ. [បិយ+អបាយ] កិ.ទៅប្រាសចាកសត្វនិងសង្ខារជាទីស្រឡាញ់, កិ.ទៅប្រាសចាកសត្វនិងសង្ខារគឺបុគ្គលគប្បីស្រឡាញ់។

បិយាយតি កិ. [បិយ+អាយ+តি-វ.] ប្រព្រឹត្តនូវសេចក្តីស្រឡាញ់, ប្រព្រឹត្តស្រឡាញ់។

បិលក បុ. ក្ងានតូច, ក្ងានខ្ចី (ដូច **ឆាប**) ។

បិលङ្ឆ បុ. ដើមលៀប (ដូច **ឫទ្ធលី**) ។

បិលធ ធា. **អលङ្ការេ បិលន្ធតি បិលន្ធិត្វា** "ប្រដាប់, តាក់តែង" រុ. ។ **បិលន្ធនំ** នបុ. "គ្រឿងប្រដាប់, គ្រឿងអលង្ការ" ។ សព្ទជាវេវចន:គឺ **បិលន្ធនំ អលङ្ការោ មណ្ឌនំ ឥតូសនំ បសាធនំ អាភរណំ** -ស. ។

បិលន្ធន នបុ. [បិលន្ធ+យុឬបិលធ+យុ, ចុះនិ-អា.] កិ.ប្រដាប់, កិ.តាក់តែង; **បិលន្ធិយតেতি>បិលន្ធនំ**។ (គ្រឿងប្រដាប់, គ្រឿងតាក់តែង); (វត្ថុ) សម្រាប់ប្រដាប់, ជាគ្រឿងប្រដាប់; រ. **បិលន្ធតি ঌតেនាតি> បិលន្ធនំ**។ -**កាល** បុ. កាលជាទីប្រដាប់។ -**មុទ្ធិក** នបុ. ចិញ្ចៀនជាគ្រឿងប្រដាប់, សម្រាប់ពាក់។ -**ឥកតি** បុ. វត្ថុជាគ្រឿងប្រដាប់គឺបុគ្គលធ្វើឱ្យវិសេស, ឱ្យប្លែក, កិ.ធ្វើឱ្យប្លែកនៃវត្ថុជាគ្រឿងប្រដាប់, គ្រឿងប្រដាប់ដ៏ប្លែក។

បិលន្ធយីសុ កិ. [បិលន្ធ+ណយ+ঃ-អជ្ជ., ឬបិលធ+ណយ+ঃ-អជ្ជ. ចុះនិ-អា.] ប្រដាប់ហើយ, ពាក់ហើយ។

បិលន្ធិ កិ. [បិលន្ធ+អ+ল্য-អជ្ជ.] ប្រដាប់ហើយ, តាក់តែងហើយ។

បិលន្ធិតុং អ. [បិលន្ធ+តុং+ឥ-អា.] ដើម្បីប្រដាប់,...។

បិលន្ធិត្វា អ. [បិលន្ធ+ত্বা+ឥ-អា.] ប្រដាប់ហើយ,...។

បិលន្ធិសฺយามি កិ. [បិលន្ធ+អ+ស្យាមិ-ភ.+ឥ-អា.] នឹងប្រដាប់, នឹងពាក់។

បិលន្ធেយ্যাথ កិ. [បិលន្ធ+អ+ঌয্যাথ-ស.] គប្បីប្រដាប់,...។

បិលវ បុ. សត្វទុង។

បិលហি ធា. **ঘতিযং បិលហতি** "ទៅ, ដល់, ប្រព្រឹត្តទៅ" ភូ. ។

បិលិន្ទវচ্ছ អ.ន. ឈ្មោះបិលិន្ទវច្ឆ:។ -**ত্থেরবত্থু** នបុ. រឿងនៃព្រះថេរ:ឈ្មោះ...។

បិលោតিক គុ. សំពត់ចាស់, កំណាត់សំពត់។ -**ঘণ্ডনিবত্থু** គុ. អ្នកស្លៀកនូវបំណែកនៃសំពត់ចាស់, អ្នកស្លៀកនូវកំណាត់នៃសំពត់។ -**ত্থেরবত্থু**

នបុ. រឿងនៃព្រះថេរៈឈ្មោះបិណ្ឌោតិកៈ។

បិណ ធាតុ **ខេបេ បិណេតិ បិណយតិ** "ធ្វើឲ្យអស់ទៅ" ចុ. ។

បិវតិ កិ. [បា+អ+តិ-រ., បា>បិវ] ផឹក, ហុត។

បិវន នបុ. [បា+យុ, បា>បិវ] កិ.ផឹក; វិ. **បិយតេតិ>បិវនំ**។ **-អត្ថាយ** ដើម្បីប្រយោជន៍ដល់កិ.ផឹក។ **-ភាវ** បុ. ភាវៈនៃកិ.ផឹក, ភាវៈគឺកិ.ផឹក។

បិវន្ត គុ. [បា+អ+អន្ត] កាលផឹក, កំពុងផឹក។

បិវសិ កិ. [បា+អ+សិ-រ.] ផឹក, រមែងផឹក។

បិវាមិ កិ. [បា+អ+មិ-រ.] ផឹក, រមែងផឹក។

បិវិ កិ. [បា+អ+ណ្ឍ-អជ្ជ.] ផឹកហើយ។

បិវិតុកាម គុ. [បិវិតុំ+កម+ណ] ប្រាថ្នាដើម្បីផឹក, ចង់ដើម្បីផឹក; វិ. **បិវិតុំ កាមេតីតិ> បិវិតុកាមោ**។

បិវិត្វា អ. [បា+ត្វា+ឥ-អា.] ផឹកហើយ។

បិវិស្សាម កិ. [បា+អ+ស្សាម-ភ.+ឥ-អា.] នឹងផឹក។

បិវីសុ កិ. [បា+អ+ឧ-អជ្ជ.] ផឹកហើយ។

បិវេយ្យុ កិ. [បា+អ+ឯយ្យុ-ស.] គប្បីផឹក។

បិវំ គុ. [បិវន្ត+សិ-រ., ន្ត+សិ>អំ] កាលផឹក, កំពុងផឹក។

បិវ ធា. **ថូលិយេ បិវតិ** "ធាត់, ធំ, ក្រាស់" ភូ. ។ **បិវនោ** បុ. "អណ្តើក" = **កច្ឆបោ** -ស. ។

បិសន្ត សម្ព្ធរដំដែង, លឿងទន់ (ដូច **ឱ្ន**) ។

បិសាច បុ. បិសាច (អមនុស្សស៊ីសាច់) ។

បិសិត នបុ. សាច់ (ដូច **មំស**) ។

បិសុណា ឥ. [បិសិ+ឧន, ន>ណ+អា-ឥ.] (វាចា) ធ្វើនូវភាពនៃសេចក្តីស្រឡាញ់ឱ្យសូន្យ (វាចាជាហេតុញុះញង់); វិ. **បិយភាវំ សុញ្ញំ ករោតីតិ> បិសុណា**។

បិសុណ គុ. ជនអ្នកស៊ីកសៀត, អ្នកញុះញង់ (ដូច **ករណ្ណេជ្ជ**) ។

បិសិ ធា. ១-**ចុណ្ណនេ ឫសតិ ឫសេតិ ឫសកោ ឫ**ញ្ជោ "បុក, កិន, ធ្វើឲ្យល្អិត, ធ្វើឲ្យម៉ដ្ត" រុ.។ **បិសុណវាចា** ឥ. "សម្ដីស៊ីកសៀត, សម្ដីចាក់រុក, ពាក្យចុចបំបែក" (បិសិ+ ឧណ) **ឬ**សុញ្ញ<**បិសុណស្ស ភាវោ** (**ណ្យ**) ។ **ឫ**ជ្ជ នបុ. "ម្សៅ, លម្អិត" ។

២-**ពលចានេសុ ឫ**សេតិ **ឫ**សយតិ "អាច, មានសមត្ថភាព, ផឹក" ចុ. ។

៣-**ឬ**សនេ **ឬ**សេតិ **ឬ**សយតិ "បញ្ជូនទៅ, ប្រើទៅ" ចុ. ។

បេសេ្ស បុ. "បាវ, ខ្ញុំ"។
៤-**គតិយំ បិសតិ** "ទៅ, ដល់, ប្រព្រឹត្តទៅ" ភូ. ។
៥-**ភាសាយំ បិសេតិ បិសយតិ** "ពោល, និយាយ" ចុ. ។
៦-**ឧបទ្ទាហារវិជ្ជាវេសុ**
បេសតិ បិសតិ "ដុត, ឆេះ, ជាចំណែក, ជាផ្នែក" ភូ. ។

